សារព័ត៌មាន ខ្មែរផុស ស.រ.អា
KhmerPost USA
E-mail: info@khmerpost.us / Website : khmerpost.us
Advertising: 978-656-8141/ Hotline news: 978-942-1641

Free

មាតិការឿង Issue 181 July 26th. to Aug 09th. 2015

១-ទៅលេងញូយ៉កនាថ្ងៃ"យូឡាយហ្វ៊ត"...........០២
២-ទិវាបុណ្យឯករាជ្យ.................................០៣
៣-"ខពលស្ព៊ែរ"កំពុងកែលម្អ........................០៤
៤-ព័ត៌មានសំខាន់អន្តរជាតិ និងទាន់សភាពការណ៍...០៥
៥-រ៉ូដាយឡិន : ខួប២ឆ្នាំនៃវត្តមណ្ឌលពុទ្ធសាសនា.......០៦
៦-កាកបាទក្រហមខ្មែរ នឹងខុសច្បាប់ស្ដីពីសមាគម.......០៨
៧-ឃាតករប្រកាន់ពូជសាសន៍បានបាញ់សំលាប់...........១០
៨-លោក វ៉ា គឹមហុង : រាល់បញ្ហាព្រំដែនគ្រប់..........១៣

Office: Tel: (978) 677-7163 Fax: (978) 677-7092
45 Merrimack St. Suite 218A Lowell, MA 01852

បទវិភាគ

# ព្រំប្រទល់ខ្មែរវៀតណាម

ដោយ ពិន សំខុន



ពិន សំខុន

●●●ក្នុងខណៈដែលបញ្ហាព្រំប្រទល់ដែលខ្មែរវៀតណាមកំពុងតែក្លាយទៅជាព័ត៌មានដ៏ក្ដៅគគុកនៅអាស៊ីអគ្នេយ៍ខ្ញុំសូមលើកយកបទវិភាគមួយមកជូនជាសណ្ដាប់បន្ទាប់ពីខកខានមិនបានបញ្ចេញយោបល់ជាយូរបន្តិចមកហើយ ។

ជាង២០ឆ្នាំកន្លងមកនេះ វៀតណាមធ្វើអ្វីគ្រប់យ៉ាងដើម្បីយកទឹកដីបរទេសដែលនៅជុំវិញខ្លួន មានឡាវ មានខ្មែរ ឥឡូវមានទាំងលួចដីចិន ជាអ្នកជិតខាងខ្លួនថែមទៀត ។ ស្រាប់តែឆ្នាំចុងក្រោយនេះ ចិនភ្ញាក់ឡើង វាយវៀតណាមចេញពីកោះស្ប្រាតលី យ៉ាងអាម៉ាស់ ឥឡូវមានខ្មែរក៏ផ្ដើមភ្ញាក់ឡើងដែរ និយាយថា, ព្រំប្រទល់វៀតណាមបោះក្នុងដីខ្មែរ។ ខ្ញុំតែងតែនឹកថា វៀតណាមជាប្រទេសកុម្មុយនីស្តច្បាស់ជាមានកម្លាំងទ័ពដ៏រឹងមាំប្រជាជនគេមុខជាស្រុះស្រួលគ្នាក្នុងការដណ្ដើមពង្រីកទឹកដីរបស់គេជាមិនខានទេ។

ខ្ញុំបានទៅដល់ស្រុកយួន គេហៅថា កម្ពុជាក្រោមកាលពីចុងឆ្នាំមុនបានឃើញខ្មែរពេញផ្ទៃកខាងត្បូងរស់នៅជាខ្មែរ គឺនៅពេញ១ភាគ៣ នៃស្រុកយួនទាំងមូល។ ខ្ញុំបានដឹងទៀតថា នៅផ្ទៃកកណ្ដាលនៃស្រុកដដែលយួន គឺជាប្រជាជនភាគតិចក្នុងតំបន់ដែលមានម្ចាស់ដើមរបស់គេដូចជាពួកម៉ុង ចារ៉ៃ ម៉ុងតាញ៉ា ដែលមកទល់ថ្ងៃនេះ មិនទាន់ជ្រាបចូលជាយួនបាននៅឡើយទេ។ នៅសល់១ភាគ៣ទៀតប៉ុណ្ណោះ ដែលនៅខាងជើងហាណូយ ទើបមានយួនជាប្រជាជនភាគច្រើន។

ក្នុងភូមិសាស្ត្ររបៀបនេះ តទៅទំព័រទី ១៧

# ពិធីបុណ្យគ្រប់ប្រពៃណីនៅឡូវែល

## Lowel Forlk Festival



២០១៥ខ្មែរផុសស.រ.អា.ដូចរៀងរាល់រដូវក្ដៅ នាចុងខែកក្កដាឆ្នាំ២០១៥នេះ ទីក្រុងឡូវែលមិនបានស្ងប់ស្ងាត់ដូចក្រុងដ៏ទៃឯទៀតនៃស.រ.អា. ដែលអ្នកធ្វើការតែងយកវិស្សមកាល ហើយចេញពីទីក្រុងអស់នោះទេ ផ្ទុយទៅវិញ នៅក្នុងរយៈ៣ថ្ងៃនៃចុងខែកក្កដានោះ ជនជាតិទាំងអស់នៃសហគមន៍ឡូវែលបានចេញមកបង្ហាញខ្លួនបង្ហាញសំលៀកបំពាក់បង្ហាញម្ហូបអាហារបង្ហាញភ្លេងចំរៀង ជាពិសេសលើកទង់ជ័យបង្ហាញអត្តសញ្ញាណតែរៀងៗខ្លួនទៅវិញទៅមកយ៉ាងហោចណាស់ក៏បានម្ដងក្នុង១ឆ្នាំដែរ គឺពេលនេះឯង។

ក្បួនដង្ហែរព្យូរយាត្រាបានចេញដំណើរនៅម៉ោង៦កន្លះល្ងាចថ្ងៃសុក្រពីសាលាក្រុងសំដៅទៅឱទ្យានប្រវត្តិសាស្ត្រជាតិ National Historic Park ដែលបានក្លាយទៅជាអ៊ូអរជាមួយនឹងមនុស្សរាប់ពាន់នាក់ចេញមកទទួលស្វាគមន៍ប្រជាជនប្រមាណ២០សញ្ជាតិដែលបានមកលើកទង់ជាអត្តសញ្ញាណប្រទេសគេម្នាក់ៗនៅក្នុងនោះសហគមន៍ខ្មែរ ក៏បានបញ្ចេញមុខមាត់ជាសហគមន៍ដ៏ធំមួយជាមួយសមាគមខ្មែរនឹងបេក្ខជនក្រុមប្រឹក្សាក្រុង២រូបព្រមទាំងបេក្ខជនក្រុមប្រឹក្សាសាលារៀន២រូបទៀត ចូលរួមដង្ហែរក្បួនព្យូយាត្រាដែរ។

នៅតាមផ្លូវនៃក្បួនដង្ហែរដឹកមុខដោយភ្លេងផ្លុំនៃក្រុមញូអ័រលីនអ្នកដំណើរ នឹងក្រុមពាណិជ្ជករ តទៅទំព័រទី ០៣

REMEDIUM PHARMACY
ឱសថស្ថានរ៉ុមីឌៀម
2 Vinal Square. North Chelmsford, MA 01863
ជាឱសថស្ថានបំរើការគ្រប់យ៉ាងដល់អ្នក
• ផ្ទេរឬផ្លាស់ប្ដូរសេវាកម្ម
• ការវេចខ្ចប់ឱសថ
• ការលាយផ្សំឱសថ
• បញ្ជូនឱសថដល់ផ្ទះដោយឥតគិតថ្លៃ
• ជួយធ្វើសំបុត្រទិញថ្នាំ
• ផ្លាស់ប្ដូរយោបល់ដោយរាក់ទាក់
ឱសថស្ថានយើងខ្ញុំនិយាយភាសាខ្មែរ
FREE daily delivery | Bliterpack Packaging | Compounding Medication
Friendly consultations | Easy Transfers
Tel: 978-251-7070 | Fax: 978-251-7071

# សមាគមខ្មែររៀបចំពិធីបង្ហាញម៉ូដសំលៀកបំពាក់

## CMAA:

រាត្រីបង្ហាញសម្រស់យុវនារីសំលៀកបំពាក់ម៉ូដនឹងប្រព្រឹត្តទៅថ្ងៃសុក្រទី ៣១កក្កដា២០១៥ នៅភោជនីយដ្ឋាន LENZI'S Restaurant Dracut, MA រៀបចំឡើងដោយ សមាគមខ្មែរ ដើម្បីប្រមូលថវិការសម្រាប់កម្មវិធីចាំបាច់របស់សមាគម ។ ពីធីករពិសេស Ms. ShalaMurray ។

ព័តមានបន្ថែមនឹងសំបុត្រចូល Vichtcha Kong (978) 996 2479




Ms. Shala Murray, Attleboro, MA.

# ទៅលេងញ៉ូយ៉កនាថ្ងៃ "យូឡាយហ្វ័ត" (ភាគ២បញ្ចប់)

## July 4th.at New York City



**ដោយ : ពិន សំខុន**

"ថាមស្គែ"នាទីក្រុងញូយ៉ក គឺជាតំបន់កណ្តាលក្រុងដ៏មួយតូចទេ តែនរណាក៏ស្គាល់ចង់បានឃើញគេបានម្តងដែរ ដោយសាររៀងរាល់ដំណាច់ឆ្នាំម្តង១គ្រប់ស្ថានីយទូរទស្សន៍បានផ្សាយបន្តផ្ទាល់ពីវិនាទីចុងក្រោយប្រចាំឆ្នាំពីទីនោះទៅ។ ហេតុនេះហើយ បានជាច្រើនឆ្នាំក្រោយមក ថាមស្គែ នេះបានក្លាយជាមណ្ឌលផ្សាយពាណិជ្ជកម្មដ៏ធំជាងគេបង្អស់នៅសហរដ្ឋអាមេរិកនេះ មានជញ្ជាំងផ្សព្វផ្សាយអេឡិកត្រូនិករាប់រយពាន់ផ្ទាំងគ្មានជញ្ជាំងណាមួយសល់ទំនេរនោះទេ។ មនុស្សម្នាដើរស្ទើរជាន់កគ្នាពីហាងមួយទៅហាងមួយដែលរៀបតាំងលំអផលិតផលរបស់ខ្លួនតាមសិល្បៈទីផ្សារទំនើបបំផុត បើទោះជាភ្ញៀវមិនគ្រោងទិញអ្វីក៏ដោយ ក៏គង់ចង់មើលហាងទាំងនោះដែរ។







ម៉ោង១០យប់ទៅហើយ យើងគ្មានឃើញមនុស្សហត់ហេវ ឬងោកងុយ ឬក៏ហាងផ្តើមឈប់លក់ដូរដោយសារយប់កាន់តែជ្រៅនោះទេ ផ្ទុយទៅវិញ វិចិត្រករនៅគូររូបឱ្យភ្ញៀវដែលបន្តកន្ទុយរង់ចាំនៅឡើយ អ្នកលក់ "ហតឌុក" តាមចិញ្ចើមថ្នល់ ក៏នៅតែផ្តល់ម្ហូបយ៉ាងញាប់ដៃ...មនុស្សនៅតែច្រើនណែនទំនងជារង់ចាំការបាញ់កាំជ្រួចនៃ "យូឡាយហ្វ័ត"... តែគ្មាននរណាអាចមើលឃើញទេ ពីព្រោះផ្ទះនៅជុំវិញខ្ពស់ៗណាស់។ ម៉ោង១១យប់ទៅហើយ ឃើញប៉ុណ្ណារ៉ូ រាងអស់កម្លាំង ហើយក៏មិនដឹងថា ធ្វើយ៉ាងដូចម្តេច ទើបអាចចូលទោះមើលគេបាញ់កាំជ្រួចបាន ពីព្រោះផ្លូវបានត្រូវបិទអស់ទៅហើយនោះ? យើងសម្រេចចេញដំណើរទាំងយប់ទៅហ្វីឡាដែលហ្វៀខកខានមិនបានមើលកាំជ្រួចនោះទៅ ពីព្រោះមានមិត្តរង់ចាំនៅទីនោះ។ ដំណើរយើងមានតែ២ម៉ោងប៉ុណ្ណោះហើយអ្នកបើកឡានឈ្មោះ សួន ជាយុវជនមាំមួនធានាថានឹងបើកទៅដល់ដោយមិនបាច់ជួយ។

ម៉ោង១ទាបភ្លឺ យើងបានទៅដល់ហ្វីឡាខាងជើងជាទីកន្លែងសម្រាករបស់យើង។ យើងមានក្តីរំភើបក្នុងចិត្តដោយនៅតំបន់នោះ ជាកន្លែងដែលចាប់ប្តើមកាសែតខ្មែរផុសកាលពី៨ឆ្នាំមុន ប៉ុណ្ណារ៉ូ ក៏កើតនៅទីនោះ កាសែតក៏បានចែកចាយយ៉ាងទៀងទាត់២សប្តាហ៍ម្តងមិនថាចំណេញ ឬខាតមានបុគ្គលិកជួយ ឬអត់ភ្លៀងផ្គរ ឬមេឃស្រឡះ ហើយក៏ហៀវហូរ ទៅដល់រ៉ូដអាយឡិននឹងឡូវែលនៅ៣ឆ្នាំក្រោយមក។ ដូច្នេះការមកដល់នេះ ជាការត្រឡប់ទៅរកប្រភពដើមរបស់យើងសម្រាប់ប្រៀបធៀបការប្រែប្រួលនៅទីនោះ ថាតើបានរីកចំរើនដល់ណាហើយ តើមិត្តភ័ក្រ្តណាខ្លះនៅរស់ ឬចាកលោកខ្លះទៅហើយ ឬក៏ផ្លាស់ប្តូរទីកន្លែង?

នៅហ្វីឡាដែលហ្វៀមានប្រជាជនដើមកំណើតខ្មែរ ២-៣ម៉ឺននាក់ដែរ គឺជាក្រុងទី៣ដែលសម្បូរខ្មែររស់នៅនាស.រ.អានេះ បន្ទាប់ពីឡុងប៊ិច នឹងឡូវែលមក។ តំបន់ខាងជើងកន្លែងដែលប្រមូលបុំសហគមន៍ខ្មែរស្ថិតនៅតាមបណ្តោយផ្លូវ"វ៉ាយស៊ីងសាន់" នឹងផ្លូវ"អូលយ៉ក"មានពាណិជ្ជករអាស៊ីតូចធំនឹងវត្តខ្មែរ២ វត្តឡាវ១។ ចំណែកនៅតំបន់ពីកណ្តាលក្រុងទៅខាងត្បូងមានតំបន់ចិន"ឆាយណាថោន"នៅផ្លូវ"ម៉ាកិតស្ទ្រីត" -តំបន់សម្បូរវៀតណាមរកស៊ី គឺនៅផ្លូវ "វ៉ាស៊ីនតោន"។ រីឯខ្មែរច្រើនរស់នៅតំបន់ខាងត្បូងម្តុំផ្លូវលេខ៦ នឹងលេខ៧ រហូតដល់ផ្លូវ"អូរេគ្វាន់" ទីនោះគេស្ទើរតែអាចហៅថា "ក្រុងខ្មែរ" បានទៅហើយ ហើយមានវត្តដ៏សំខាន់តែមួយ គួរជាទីគោរពគឺវត្តព្រះពុទ្ធរង្សីតាំងតែពីវត្ត "ប៉ាលីល័យ" ប្តូរទីកន្លែងទៅនៅតំបន់ខាងលិចទៅនោះ។ នៅតំបន់ខាងលិចជាតំបន់ក្រីក្រជាងគេ ក៏មានខ្មែរទៅរស់នៅទីនោះច្រើនដែរ...ឥឡូវនេះបានអ៊ូអរគ្រាន់បើ ដោយសារវត្ត "ប៉ាលីល័យ" ទៅឈរជើងនៅទីនោះ ។ សហគមន៍ខ្មែរនឹងឡាវរស់នៅរកស៊ីជិតគ្នាមានការស្រុះស្រួលជាមួយគ្នាប្រសើរណាស់ តែមិនមានតំណាងជាផ្លូវការណ៍ ដូចនៅឡូវែលនៅឡើយទេ។

អ្នកដែលទៅលេងហ្វីឡាដែលហ្វៀគួរដឹងថាដំបន់អាស៊ីនៅត្រង់ណាខ្លះ? ទើបទៅលេងសប្បាយបាន ពីព្រោះទីនោះ ជា "អាមេរិកកូនកាត់" ថ្វីត្បិតតែមិនសូវស្អាតតែជាតំបន់ថ្មី មិនមានអ្វីដូចអាមេរិកកណ្តាលក្រុង ហើយក៏មិនដូចជា

តទៅទំព័រទី ១៨







តមកទំព័រទី ០១

## ពិធីបុណ្យគ្រប់ប្រពៃណីនៅឡូវែល...

តាំងទីនៅតាមដងផ្លូវបង្ហាញពីផលិតផលរបស់ខ្លួនបានសម្តែងការអបអរទទួលក្បួនដង្ហែរ។ នៅមានតូបខ្លះ នៅទំនេនៅឡើយនាល្ងាចថ្ងៃសុក្រតែនឹងបំពេញនៅថ្ងៃបន្ទាប់ៗដោយសិល្បករដោយអង្គការ ឬដោយក្រុមសេវាកម្មផ្សេងៗដែលមានបំណងនឹងទាក់ទាញភ្ញៀវសម្រាប់ពាណិជ្ជកម្មរបស់គេតែយើងនៅមិនទាន់ឃើញពាណិជ្ជករខ្មែរតាំងនៅទីនោះនៅឡើយទេ។

លោកអភិបាលក្រុងឡូវែល អេលិយ៉ុត រ៉តនីយ បានប្រកាសសម្ពោធកម្មវិធីនៅក្នុងឱទ្យានជាតិដែលស្ថិតនៅពីមុខសារមន្ទីររោងចក្រតម្បាញ Boott Cotton Mills របស់ក្រុងឡូវែល ដែលទាំងមូលអណ្តែតលើបណ្តាញអូរទឹកសិប្បនិមិត្តខ្វាត់ខ្វែងមានបុគ្គលិកឱទ្យានជាតិ គេថែរក្សាឱ្យចូលជាសួនច្បារឱទ្យានជាតិរួមគ្នាធ្វើឱ្យឡូវែលកាន់តែមានសោភ័ណភាពនឹងកេរឈ្មោះកាន់តែល្បីជុំវិញតំបន់នៃស.រ.អា.។ លោករ៉តនីយសង្កត់បន្ថែមថាឡូវែលជាក្រុងនៃអន្តោប្រវេសន៍ធ្វើឱ្យភ្ញៀវអ្នកស្តាប់ទាំងអស់មានមោទនភាពនឹងរីករាយក្រៃលែងរាប់ទាំងលោក រ៉តនី ខ្លួនឯងផង។ រីឯភ្ញៀវកិត្តិយសនៅលើឆាក គឺតំណាងឱ្យភាគី៦ក្រុមរួមចំណែកអភិវឌ្ឍន៍ឡូវែលនឹងតំបន់ជុំវិញ មានគណៈក្រុមប្រឹក្សាក្រុង City Council អភិរក្សឱទ្យានជាតិ National Park ការិយាល័យពាណិជ្ជកម្ម Chamber of Commerce ការយាល័យទេសចរ ConventionVisiterBureau អង្គការវប្បធមិ Cultural Organisation Of Lowell ហើយភ្ញៀវកិត្តិយសជាខ្មែរម្នាក់ដែរនោះគឺលោក រ៉ាឌី ម៉ម ជាតំណាងរដ្ឋ State Representative ធ្វើច្បាប់លើកតំកើងឡូវែលនៅបូស្តុន។



២០១៥ខ្មែរផុសស.រ.អា.នៅពេលដែលសកម្មភាពទទួលភ្ញៀវចេះតែទៅមុខក្នុងរយៈពេលបីថ្ងៃយ៉ាងវែងនោះ LTC ក៏បញ្ចេញស្នាដៃថ្មីដោយផ្សាយទូរទស្សន៍បន្តផ្ទាល់៥ទៅ៧ម៉ោងក្នុងមួយថ្ងៃពីតំបន់កាន់តែធំក្នុងពេលជាតែមួយ។ ពិធីករឆ្នាំនេះគឺ សូបិន ពិន ពីកាសែតខ្មែរផុសស.រ.អា.












តទៅទំព័រទី ០៦










# រំលឹកព័ត៌មានពីថ្ងៃ២៧ឧសភា ដល់ ១៤កក្កដា២០១៥

**ដោយលោក ហ្វ្រង់ស្វ័រ ប៉ុងសូរ**



លោក ជា ស៊ីម ប្រធានព្រឹទ្ធសភាបានចូលមរណភាពកាលពីថ្ងៃទី៨ មិថុនា ក្នុងជន្មាយុ ៨២ឆ្នាំ។ កើតពីឆ្នាំ១៩៣២ នៅរមាស ខេត្តស្វាយរៀង ជា ស៊ីម បានក្លាយទៅជាអ្នកតស៊ូប្រឆាំងនឹងបារាំង នៅឆ្នាំ១៩៥២ ក្នុងនាមជាក្រុមឥស្សរៈ បន្ទាប់ពីឆ្នាំ១៩៧០មក ក៏បានក្លាយជាថ្នាក់ដឹកនាំតូចតាចម្នាក់នៃក្រុមខ្មែរក្រហម។ លោកមានតំណែងជាប្រធានក្រុមនៅពញាក្រែកក្នុងរបបខ្មែរក្រហម ហើយផ្តាច់ចេញពិរបប ប៉ុល ពត វិញនៅឆ្នាំ១៩៧៨ ដើម្បីទៅលាក់ខ្លួមនៅវៀតណាម លោកគឺជាស្ថាបនិកនៃ FUNSK (Front Uni National de Salut du Kampuchéa) រណសិរ្សរួបរួមជាតិកម្ពុជា។ នៅថ្ងៃ២ ធ្នូ១៩៧៨ លោកបានហៅវៀតណាមឱ្យមករំដោះកម្ពុជា។ នៅក្នុងរយៈពេលដំបូងនៃរបបកម្ពុជាប្រជាមានិត១៩៧៩-៨៩ លោកគឺជារដ្ឋបន្ត្រីក្រសួងមហាផ្ទៃដែលមានដៃក្តៅ ហើយបានចាប់ខ្លួនពួកបដិវត្តន៏ជាច្រើនដែលនៅជុំវិញ ហ៊ុន សែន ដែលមានអាយុក្មេងជាង២០ឆ្នាំ ហើយដែលជាតារាកំពុងល្បីឈ្មោះនៅក្នុងរបប។ បន្ទាប់ពីរៀបរដ្ឋប្រហារមួយប្រឆាំង ហ៊ុន សែន នាឆ្នាំ១៩៩៨លោកបានបាត់បង់អំណាច



ម្តងបន្តិចៗ ជាពិសេសបន្ទាប់ពិជម្ងឺខួរក្បាល នាឆ្នាំ ២០០០មក ។ គណប្រតិភូបក្សកុម្មុយនីស្តវៀតណាមក្នុងនោះមានប្រធានរដ្ឋសភាវៀតណាមផង បានមកគោរពសពលោក ជា ស៊ីម ជាចុងក្រោយជាសញ្ញានៃចំណងមិត្តភាពដ៏ល្អរវៀងខ្មែរនឹងវៀតណាម ។ សពលោកបានត្រូវបូជាយ៉ាងឧឡារិក្ស នាថ្ងៃ១៩មិថុនានេះ នៅមុខវត្តបូទុមវតី ។

## នយោបាយក្នុងស្រុក

បន្ទាប់ពីបរាជ័យឆ្នោតថ្ងៃ២៧កក្កដា ២០១៣ មកគណបក្សប្រជាជនខិតខំយ៉ាងខ្លាំង ដើម្បីបិទមាត់អ្នកប្រឆាំងនឹងសេរីភាពខាងបញ្ចេញមតិ

-រដ្ឋភិបាលប្រញាប់ប្រញាល់អនុម័តច្បាប់ស្តីពីអង្គការក្រៅរដ្ឋាភិបាល (អ.ក.រ.) ដែលទុកចោលជាយូរឆ្នាំណាស់មកហើយ ហើយជាផ្លូវការច្បប់សម្រាប់ទប់ស្កាត់ភរវកម្មផ្ទៃក្នុងនៃពួកគេ។ គម្រោងនេះបង្កើតឱ្យមានប្រតិកម្មយ៉ាងច្រើនពី អ.ក.រ ពីស្ថានទូតស.រ.អា. ពីសហគមន៏អឺរ៉ុប ដែលមើលឃើញថា ជាការប៉ុនប៉ងបំបិទមាត់ អ.ក.រ.ណាដែលហ៊ានប្រឆាំង(លទ្ធភាពនឹងបិត អ.ក.រ.ដែលរំខានទម្លាប់របស់ប្រទេស ឬទប់មិនឱ្យបើកអ.ក.រ.ដោយមិនចាំបាច់ពន្យល់ហេតុផល ឬបង្ខំឱ្យបង្ហាញសេចក្តីរាយការណ៏ហិរញ្ញវត្ថុនឹងសិលធមិប្រចាំឆ្នាំ។ល។) ។ អ.ក.រ.រអ៊ូថា ពួកគេមិនបានត្រូវសួរយោបល់ទេ ហើយគេមានតែអត្ថបទគម្រោងចាស់គំរិលអាយុ៣ឆ្នាំមុនតែប៉ុណ្ណោះ។ ពួកគេបានសម្តែងបាតុកម្មជំទាស់ច្រើនដងហើយ...ថ្ងៃ៣០មិថុនា កងប៉ូលិសបានទប់ស្កាត់បាតុករអ.រ.ក.ជាច្រើនរយនាក់(ខេមបូឌាដេលី១.៧.១៥)

-ថ្ងៃ៦កក្កដា ច្បាប់បានត្រូវអនុម័តដោយគណរដ្ឋមន្ត្រី **តទៅទំព័រទី ២២**




MIDDLESEX Community College
BEDFORD • LOWELL
ACADEMY OF HEALTH PROFESSIONS
Begin a career in health care!
MCC's Academy of Health Professions offers short-term training and college-credit programs that can lead to a satisfying job in the fast-growing field of health care.
Medical Receptionist (includes Medical Billing)
Nursing Assistant
Medical Office Administration (includes Insurance and Medical Coding)
Medical Assistant
Clinical Laboratory Assistant
Phlebotomy
Day, evening, weekend, and accelerated courses are available.
BEST
WINNER 2014
Register today for fall courses. Seats are limited!
To learn more, contact 1-800-818-3434 or admissions@middlesex.mass.edu
www.middlesex.mass.edu/AHP


MIDDLESEX Community College
BEDFORD • LOWELL
Everyone teaches, everyone learns.
Middlesex offers 70+ degree & certificate programs, and hundreds of noncredit courses. Earn a degree, begin a bachelor's degree or upgrade your skills.
• A price you can afford
• Small-class environment
• Flexible schedule
• Online or on campus
Classes begin SEPTEMBER 9
REGISTER NOW!
STAY CONNECTED...
To learn more, call 1-800-818-3434
or visit www.middlesex.mass.edu


FREE BRACES!
(Free Braces apply only to Eligible MassHealth patients under 21.
Value ranges from $155 to $4300 depending on need)
The BRACES PLACE
Dr. Mouhab Rizkallah DDS MSD
MassHealth & All Insurances
(978) 454-0774
bracesplaces.com
710 Chelmsford St
Lowell, MA 01851

តមកពីទំព័រទី ០៣ ពិធីបុណ្យគ្រប់ប្រពៃណីនៅឡូវែល...

ចូលរួមជាមួយ រ៉ាយិន ស្ហ៊ា ដែលមានបទពិសោធន៍៩ឆ្នាំពីការផ្សាយបន្តផ្ទាល់របស់ LTC ។ សូបិន ក៏ទៅពីគណកម្មការសេដ្ឋកិច្ចសាលាក្រុងឡូវែលនឹងពីខាងគណកម្មការនាយកក្រសួងទេសចរតំបន់ចូលរួមរាយការជាលើកដំបូងជាធនធានមនុស្សថ្មីរបស់ទូរទស្សន៍ ។

នៅមានធនធានមនុស្សថ្មីជាច្រើនទៀត ដែលចូលរួមអភិវឌ្ឍន៍ក្នុងក្រុងដែលធ្វើកាន់តែប្រសើរសម្រាប់ពលរដ្ឋរស់នៅដោយមានសកម្មភាពដោយការងារដោយការកែរលំអដោយសម្តែងសិល្ប...ធ្វើឱ្យឡូវែលរស់រវើកមិនត្រឹមតែនៅហ្វូកហ្វេសទីវលទេ គឺនៅរាល់ថ្ងៃ ៕













# REMEDIUM PHARMACY

2 VINAL Square
N. Chelmsford, MA 01863

Phone: (978) 251-7070

## FREE Daily Home Delivery



**Blisterpack Packaging**

**Friendly Consultations**

**Compounded Medications**

**Easy Transfers**

បុគ្គលិកទាំងអស់របស់ឱសថស្ថានរីមីឌីមយើងខ្ញុំមានបទពិសោធន៍គ្រប់គ្រាន់ក្នុងការបំរើសេវាផ្តល់ឱសថជូនដល់សហគមន៍ខ្មែរ។ គេទាំងអស់គ្នាបានត្រៀមរួចជាស្រេចដើម្បីជួយ និង ត្រៀមបំរុងជានិច្ច ដើម្បីប្រើគ្រប់ជំនាញ និង ការពិសោធន៍ក្នុងការបំរើលោកអ្នក។




ឱសថស្ថានរីមីឌីម ផ្តល់ជូនលោកអ្នកនូវ:

**ជូនឱសថឲ្យដល់លំនៅស្ថានដោយឥតគិតថ្លៃ**
**ដាក់ឱសថក្នុងបន្ទះបែងចែកឱសថសំរាប់ប្រើតាមពេល**
**ការពិគ្រោះយោបល់យ៉ាងរាក់ទាក់ស្និទស្នាល**
**មានផ្តល់ជូនម្សៅថ្នាំលាយ**
**ភាពងាយស្រួលក្នុងការផ្ទេរចេញចូល**



Cristina គ្រីស្ទីណា:
គ្រីស្ទីណាមានការពិសោធន៍គ្រប់គ្រាន់នៅក្នុងកិច្ចការបំរើសហគមន៍ខ្មែរក្រុងឡូវែលអស់រយៈពេលជាង៣ឆ្នាំមកហើយ។អ្នកស្រីគឺជាឱសថការិនីដែលគ្រប់គ្រងឱសថស្ថាន រីមីឌីម នេះ ហើយគាត់ក៏អាចធ្វើការពិគ្រោះអំពីឱសថ ជូនលោកអ្នកដល់ផ្ទះផងដែរ។ ដោយសារការផ្តល់នូវសេវាកម្មផ្នែកឱសថនេះ បានច្បាស់លាស់ទើប អ្នកស្រីអាចបង្កើត បាននូវចំណងមិត្តភាពយ៉ាងល្អប្រពៃក្នុងសហគមន៍ខ្មែរក្នុងក្រុងឡូវែល ហើយអ្នកស្រីមានសេចក្តីរីករាយណាស់ដើម្បីរង់ចាំបំពេញនូវបំណងរបស់លោកអ្នកដែលត្រូវការឱសថ។



Pahim លោកប៉ាហ៊ីម:
គឺជាបុគ្គលម្នាក់ដែលមានការគោរពច្រើននៅក្នុងសហគមន៍ខ្មែរ គាត់ក៏ជាសមាជិកម្នាក់នៅក្នុងគណកម្មការវត្តត្រៃរតនារាម ហើយធ្លាប់មានការពិសោធន៍ជាច្រើនឆ្នាំក្នុងការជួយសហគមន៍ដែលត្រូវការព្យាបាលជម្ងឺ។ ក្នុងរយៈកាលកន្លងមក គាត់ធ្លាប់បានធ្វើការយ៉ាងច្រើនជួយគាំទ្រដល់អ្នកជម្ងឺនៅមជ្ឈមណ្ឌលសុខភាពសហគមន៍ក្រុងឡូវែលនិងមណ្ឌលសុខភាពពេទ្យមេត្តាព្រមទាំងធ្លាប់បានចូលរួមចំណែកក្នុងការថែទាំដោយឱសថសំរាប់សហគមន៍ខ្មែរក្រុងឡូវែលអស់រយៈពេលជាង២ឆ្នាំផងដែរ។ ក្នុងនាមជសមាជិកម្នាក់នៃឱសថស្ថានរីមីឌីម គាត់នឹងបន្តធ្វើការបំរើឱ្យកាន់តែខ្លាំងខ្លាថែមទៀតដើម្បីបំពេញនូវតំរូវការក្នុងការផ្តល់ឱសថដល់លោកអ្នក។



Dary ដារី:
តែងបានយកចិត្តទុកដាក់ជាប់ជានិច្ចក្នុងសេវាកម្មផ្តល់ឱសថ ដើម្បីបំពេញតាមតំរូវការនៃសហគមន៍ខ្មែរក្រុងឡូវែលអស់រយៈជាង២ឆ្នាំមកហើយ ហើយតែងទទួលបាននូវការកោតសរសើរពីសំណាក់អតិថិជនដែលបានជួបបាស្រ័យជាមួយគាត់។ ក្នុងឋានៈជាអ្នកបច្ចេកទេសម្នាក់របស់ឱសថស្ថាន គាត់មានការយល់ដឹងយ៉ាងជ្រៅជ្រះអំពី តំរូវការ និងប៉ិនប្រសប់ក្នុងការផ្តល់សេវាជូនលោកអ្នកនិងចេះសំដែងនូវការគោរពយ៉ាងទន់ភ្លន់ចំពោះលោកអ្នកផងដែរ។



Kelly ខែលលី:
គឺជាឱសថការិនីយើងដែលអាចនិយាយភាសាខ្មែរហើយដែលយកចិត្តទុកដាក់ចេះជួយលោកអ្នក។ គាត់ជាឱសថការិនី ចេញពីមហាវិទ្យាល័យឱសថសាស្រ្តរដ្ឋម៉ាសាឈូសេត និង ពេញចិត្តធ្វើការបំរើសហគមន៍ខ្មែរដែលគាត់ក៏ជាសមាជិកម្នាក់នៃសហគមន៍នេះដែរ។



Daniela ដានីញែលឡា:
មានជំនាញច្បាស់លាស់ក្នុងការវេចខ្ចប់ឱសថដាក់ក្នុងបន្ទះពង្រាយថ្នាំសំរាប់ប្រើតាមពេល ហើយធ្លាប់ឆ្លងកាត់ការថែទាំអ្នកជម្ងឺខ្មែរដែលរស់នៅក្នុងក្រុងឡូវែលនេះអស់រយៈពេលជាង៣ឆ្នាំមកហើយ។ ប្រសិនបើលោកពេញចិត្តនឹងការប្រើថ្នាំដាក់ក្នុងបន្ទះបែបនេះ ដានីញែលឡាពេញចិត្តណាស់នឹងធ្វើកិច្ចការនេះជូនលោកអ្នក។



Kassandraកាសាន់ដ្រា:
គឺជាបុគ្គលិកដែលមានការពិសោធន៍ច្រើនក្នុងការធ្វើទំនាក់ទំនងជាមួយសហគមន៍ខ្មែរ និងស្ប៉ានិសសដែលរស់កក្នុងងក្រុងឡូឡូវែលលនេះ។
លោកអ្នកអាចនឹងពេញចិត្តអំពីភាពរាក់ទាក់រាល់ពេលនិយាយឆ្លើយឆ្លងតាមទូរស័ព្ទជាមួយនាង និងប៉ិនប្រសប់ក្នុងការរៀបចំឱសថជូនលោកអ្នកនៅរាល់ពេលដែលលោកអ្នកត្រូវការ។




# More benefits. $0 cost.

If you are 65 or older and qualify for MassHealth Standard, our plan could get you more benefits than Original Medicare.

With **UnitedHealthcare® Senior Care Options (HMO SNP)**, your doctor, hospital and prescription drug coverage are all under one convenient card.

Plus, you'll get extra benefits — at no cost to you. These extra benefits include:

- **$0 co-pay** for dental cleanings, fillings, dentures and more.
- **$0 co-pay** for all covered medications.
- **$0 co-pay** for eyewear.
- **$0 co-pay** for rides to doctor appointments.





Call **1-781-888-7779, TTY 711,** and one of our local, licensed agents can help you find out if you could get more benefits at no cost to you.

UnitedHealthcare® Community Plan

UnitedHealthcare SCO is a Coordinated Care plan with a Medicare contract and a contract with the Commonwealth of Massachusetts Medicaid program. Enrollment in the plan depends on the plan's contract renewal with Medicare. This plan is a voluntary program that is available to anyone 65 and older who qualifies for MassHealth Standard and Original Medicare. If you have MassHealth Standard, but you do not qualify for Original Medicare, you may still be eligible to enroll in our MassHealth Senior Care Option plan and receive all of your MassHealth benefits through our SCO program. The benefit information provided is a brief summary, not a complete description of benefits. For more information contact the plan. Limitations, co-payments and restrictions may apply. Benefits, formulary, pharmacy network, provider network, premium and/or co-payments/co-insurance may change on January 1 of each year. Premiums, co-payments, co-insurance and deductibles may vary based on the level of Extra Help you receive. Please contact the plan for further details. Enrollees have no out of pocket costs.

H2226_150326_160615 Accepted
UHCSCO_150326_160615

**ព័ត៌មានសំខាន់អន្តរជាតិ និងទាន់សភាពការណ៍**
**រៀបរៀងដោយៈបុគ្គលិកស្ម័គ្រចិត្ត K.O. ដក់ស្រង់ចេញពីកាសែតញូយ៉ក ខ្មែរ** (New York Time)

# វិបត្តិសេដ្ឋកិច្ចរបស់ប្រទេសក្រិច!

**(តពីអត្ថបទមុន)**

សេដ្ឋកិច្ចក្រិចបានជិតបាត់បង់សាច់ប្រាក់របស់ខ្លួនហើយអ្នកជំនាញភាគច្រើន និយាយថា ប្រទេសក្រិចអាចត្រូវបានបង្ខំចិត្តបោះពុម្ពរូបិយប័ណ្ណរបស់ខ្លួនបន្ថែម។

អ្នកជំនាញភាគច្រើនដ៏ដែលនេះ ធ្វើការប្រមើលថា ប្រទេសក្រិតប្រហែល និងត្រូវណែនាំដល់សាធារណៈ និងប្រជាពលរដ្ឋរបស់ខ្លួនដើម្បីឱ្យទទួលស្គាល់ឡើងវិញ នៅរូបិយប័ណ្ណចាស់របស់ក្រិចឈ្មោះថាៈ ដ្រាឆ្មើ (Dramchma) ។ រូបិយប័ណ្ណនេះ ត្រូវបានប្រទេសក្រិចប្រើប្រាស់ក្នុងប្រព័ន្ធសេដ្ឋកិច្ចរបស់ខ្លួនមុខពេលដែលពួកគេផ្លាស់ប្តូរ ដ្រាឆ្មើ (Dramchma) នេះទៅប្រើរូបិយប័ណ្ណនៃសហគមន៍អឺរ៉ុបឈ្មោះថាៈ យ៉ូរ៉ូ (Euro) វិញ។







យោងតាម ស៊ី អិន អិន ម៉ានណី (CNN Money) បានផ្តល់នូវអនុសាសន៍មួយចំនួនដែលសង្ឃឹមថា ជាអនុសាសន៍ទាំងនោះ និងជួយដល់វិបត្តិសេដ្ឋកិច្ចរបស់ប្រទេសក្រិចនាពេលបច្ចុប្បន្នឱ្យបានល្អប្រសើរ និងមាននិរន្តភាពនៃថ្ងៃនាគត់។ អនុសាសន៍ទាំងនោះមានមានដូចតទៅៈ

• ផ្តល់តំលៃខ្ពស់ទៅដល់រូបិយប័ណ្ណចាស់របស់ក្រិតនេះ គឺដ្រាឆ្មើ (Dramchma) ក្រៅពីការផ្តល់តំលៃខ្ពស់ដល់ដ្រាឆ្មើ (Dramchma) រដ្ឋភិបាលក្រិចត្រូវជំរុញឱ្យប្រជាពលរដ្ឋក្រិចចាយឬប្រើប្រាស់ ដ្រាឆ្មើ (Dramchma) ប្រចាំថ្ងៃជាក៏រិត ឧទាហរណ៍ ដូចជារដ្ឋភិបាលក្រិចគឺតំរូវឱ្យប្រជា-ពលរដ្ឋក្រិចទាំងអស់បង់ពន្ធដាជារូបិយប័ណ្ណចាស់របស់ក្រិចនេះ (Dramchma)។ ប្រជាពលរដ្ឋក្រិចត្រូវតែមានទំនុងចិត្តលើរដ្ឋភិបាលរបស់ខ្លួនដែលពួកគេមានតួនាទី និងការទទួលខុសត្រូវក្នុងការធ្វើឱ្យមានតុល្យភាពនៃថវិតាជាតិ។ ទន្ទឹមនឹងនេះដែរ រដ្ឋភិបាលក្រិចត្រូវតែមានការទទួលខុសត្រូវបំផុត ចំពោះការរក្សាឱ្យមាននិរន្តភាពនៃប្រព័ន្ធសេដ្ឋកិច្ចរបស់ប្រទេសក្រិច។ ហើយទង្វើនេះឡើងដោយមានការបង្កើតនូវគោលការណ៍សុវត្ថិភាពផ្សេងៗ ដើម្បីជំរុញអោយប្រជាពលរដ្ឋប្រើប្រាស់នូវរូបិយប័ណ្ណចាស់របស់ក្រិតនេះដ្រាឆ្មើ (Dramchma) ដូចជាៈ យកលុយទៅដាក់នៅធនាគាជាដ្រាឆ្មើ (Dramchma) មិនយក យ៉ូរ៉ូ (Euro) ទៅដាក់ក្នុងធនាគានោះទេ ឬក៏បើកកុងថ្មី (New Account) ជាប្រាក់យ៉ូរ៉ូ (Euro) នោះឡើយ។

• ចាប់ផ្តើមបោះពុម្ពលិខិតបញ្ជាក់ជំពាក់លុយ (IOUs) Will Be Continued) នឹងបន្តនៅអត្ថបទក្រោយទៀង...៕







19TH ANNUAL LOWELL
SOUTHEAST ASIAN
WATER FESTIVAL
BOAT RACES
LIVE ENTERTAINMENT
AUTHENTIC FOOD
MERCHANDISES
INFORMATION BOOTHS
CULTURAL PERFORMANCES
PAPAYA SALAD TASTING CONTEST
&
MANY MORE
VISIT US AT:
LOWELLWATERFESTIVAL.ORG
GREAT EATS!
AUGUST 15, 2015
CONTACT INFO:
LOWELLSEAWATERFESTIVAL@GMAIL.COM
SAVE THE DATE
FLYER DESIGN BY: RICKY MAO -ricmao26@gmail.com

# ការិយាល័យ មេធាវី ថូម៉ាស ស្តាលីយ៉ាណូស

**Law Office of Thomas Stylianos Jr.**

**287 Appleton St. Lowell MA 01852**

- Immigration • អន្តោប្រវេសន៍
- Auto Crash • គ្រោះថ្នាក់រថយន្ត
- Divorce • លែងលះប្តីប្រពន្ធ

សូមទាក់ទង សោភា ឬ ធំ **978-459-5000 or 800-308-3766**

# យើងខ្ញុំយកចិត្តទុកដាក់ដើម្បីឲ្យលោកអ្នកញញឹម។

## *លោកអ្នកទទួលបានសេវាកម្មទន្តពេទ្យដោយមិនបង់ប្រាក់!*





លោកអ្នកទទួលបានអត្ថប្រយោជន៍ទាំងអស់របស់លោកអ្នកនៅក្នុងកម្មវិធីស្តង់ដារ **MassHealth** និងកម្មវិធី **Medicare** រួមទាំងសេវាកម្មជាច្រើនទៀត។

- លោកអ្នកទទួលបានសេវាកម្មទន្តពេទ្យ ដោយមិនបង់ប្រាក់ ដែលរួមមាន៖ *
  - ពិគ្រោះយោបល់នៅការិយាល័យ និងសម្អាតធ្មេញ
  - ដាក់ក្រាសធ្មេញទាំងមូលនិងដោយផ្នែក
  - ប៉ះធ្មេញ
  - ដាំធ្មេញ
- ចំណាយបដិភាគ $0 សម្រាប់គ្រប់សេវាកម្ម
- ប័ណ្ណ លោកអ្នកមានសុខភាពល្អ សម្រាប់ទិញទំនិញពាក់ព័ន្ធនឹងសុខភាពដែលមិនមានវេជ្ជបញ្ជា (រហូតដល់ $140ក្នុងមួយឆ្នាំ / $35 ក្នុងមួយត្រីមាស) *
- សេវាកម្មដឹកសមាជិកទៅកាន់និងមកពីកន្លែងណាត់ជួប *
- អាចហៅទូរស័ព្ទទៅកាន់សមាជិកក្រុមការងារនៃគម្រោង SWH បាន 24/7

SWH SENIOR WHOLE HEALTH®

Simple. Secure. Independent.

សម្រាប់ព័ត៌មានបន្ថែម សូមទូរស័ព្ទទៅ:

**1-888-566-3526**(ខ្សែទូរស័ព្ទឥតគិតថ្លៃ) **TTY/TDD:711**

**www.seniorwholehealth.com/SNP**

យើងខ្ញុំបើកដំណើរការចាប់ពីម៉ោង 8 ព្រឹកដល់ម៉ោង 8 យប់ ប្រាំពីរ (7) ថ្ងៃក្នុងមួយសប្តាហ៍។

ប្រសិនបើលោកអ្នកមានសេវាកម្មធានារ៉ាប់រងក្នុងកម្មវិធីស្តង់ដារ MassHealth ក៏ប៉ុន្តែមិនមានសេវាកម្មធានារ៉ាប់រងក្នុងកម្មវិធី Medicare ផ្នែក A និង/ឬក៏ផ្នែក B លោកអ្នកប្រហែលជា អាចចុះឈ្មោះនៅក្នុងកម្មវិធីជម្រើសថែទាំសុខភាពមនុស្សចាស់ MassHealth Senior Care Options (SCO) របស់យើងខ្ញុំបាន។
លោកអ្នកដែលឆ្លើយតបទៅនឹងលក្ខខណ្ឌខាងលើអាចចុះឈ្មោះបានគ្រប់ពេលវេលារៀងរាល់ឆ្នាំ។

** លក្ខខណ្ឌកំណត់អាចត្រូវបានអនុវត្ត*

គម្រោងសុខភាពទាំងមូលរបស់មនុស្សចាស់ គឺជាគម្រោងថែទាំសុខភាព HMO SNP ដែលមានការសម្របសម្រួល និងកិច្ចសន្យាផ្តល់- ទទួលសេវាកម្មនៃកម្មវិធី Medicare និងកិច្ចសន្យាជាមួយ Commonwealth of Massachusetts/កម្មវិធី EOHHS MassHealth។ ការចុះឈ្មោះធ្វើឡើងដោយស្ម័គ្រចិត្ត និងអាស្រ័យទៅលើការបន្តកិច្ចសន្យាប្រចាំឆ្នាំ។ ព័ត៌មានអំពីអត្ថប្រយោជន៍នៅក្នុងឯកសារនេះ គឺជាសេចក្តីសង្ខេបមួយ មិនមែនជាសេចក្តីពិពណ៌នាលម្អិតអំពីអត្ថប្រយោជន៍ទេ។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងការិយាល័យគម្រោង។ លក្ខខណ្ឌកំណត់ ប្រាក់បដិភាគ ឬក៏លក្ខខណ្ឌកម្រិតផ្សេងៗទៀតអាចត្រូវបានអនុវត្ត។អត្ថប្រយោជន៍ របមន្ត បណ្តាញអ្នកផ្តល់សេវាកម្ម និងបណ្តាញឱសថស្ថាន អាចត្រូវបានផ្លាស់ប្តូរនៅថ្ងៃទី 1 ខែមករា នៃឆ្នាំនីមួយៗ។ លោកអ្នកត្រូវតែបន្តបង់បុព្វលាភផ្នែក B របស់លោកអ្នក ប្រសិនបើបុព្វលាភនោះមិនកំពុងត្រូវបានបង់ដោយភាគីណាមួយផ្សេងទៀតនៅឡើយទេ។ គម្រោងនេះត្រូវបានបង្កើតឡើងសម្រាប់មនុស្សដែលមានអាយុចាប់ពី 65 ឆ្នាំឡើងទៅ ដែលមានជំនួយវេជ្ជសាស្ត្រដែលទទួលបានទាំងពីរដ្ឋ និងកម្មវិធី Medicare។ H2224_2015_104kh Accepted 12/7/2014

ឌឹ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសំរួលពីកាសារអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី

# ឧកញ៉ា សុខ ប៊ុន ត្រូវបានចាប់ខ្លួនបញ្ជូនទៅពន្ធនាគារព្រៃស បន្ទាប់ពីតុលាការចោទប្រកាន់

**ដោយ អ៊ូច សូនី** | **July 20, 2015**

លោក សុខ ប៊ុន ដែលជាឧកញ្ញាក្នុងវិស័យអចលនទ្រព្យត្រូវបានឃុំខ្លួនតាមការចោទប្រកាន់ពីបទប្រើអំពើហិង្សាដោយចេតនាកាលពីថ្ងៃសៅរ៍ ជុំវិញការប្រើអំពើហិង្សាយ៉ាងសាហាវទៅលើពិធីការិនីម្នាក់កាលពីដើមខែនេះដោយរូបភាពវីដេអូនៃការប្រើអំពើហិង្សានោះត្រូវគេចែករំលែកព្រោងព្រាតតាមប្រព័ន្ធផ្សព្វផ្សាយសង្គម ប៉ុន្មានថ្ងៃបន្ទាប់ពីកើតហេតុ។

ចៅក្រមស៊ើបសួរ លាង សំណាត បានមានប្រសាសន៍ថា លោក សុខ ប៊ុន ដែលត្រូវបានចាប់ខ្លួនពេលមកដល់អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ តាមជើងហោះហើរពីប្រទេសសិង្ហបុរីកាលពីព្រឹកថ្ងៃសៅរ៍ ត្រូវបានចោទប្រកាន់នៅវេលាម៉ោងប្រហែល១រសៀល។ ចៅក្រមរូបនេះបានលើកឡើងបន្ថែមទៀតថា "ខ្ញុំបានចោទប្រកាន់គាត់ពីបទប្រើអំពើហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស"។

ប្រសិនបើត្រូវតុលាការកាត់ឱ្យជាប់ទោសនោះ លោក សុខ ប៊ុន អាចប្រឈមការជាប់ពន្ធនាគាររហូតដល់ទៅប្រាំឆ្នាំ និងពិន័យជាប្រាក់ចំនួន១០លានរៀល។

លោក ខៀវ សុភ័គ អ្នកនាំពាក្យក្រសួងមហាផ្ទៃបានមានប្រសាសន៍ថា បន្ទាប់ពីតុលាការចោទប្រកាន់រួចលោក សុខ ប៊ុន ត្រូវបានបញ្ជូនទៅឃុំខ្លួននៅពន្ធគារព្រៃសដើម្បីរង់ចាំសវនាការជំនុំជម្រះទោស។

កាលពីថ្ងៃទី៧ ខែកក្កដា រូបភាពវីដេអូកាមេរ៉ាសុវត្ថិភាពបានបែកធ្លាយដែលបង្ហាញពីសកម្មភាពលោក សុខ ប៊ុន ដាល់ទាត់ធាក់ និងជាន់យ៉ាងរន្ធើនទៅលើសិល្បការិនី ឯក សុជាតា ហៅ សាសា នៅភោជនីយដ្ឋានមួយកន្លែងលើកោះពេជ្រក្នុងរាជធានីភ្នំពេញកាលពីថ្ងៃទី២ ខែកក្កដា ។

កញ្ញា ឯក សុជាតា បានអះអាងថា ការប្រើអំពើហិង្សានេះបានកើតឡើង បន្ទាប់ពីនាងព្យាយាមរារាំងលោក សុខ ប៊ុន និងអង្គរក្សរបស់គាត់មិនឱ្យនាំខ្លួនស្ត្រីម្ចាស់ភោជនីយដ្ឋានជនជាតិជប៉ុនដែលដេកសន្លប់នៅលើសាឡុងបន្ទាប់ពីផឹកស៊ីជាមួយបុរសទាំងពីរចេញទៅក្រៅ។

យោងតាមក្រសួងមហាផ្ទៃបានឱ្យដឹងថា លោក សុខ ប៊ុន បានគេចខ្លួនទៅប្រទេសសិង្ហបុរីកាលពីថ្ងៃទី៧ ខែកក្កដា មួយថ្ងៃមុនសាលាដំបូងរាជធានីភ្នំពេញកោះហៅគាត់មកសាកសួរ។ បន្ទាប់មកលោក សុខ ប៊ុន បានជិះយន្តហោះពីប្រទេសសិង្ហបុរីឆ្ពោះទៅទីក្រុងប៉ារីស នេះបើយោងតាមការិយាល័យនគរបាលអាំងទែប៉ូល



របស់កម្ពុជា។

ក្នុងសុន្ទរកថា មួយកាលពីថ្ងៃព្រហស្បតិ៍ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានប្រកាសឱ្យលោក សុខ ប៊ុន ដែលកាលពីសប្តាហ៍មុនបានបោះបង់ងារជា "ឧកញ៉ា" របស់ខ្លួន និងសុំផ្តល់សំណងជំងឺចិត្តដល់កញ្ញា ឯក សុជាតា ចំនួន១០០.០០០ដុល្លារ ចូលខ្លួនដើម្បីដោះស្រាយ។

លោកនាយករដ្ឋមន្ត្រីបានមានប្រសាសន៍នៅពេលនោះថា "បើយើងមើលតាមឃ្លីបវីដេអូអំពើហិង្សាបែបនេះគឺវាហួសហេតុពេកហើយជាមួយស្ត្រីដែលមានភាពទន់ខ្សោយម្នាក់។ កុំគិតថាដោយសារអ្នកឯងមានលុយអាចដោះស្រាយបញ្ហាបាននោះ"។

លោក ខៀវ សុភ័គ បានលើកឡើងកាលពីម្សិលមិញថា លោក សុខ ប៊ុន មិនមែនត្រូវបានចាប់ខ្លួននៅក្នុងទីក្រុងប៉ារីសទេ គឺគាត់បានវិល

**តទៅទំព័រទី ១៦**

# Tycoon Jailed For Assault After Arrest at Airport

**BY OUCH SONY | JULY 20, 2015**

Real-estate tycoon Sok Bun was imprisoned on charges of intentional violence on Saturday over the savage assault of a female television personality earlier this month, footage of which went viral on social media days after the attack.

Mr. Bun, who was arrested upon arriving at Phnom Penh International Airport on a flight from Singapore on Saturday morning, was charged at about 1 p.m., said Investigating Judge Leang Samnath.

"I charged him with intentional violence with aggravating circumstances," he said.

If convicted, Mr. Bun faces up to five years in prison and a fine of 10 million riel, or about $2,500.

Interior Ministry spokesman Khieu Sopheak said that after the court charged Mr. Bun, he was sent to Prey Sar prison to await trial.

On July 7, security camera footage emerged showing Mr. Bun punching, kicking and stomping on EkSocheata, an entertainer better known as Sasa, at a restaurant on Phnom Penh's Koh Pichisland on July 2.

Ms. Socheata has said that the assault took place after she attempted to stop Mr. Bun and his bodyguard from leaving with the female Japanese owner of the restaurant, who had fallen asleep on a couch after drinking with the two men.

According to the Interior Ministry, Mr. Bun fled to Singapore on July 7, the day before the Phnom Penh Municipal Court summoned him for questioning. Mr. Bun then flew from Singapore to Paris on Tuesday, according to Cambodia's Interpol office.

In a speech on Thursday, Prime Minister Hun Sen appealed to Mr. Bun-who last week relinquished his royally bestowed title of "oknha" and offered Ms. Socheata $100,000 in compensation-to turn himself in.

"Looking at the video footage: It's unthinkable violence committed against a weak woman," the prime minister said at the time. "Don't think that because you have money you can fix this."

General Sopheak said Sunday that Mr. Bun was not arrested in Paris, and returned to Cambodia voluntarily after his family told him about Mr. Hun Sen's speech.

"After the prime minister appealed for him to report, his family told him to come back," he said. "After getting information from his family, we went to pick him up at the airport and sent him straight to the court on Saturday morning."

Gen. Sopheak said that Mr. Bun's bodyguard-whom he refused to identify and who can be seen in the security camera footage brandishing a pistol and briefly pointing it at Ms. Socheata's head-was still at large.

"Now we are waiting for the arrest warrant from the court, and I believe he will not get far," he said, adding that he did not know whether the man was still in the country.

Contacted Sunday, Ms. Socheata reiterated that she would not settle out of court with Mr. Bun, regardless of how much money he offered.

"I still demand legal action against him, and I will not make any compromises outside of court," she said. "I have stepped forward already, so I will not turn back."

(Additional reporting by Chris Mueller)

TRITON STAFFING GROUP

# ទ្រីថុនស្តាហ្វីងគ្រួប

## គឺជាក្រុមហ៊ុនសេវាគ្រប់យ៉ាងស្ថិតនៅ

330 Boston Rd. Billerica, MA 01862Phone: (978)663 2013 fax (978)663 2513

យើងមានការងារបើកថ្មីនៅតំបន់ឡូវែល បីលរិកា នឹងនៅខាងត្បូង តំបន់ញូហាមស្សៀ

Triton Staffing Group is a full service staffing agency located at 330 Boston Road, Billerica, MA 01862, Phone: 978-663-2013, Fax:978-663-2513

We currently have job openings in the Great Lowell, Billerica and Southern New Hampshire areas.

| Positions Available Include : | | ការងារដែលមាន : | |
|---|---|---|---|
| -Machine Operators | បញ្ជាគ្រឿងម៉ាស៊ីន | -Assemblers | រៀបគ្រឿងផ្គុំ |
| -Warehouse | ការងារក្នុងឃ្លាំងអីវ៉ាន់ | -General Labor | ការងារទូទៅ |
| -Administrative | រដ្ឋបាល | -Shipping, Receivers | ផ្ញើរអីវ៉ាន់, ទទួលអីវ៉ាន់ |
| -Technicians | បច្ចេកទេសជាង | -CNC Operators | អ្នកបញ្ជា សីអិនសី |
| -Data Entry | បញ្ចូលព័ត៌មាន | -Cable Harness | តម្លើងខ្សែរអាស្សាណ |
| -Welders | ជាងផ្សារដែក | | |

សូមអញ្ជើញមកចុះឈ្មោះ យកប្រវត្តិរូបមកផង ឬក៏ឱ្យបុគ្គលិកយើងជួយមើល ធ្វើឱ្យមួយ។

Come in and apply, please bring a resume or have one of our recruiters assist you with one.

**TRITON STAFFING GROUP**
**978-663-2013**



# វិជ្ជាស្ថានរៀន ថែសម្ផស្សមុខនិងត្រចក

## Chelmsford Beauty Academy

**60 Chelmsford St.,2nd Floor Chelmsford, MA. 01824**
**Tel: (978)328-9722 ឬ (978) 250-4488**



- យើងខ្ញុំបានបើកវគ្គបង្រៀនធ្វើត្រចក និងថែសម្ផស្សមុខ គ្រូបង្ហាត់ មានការដកពិសោធន៍ច្រើនឆ្នាំ មានថ្នាក់រៀនក្រៅម៉ោង និងពេញម៉ោងរៀន៧ថ្ងៃក្នុង១សប្តាហ៍
- យើងខ្ញុំបើកវគ្គសិក្សា៣០០ម៉ោង (ក្នុងវេលា២ខែកន្លះ) សម្រាប់ថ្នាក់ថែសម្ផស្សមុខ និងវគ្គ១០០ម៉ោង (ក្នុងវេលា៣អាទិត្យ)
- សម្រាប់ថ្នាក់ធ្វើត្រចក។
- សូមចុះឈ្មោះជាប្រញាប់ !

**ជួយណែនាំរកការងារធ្វើ ពេលចប់ការសិក្សា**

Chelmsford Beauty Academy មានចម្ងាយ៥នាទីពីក្រុង Lowell, និង១៥នាទីពីក្រុង Lawrence, ចម្ងាយ១០នាទីពី Burlington Mall, និង១០នាទី Andover.



**ព័ត៌បន្ថែមទាក់ទងជាមួយយើងខ្ញុំថ្ងៃនេះទូរស័ព្ទលេខ : (978)328-9722** ឬលេខ : **(978)250-4488**

ឌឹ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសំរួលពីភាសាអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី

# លោកនាយករដ្ឋមន្ត្រីៈ បង្គោលព្រំដែនមួយចំនួនអាចបោះមិនត្រឹមត្រូវនៅក្នុងទឹកដីកម្ពុជា

**ដោយ ឃួន ណារិមនិងអេឡិក វិល្លឹមមីនស៍**

**| July 17, 2015**

កាលពីម្សិលមិញលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានទទួលស្គាល់ថា បង្គោលព្រំដែនមួយចំនួនដែលកំណត់ព្រំដែនជាមួយវៀតណាមអាចត្រូវបានបោះមិនត្រឹមត្រូវនៅក្នុងទឹកដីកម្ពុជា ប៉ុន្តែលោកបានលើកឡើងថា រដ្ឋាភិបាលអាចពិនិត្យឡើងវិញ ហើយ "ទាមទារឱ្យមានការកែតម្រូវ"។

ចាប់តាំងពីខែមុនសមាជិកសភាគណបក្សសង្គ្រោះជាតិបានដឹកនាំយុទ្ធនាការមួយរកឱ្យឃើញពីការទន្ទ្រានចូលរបស់វៀតណាមក្នុងទឹកដីកម្ពុជា ទន្ទឹមនឹងនោះក៏បានចោទប្រកាន់រដ្ឋាភិបាលគណបក្សប្រជាជនកម្ពុជាថា បានឃុបឃិតក្នុងការបោះបង្គោលព្រំដែននៅក្នុងទឹកដីកម្ពុជាផងដែរ។

លោក ហ៊ុន សែន បានច្រានចោលការអះអាងបែបនេះជាយូរមកហើយ ហើយដែលគួរឱ្យកត់សម្គាល់បំផុតនោះ នៅក្នុងការថ្លែងសុន្ទរកថាដ៏វែងរយៈពេល៥ម៉ោងនៅក្នុងរដ្ឋសភាកាលពីឆ្នាំ២០១២ ប៉ុន្តែលោកបានលើកឡើងកាលពីម្សិលមិញថា បង្គោលព្រំដែននៅតាមព្រំដែនវៀតណាមប្រវែង១.២២៨គីឡូម៉ែត្រប្រហែលជាត្រូវពិនិត្យឡើងវិញ។

លោក ហ៊ុន សែន បានមានប្រសាសន៍អំឡុងពិធីចែកសញ្ញាបត្រមួយក្នុងរាជធានីភ្នំពេញថា "ឥឡូវបាន៨៣ភាគរយហើយ នៅសល់១៧ភាគរយ ហើយ៨៣ភាគរយនេះ ក៏យើងនៅអាចសើរើបានទៀតត្រូវធ្វើអូឌីតមួយចំនួនទៀត ករណីដែលបោះទៅវាមានលម្អៀងអីចឹងត្រូវកែទាមទារឱ្យមានការកែតម្រូវ"។

ទោះជាយ៉ាងណាលោកនាយករដ្ឋមន្ត្រីបានច្រានចោលការអះអាងរបស់គណបក្សប្រឆាំងដែលថា រដ្ឋាភិបាលរបស់លោកបានបង្កើតឡើងក្រោមការកាន់កាប់ប្រទេសកម្ពុជាពីសំណាក់វៀតណាមក្នុងទសវត្សរ៍ឆ្នាំ១៩៨០។

លោក ហ៊ុន សែន បានមានប្រសាសន៍ថា "ខ្ញុំបានប្រាប់អ្នកចរចាថាៈ បើចរចាមិនត្រូវគ្នាអូសបន្លាយក៏អូសទៅប្រសើរជាងបាត់ដី"។

លោកបានបន្ថែមថា "ដាក់ជាសំណួរមួយថា ជិត៣០ឆ្នាំតាំងពីកងទ័ពវៀតណាមនៅស្រុកខ្មែរ ម៉េចក៏មិនបោះឱ្យហើយតែម្តងទៅដោយសារខ្មែរមិនព្រមនិយាយឱ្យពិត"។

លោក ហ៊ុន សែន ក៏ទំនងជាបានព្រមានដល់ប្រទេសវៀតណាមផងដែរកុំឱ្យគឃ្លើនពេកនៅក្នុងការចរចាជុំវិញការបោះបង្គោលព្រំដែន ឬក្នុងការស្វែងរកទំនុកចិត្តចាំបាច់នៅពេលមានភាពតានតឹងក្នុងពេលបច្ចុប្បន្នរវាងរដ្ឋាភិបាល និងគណបក្សប្រឆាំងក្នុងប្រទេសកម្ពុជា។

លោកបានមានប្រសាសន៍ថា "ខ្ញុំបានផ្ញើសារទៅដៃគូរបស់យើងប្រទេសជិតខាងថា កម្ពុជាមិនបោះបង់សិទ្ធិក្នុងការទាមទារទៅលើចំណុចមួយចំនួនទៀតឡើយ បើទោះជាកម្ពុជាមិនទាន់បានត្រូវគ្នាទៅលើចំណុចមួយចំនួនផ្ទៃក្នុងក៏ដោយ"។

លោក សម រង្ស៊ី មេដឹកនាំគណបក្សប្រឆាំងបានមានប្រសាសន៍តាមទូរស័ព្ទថា សុន្ទរកថា របស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បន្ទាប់ពីការបដិសេធជាច្រើនឆ្នាំដែលថា គ្មានបង្គោលព្រំដែនណាមួយត្រូវបានបោះខុស ហើយបណ្តាលឱ្យបាត់បង់ទឹកដីប្រទេសកម្ពុជាទៅប្រទេសវៀតណាមនោះ គឺជាការបង្ហាញឱ្យឃើញថា ត្រូវនៃគោលនយោបាយរបស់គណបក្សប្រឆាំងដែលមានជាយូរមកហើយ។

លោក សម រង្ស៊ី បានមានប្រសាសន៍ថា "ខ្ញុំសូមស្វាគមន៍ការទទួលស្គាល់នេះតាងនាមលោកនាយករដ្ឋមន្ត្រីដែលយ៉ាងហោចណាស់បង្គោលព្រំដែនមួយចំនួនក្នុងចំណោមបង្គោលព្រំដែនជាច្រើនត្រូវបានបោះមិនត្រឹមត្រូវក្នុងទឹកដីកម្ពុជា ហើយនេះបង្ហាញឱ្យឃើញថា ត្រូវពីអ្វីដែលខ្ញុំបានព្យាយាមលើកឡើងជាច្រើនឆ្នាំមកហើយ"។

លោកបានមានប្រសាសន៍បន្ថែមថា "ប្រជាពលរដ្ឋជាច្រើននឹងចាំថា ដំបូងនៅពេលខ្ញុំបាននិយាយថា បង្គោលព្រំដែនទាំងនេះត្រូវបានបោះមិនត្រឹមត្រូវនោះ ខ្ញុំត្រូវផ្តន្ទាទោសឱ្យជាប់ពន្ធនាគារសរុប១២ឆ្នាំ ដែល១០ឆ្នាំពីបទបំផ្លាញទ្រព្យសម្បត្តិសាធារណៈ និង២ឆ្នាំទៀតពីបទផ្សព្វផ្សាយព័ត៌មានមិនពិត"។

លោក សម រង្ស៊ី បានថ្លែងថា ការកើនឡើងនូវបណ្តាញផ្សព្វផ្សាយសង្គមនៅប្រទេសកម្ពុជាបានបំបែកទីតាំងរឹងមាំរបស់គណបក្សប្រជាជនកម្ពុជានៅតាមប្រព័ន្ធផ្សព្វផ្សាយរបស់ប្រទេស ហើយបានបង្ខំឱ្យដោះស្រាយបញ្ហាព្រំដែនវៀតណាមក្រោមសម្ពាធពីគណបក្សសង្គ្រោះជាតិ។

លោកបានមានប្រសាសន៍បន្ថែមទៀតថា "វាជាបរិយាកាសថ្មី។ មានវិធានថ្មីសម្រាប់រឿងនេះ ហើយគណបក្សប្រជាជនកម្ពុជាមិនអាចធ្វើ

តទៅទំព័រទី ១៥

## Border Posts Could Be in Wrong Place, Hun Sen Says

**By Khuon Narim and Alex Willemyns | July 17, 2015**

Prime Minister Hun Sen acknowledged Thursday that some of the border posts demarcating the frontier with Vietnam may have been incorrectly positioned inside Cambodia, but said the government can review them and "demand corrections."

Since last month, opposition CNRP lawmakers have led a campaign to uncover Vietnamese encroachments into Cambodia while also accusing the CPP government of complicity in planting border posts well inside Cambodian territory.

Mr. Hun Sen has long fiercely rejected such claims—most notably in a marathon five-hour speech in the National Assembly in 2012—but said Thursday that posts along the 1,228-km Vietnamese border may have to be re-examined.

"Now we have done 83 percent [of the border demarcation] and there remains 17 percent. And that 83 percent, we can revise [those posts] and go audit some others. In cases of demarcation with bias, we must rectify it, must demand corrections," Mr. Hun Sen said during a speech at a graduation ceremony in Phnom Penh.

However, the prime minister rejected claims from the opposition that his government—created under the Vietnamese occupation of Cambodia in the 1980s—has been too fast to bow to Hanoi, saying that the opposite is true.

"I told the negotiators: If negotiations do not reach an agreement, and they need to be dragged out, then drag them out—it's better than losing land," Mr. Hun Sen said.

"Pose the question: It has been nearly 30 years since the Vietnamese army was in Cambodia. Why has the demarcation not finished?" the prime minister asked, pausing. "It's because the Khmer have not agreed. This is the true story."

Mr. Hun Sen also appeared to warn Vietnam against being too aggressive in negotiations over border demarcations, or in finding undue confidence in current tensions between Cambodia's government and the opposition.

"I send a message to our partners, the neighboring countries, that Cambodia does not give up the right to make demands on some other points, even if Cambodia has not yet united on some points internally," Mr. Hun Sen said.

Opposition leader Sam Rainsy said by telephone that Mr. Hun Sen's speech—after years of denials that any markers had been placed wrongly and caused the loss of Cambodian land to Vietnam—was a vindication of long-held opposition policies.

"I welcome this recognition on behalf of the prime minister that at least some of the border markers have been planted wrongly inside Cambodia's territory, and this vindicates what I have been trying to expose for many years," Mr. Rainsy said.

"Many people will remember that when I first said these border markers were inappropriately planted, I was sentenced to a total of 12 years in prison—10 years for destroying public property, and two years for spreading false information," he added.

Mr. Rainsy said the growth of social media in Cambodia had broken the CPP's stranglehold on the country's media and forced it to deal with the Vietnamese border issue under pressure from the CNRP.

"It's a new environment. There are new rules for the game and the CPP cannot work the same as it did before, because technology is available to everybody," he said.

Also Thursday, the government sent a team led by Foreign Affairs Ministry Secretary of State Long Visalo to an area in SvayRieng province's Kompong Ro district to inspect a disputed area alongside foreign ministry counterparts from Vietnam.

"We did not finish yet," said district police chiefSathSamuth last night. "They did not accept that the disputed land belongs to us and it might continue tomorrow."

On Sunday, opposition lawmaker Real Camerin plans to lead his second trip to border markers 202 and 203 on the border in Kompong Ro district to highlight alleged encroachments by Vietnam.

But Buntenh, head of the Independent Monk Network for Social Justice, said Thursday he would be sending 50 monks from his group alongside Mr. Camerin.

The prominent monk said that he was pleased to see Mr. Hun Sen taking a stronger stance on territorial encroachments, but that the prime minister should also adjust the labels he has been using recently for his political rivals.

"Hun Sen and his officials have confessed now that they have not done a really good job, but it is good that he says he will not give up—even if there are some controversies—and now plans to make things right," But Buntenh said.

"The fruit is ripe now. Hun Sen knows it is ripe and so he has to eat it," the monk added. "In the meantime, he should stop condemning the opposition as extreme nationalists. If it was not for the opposition, he might not have this very good opportunity."

**(Additional reporting by MechDara)**

ឌឹ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសំរួលពីកាសារអង់គ្លេស    អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី

# រដ្ឋាភិបាលបញ្ចេញសេចក្តីព្រាងច្បាប់ស្តីពីសុវត្ថិភាពចំណីអាហារ

**ដោយ អូន ឆេងប៉ រ និង ជេនណែល រ៉េតខា** | JULY 16, 2015

កាលពីម្សិលមិញក្រសួងពាណិជ្ជកម្មបានបញ្ចេញសេចក្តីព្រាងច្បាប់ស្តីពីសុវត្ថិភាពចំណីអាហារដំបូងរបស់កម្ពុជាដែលនឹងបង្កើតឱ្យមានអាជ្ញាធរសុវត្ថិភាពចំណីអាហារ ទទួលបន្ទុកកិច្ចការពារសុវត្ថិភាពរបស់អ្នកទទួលទានក្នុងស្រុក និងការធានាថា ការនាំចេញស្របតាមបទដ្ឋានអន្តរជាតិ។

ច្បាប់ដែលគេរំពឹងថា នឹងព្រាងចប់រួចរាល់ ហើយបញ្ជូនទៅទីស្តីការគណៈរដ្ឋមន្ត្រីត្រឹមដំណាច់ខែនេះ ចែងអំពីបទល្មើសផ្តន្ទាទោសជាច្រើន ក្នុងនោះរួមមានទាំងការលក់ចំណីអាហារដែលផ្ទុកសារធាតុគ្រោះថ្នាក់ការបិទស្លាកសញ្ញាមិនបានត្រឹមត្រូវលើចំណីអាហារការត្រៀម ឬការលក់ចំណីអាហារក្នុងស្ថានភាពគ្មានអនាម័យ និងការដំណើរការអាជីវកម្មចំណីអាហារដោយគ្មានអាជ្ញាប័ណ្ណផងដែរ។

បន្ទាប់ពីសិក្ខាសាលាមួយស្តីពីច្បាប់នេះដែលបានរៀបចំឡើងនៅសណ្ឋាគារអាំងទែកុងទីណង់តាល់ ក្នុងរាជធានីភ្នំពេញ លោកស្រី នីណា ប្រ៊ែនស្ត្រាប់ (Nina Brandstrup) តំណាងប្រចាំប្រទេសកម្ពុជានៃអង្គការស្បៀងអាហារ និងកសិកម្ម (FAO) របស់អង្គការសហប្រជាជាតិបានមានប្រសាសន៍កាលពីម្សិលមិញ"ច្បាប់នេះគឺចាំបាច់ណាស់ ពីព្រោះតែមិនទាន់មានវានៅឡើយ។ កម្ពុជាមានមហិច្ឆតាចង់ក្លាយជាប្រទេសនាំចេញចំណីអាហារដ៏ធំ ហើយដើម្បីអាចធ្វើបែបនេះទៅបានពួកគេចាំបាច់ត្រូវគោរពច្បាប់ចំណីអាហាររបស់ប្រទេសផ្សេងៗ ហើយពួកគេអាចធ្វើបានលុះត្រាតែពួកគេមានច្បាប់ចំណីអាហារដែលអនុវត្តបានល្អនៅក្នុងប្រទេសកម្ពុជា"។

លោក ស៊ុន ចាន់ថុល រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មដែលនឹងទទួលបន្ទុកតែងតាំងប្រធានអាជ្ញាធរសុវត្ថិភាពចំណីអាហារ ដែលត្រូវមានសមាសភាពតំណាងមកពីក្រសួងផ្សេងៗ បានមានប្រសាសន៍ថា ច្បាប់នេះមានសារៈសំខាន់ណាស់ចំពោះការធ្វើឱ្យអ្នកទទួលទានមានទំនុកចិត្តលើចំណីអាហារដែលមានដាក់លក់នៅក្នុងប្រទេសកម្ពុជា។

លោកបានមានប្រសាសន៍ទៀតថា "អ្វីដែលសំខាន់បំផុតគឺសុវត្ថិភាពរបស់ប្រជាជនយើង និងសុវត្ថិភាពសម្រាប់យើងទាំងអស់គ្នា។ យើងជាអ្នកទទួលទានចំណីអាហារ ដូច្នេះវាមានសារៈសំខាន់ណាស់ដែលយើងមានអារម្មណ៍ស្រួលក្នុងចិត្ត នៅពេលយើងទទួលទានអាហារ ហើយយើងប្រាកដក្នុងចិត្តថា អាហារនោះល្អ និងមានជាតិគីមីតិចដែលអាចបំផ្លាញសុខភាពរបស់យើង"។

លោកបានលើកឡើងបន្ថែមទៀតថា ច្បាប់នេះនឹងពង្រឹងការអនុវត្តបទប្បញ្ញត្តិដែលមានស្រាប់ស្ថិតក្រោមរង្វង់សមត្ថកិច្ចរបស់កាំកុងត្រូលដែលជាអង្គភាពអធិការកិច្ចគយរបស់ក្រសួងពាណិជ្ជកម្ម។

លោក គាម មករាឌី នាយកកម្មវិធីសុខភាពនៃអង្គការមជ្ឈមណ្ឌលសិក្សា និងអភិវឌ្ឍន៍កសិកម្មកម្ពុជា ហៅកាត់ថាសេដាកដែលជាអង្គការមិនមែនរដ្ឋាភិបាលធ្វើការងារផ្នែកកសិកម្មបានមានប្រសាសន៍ថា ការអនុវត្តរបស់កាំកុងត្រូលនៅក្នុងការធានាសុវត្ថិភាពការនាំចេញនាំចូលចំណីអាហារ គួរតែធ្វើឱ្យប្រសើរឡើងជាយូរមកហើយ។

តទៅទំព័រទី ២១

# Government Releases Draft Law on Food Safety

**BY JANELLE RETKA AND AUN CHHENGPOR | JULY 16, 2015**

FTLE

The Commerce Ministry on Wednesday released a draft of the country's first food law, which establishes a Food Safety Authority charged with protecting domestic consumers and ensuring that exports meet international standards.

The law-expected to be finalized and sent to the Council of Ministers by the end of next month-lays out a long list of punishable offenses, including selling food that contains harmful substances, mislabeling food, preparing or selling food in unsanitary conditions and operating a food business without a license.



"The law is needed because there isn't one," Nina Brandstrup, country representative for the U.N.'s Food and Agriculture Organization (FAO), said Wednesday after a workshop on the law at the InterContinental Hotel in Phnom Penh.

"Cambodia has the ambition to become a major food exporter, and in order for that to happen, they need to respect the food laws of other countries and they can only do that if they have a well-performing food law in Cambodia," she said.

Commerce Minister Sun Chanthol, who will appoint the head of the Food Safety Authority-to be composed of representatives from various ministries-said the law was crucial to giving consumers confidence in the food for sale in the country.

"It is the most important aspect of the safety of our people and safety for all of us," Mr. Chanthol said. "We are consumers of food, so it is important that we feel comfortable when we eat the food and we're sure that it's good, with less chemicals that can destroy our health."

Mr. Chanthol said the law would improve enforcement of existing regulations that fall under the purview of Camcontrol, the ministry's customs inspection unit.

Keam Makarady, health program director for Cedac, an agricultural NGO, said improvements in Camcontrol's performance in ensuring the safety of food imports and exports were long overdue.

"The work that has been done by Camcontrol is little, limited and incomplete," Mr. Makarady said. "Some unsafe products are already in the market…so consumers face health problems when eating and using those unsafe products."

Drafted by the FAO and relevant government ministries in consultation with local and international lawyers, along with representatives of the private sector, work on the law began in February 2014 and a finished draft is set to be completed within six weeks.

During a question-and-answer session at the end of Wednesday's workshop, participants asked how the law would be enforced, how its implementation would be funded, and who would be responsible for drafting specific sub-decrees to expand upon vague provisions in the law.

Emmanuelle Bourgois, a legal consultant who assisted in drafting the law, said the details could be ironed out after the law was approved, bringing Cambodia more in line with international requirements for food exports.

"There will be room for more regulations to be developed under the Food Safety Authority," she said.

Ms. Brandstrup of the FAO said the concerns raised during the session were understandable.

"Some of the questions reflect that people are concerned about implementation, and I think this is a valid concern. One thing is having the law, but you can have the best law in the world, but if it's not possible to implement it, then it's really for nothing," Ms. Brandstrup said.

**"Some adaptation will be required," she said.**

---

តមកពីទំព័រទី ១៤

## លោកនាយករដ្ឋមន្ត្រី ៖ បង្គោលព្រំដែន...

អ្វីដូចខ្លួនធ្លាប់ធ្វើពីមុនបានឡើយ ពីព្រោះបច្ចេកវិទ្យាអាចរកបានសម្រាប់មនុស្សគ្រប់គ្នា"។

កាលពីម្សិលមិញផងដែរ រដ្ឋាភិបាលបានបញ្ជូនមន្ត្រីមួយក្រុមដឹកនាំដោយលោក ឡុង វិសាលោ រដ្ឋលេខាធិការក្រសួងការបរទេសឱ្យចុះទៅកាន់តំបន់មួយក្នុងស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង ដើម្បីពិនិត្យមើលតំបន់ដែលមានវិវាទជាមួយសមភាគីក្រសួងការបរទេសមកពីវៀតណាម។

លោក សាត សាមុត អធិការនគរបាលស្រុកបានមានប្រសាសន៍កាលពីយប់មិញថា "យើងមិនទាន់បានបញ្ចប់នៅឡើយទេ។ ពួកគេមិនទាន់ទទួលយកថា ដីដែលមានវិវាទនោះជារបស់យើងឡើយ ហើយថា វាអាចបន្តនៅថ្ងៃស្អែក"។

កាលពីថ្ងៃអាទិត្យលោក រៀល ខេមរិន្ទ្រ សមាជិកសភាគណបក្សប្រឆាំងមានគម្រោងដឹកនាំដំណើរទស្សនកិច្ចរបស់លោកលើកទី២ទៅពិនិត្យបង្គោលព្រំដែនលេខ២០២ និង២០៣ នៅតាមព្រំដែនស្ថិតក្នុងស្រុកកំពង់រោទិ៍ ដើម្បីបង្ហាញពីការទន្ទ្រានយកដីពីសំណាក់វៀតណាម។

ព្រះតេជគុណ ប៊ុត ប៊ុនទិញ ជាប្រធានបណ្តាញព្រះសង្ឃឯករាជ្យ ដើម្បីយុត្តិធម៌សង្គមបានមានសង្ឃដីកាកាលពីម្សិលមិញថា ព្រះអង្គនឹងបញ្ជូនព្រះសង្ឃ៥០អង្គមកពីក្រុមរបស់ព្រះអង្គឱ្យនិមន្តទៅជាមួយលោក រៀល ខេមរិន្ទ្រ។

ព្រះសង្ឃអង្គនេះបានមានសង្ឃដីកាថា ព្រះអង្គរីករាយណាស់ដោយឃើញលោក ហ៊ុន សែន ប្រកាន់ជំហររឹងមាំស្តីពីការទន្ទ្រានយកដី ប៉ុន្តែថា លោកនាយករដ្ឋមន្ត្រីគួរកែតម្រូវអ្វីដែលលោកបានប្រើកាលពីពេលថ្មីៗទៅលើគូប្រជែងនយោបាយរបស់លោកផងដែរ។

ព្រះតេជគុណ ប៊ុត ប៊ុនទិញ បានមានសង្ឃដីកាទៀតថា ឥឡូវនេះលោក ហ៊ុន សែន និងមន្ត្រីរបស់លោកបានទទួលស្គាល់ថា ពួកគាត់ធ្វើការងារមិនទាន់ល្អនៅឡើយទេ ប៉ុន្តែវាជាការល្អដែលលោកបានលើកឡើងថា លោកនឹងមិនបោះបង់បើទោះជាមានភាពចម្រូងចម្រាស ខ្លះក៏ដោយ ហើយឥឡូវនេះមានផែនការធ្វើអ្វីៗត្រឹមត្រូវ"។

ព្រះអង្គបានមានសង្ឃដីកាបន្ថែមថា "ឥឡូវនេះផ្លែឈើទុំហើយ។ លោក ហ៊ុន សែន ដឹងថាវាទុំហើយ ដូច្នេះគាត់ត្រូវហូបវា។ ស្របពេលជាមួយគ្នានេះដែរ គាត់គួរឈប់ថ្កោលទោសគណបក្សប្រឆាំងថា ជាអ្នកជាតិនិយមជ្រុលទៀតទៅ។ ប្រសិនបើមិនមែនដោយសារគណបក្សប្រឆាំងទេ គាត់ក៏ប្រហែលជាគ្មានឱកាសល្អនេះដែរ"៕

**សារុន (រាយការណ៍បន្ថែមដោយ ម៉ិច ដារ៉ា)**

ឌឹ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសម្រួលពីភាសាអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី

# តំណាងរាស្ត្រទទួលរងទណ្ឌកម្មទាក់ទិននឹងការបង្ហោះហ្វេសប៊ុក

**ដោយគុច ណារ៉េន** | July 25, 2015

យោងតាមសេចក្តីសម្រេចចេញកាលពីថ្ងៃសុក្រ ដោយអគ្គលេខាធិការរដ្ឋសភាបានឱ្យដឹងថា លោក អ៊ុំ សំអាន តំណាងរាស្ត្រគណបក្សប្រឆាំង ត្រូវបានហាមមិនឱ្យចូលធ្វើការក្នុងរដ្ឋសភាក្នុងវេលា ១៥ពេលប្រជុំជាបន្តបន្ទាប់ ហើយនិងត្រូវកាត់ប្រាក់ខែជាការដាក់ទណ្ឌកម្ម ព្រោះតែការអធិប្បាយរិះគន់ដែលលោកបានបង្ហោះតាមទំព័រហ្វេសប៊ុកកាលពីដើមខែនេះ ។

សេចក្តីសម្រេចបាននិយាយថា លោក អ៊ុំ សំអាន ដែលការបង្ហោះរបស់លោកកាលពីថ្ងៃទី ១៥ ខែកក្កដា បានអះអាងថា លោក ហេង សំរិន ប្រធានរដ្ឋសភាគណបក្សប្រជាជនកម្ពុជាមិនបានបញ្ជូនលិខិតមួយច្បាប់ទៅលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន នោះ ក៏នឹងត្រូវរងការអាម៉ាស់តាមរយៈកំណត់ហេតុបន្ទោសដែលបិទនៅតាមការិយាល័យឃុំក្នុងមណ្ឌលខេត្តសៀមរាបរបស់លោកដែរ ។

សេចក្តីសម្រេចមានខ្លឹមសារថា "ឯកឧត្តម អ៊ុំ សំអាន តំណាងរាស្ត្រមណ្ឌលខេត្តសៀមរាប ត្រូវទទួលការបន្ទោស និងទណ្ឌកម្មខាងវិន័យ ស្របតាមការកំណត់ប្រការ៨១នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភាដូចតទៅៈ ក-កាត់ប្រាក់បំណាច់ប្រចាំខែហាសិបភាគរយក្នុងរយៈពេល២ខែ ។ ខ-ប្រកាសផ្សាយជាសាធារណៈ នូវសម្រង់កំណត់ហេតុបន្ទោសព្រមទាំងយកទៅបោះពុម្ពហើយបិទនៅគ្រប់ឃុំក្នុងមណ្ឌលខេត្តសៀមរាប ។ គ-ហាមមិនឱ្យចូលធ្វើការក្នុងរដ្ឋសភាក្នុងវេលា១៥ពេលប្រជុំជាបន្តបន្ទាប់" ។

លោក ហេង សំរិន បានបដិសេធមិនចារលើលិខិតថ្ងៃទី៦ ខែកក្កដា របស់លោក អ៊ុំ សំអាន និងតំណាងរាស្ត្រគណបក្សសង្គ្រោះជាតិ១១រូបផ្សេងទៀត ដែលអំពាវនាវសុំឱ្យរដ្ឋាភិបាលផ្អាកការកំណត់ព្រំដែនកម្ពុជាជាមួយវៀតណាមរហូតដល់ឆ្នាំ២០១៨ និងស្នើសុំឱ្យរដ្ឋាភិបាលពន្យល់អំពីការដោះដូរដីនៅតាមបណ្តោយព្រំដែនវៀតណាម ។

ឆ្លើយតបទៅនឹងការបង្ហោះហ្វេសប៊ុករបស់លោក អ៊ុំ សំអាន ដែលកើតឡើងបន្ទាប់នោះ



លោក ឈាង វុន អ្នកនាំពាក្យរដ្ឋសភាបាននិយាយកាលពីសប្តាហ៍មុនថា សេចក្តីសម្រេចនេះត្រូវបានធ្វើឡើង ត្បិតអីលិខិតនោះមានន័យស្មើនឹងការទាមទារជាជាងការលើកសំណួរ ។

ក៏ប៉ុន្តែលោក អ៊ុំ សំអាន បានទទូចបញ្ជាក់ថា សិទ្ធិតាមរដ្ឋធម្មនុញ្ញរបស់លោកក្នុងនាមជាតំណាងរាស្ត្រដាក់សំណួរទៅរដ្ឋាភិបាលត្រូវបានរំលោភបំពាន ហើយថា លិខិតនោះមិនត្រូវបានបញ្ជូនបន្តទៅលោក ហ៊ុន សែន ទេ ដោយសារតែបញ្ហាប្រធានបទរសើបខាងនយោបាយ ។

យោងតាមលោក អេង ឆៃអ៊ាង តំណាងរាស្ត្រមួយរូបក្នុងចំណោមប្រាំមួយរូបរបស់គណបក្សសង្គ្រោះជាតិក្នុងគណៈកម្មាធិការនេះបានឱ្យដឹងថា សេចក្តីសម្រេចកាលពីថ្ងៃសុក្រដាក់ទណ្ឌកម្មតំណាងរាស្ត្រគណបក្សសង្គ្រោះជាតិ បានធ្វើឡើងអំឡុងកិច្ចប្រជុំនៃគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាដែលមានសមាជិក១៣រូប ។

**តទៅទំព័រទី ២៧**

# NRP Lawmaker Punished Over Facebook Post

**BY KUCH NAREN | JULY 25, 2015**

Opposition lawmaker Um Sam An has been suspended from the next 15 sessions of parliament and will have his salary cut as punishment for critical comments he posted to Facebook earlier this month, according to a statement issued Friday by the National Assembly's Secretariat General.

Mr. Sam An, whose post on July 14 claimed that CPP Assembly President HengSamrin had unconstitutionally blocked a letter to Prime Minister Hun Sen, will also be publicly shamed through notifications posted at commune offices in his constituency of Siem Reap province, the statement said.

"His Excellency Um Sam An, a lawmaker for Siem Reap province, is reprimanded and received disciplinary action in accordance with Article 81 of the National Assembly's internal rules as follows: A, cut 50 percent of wages for two months. B, publicly display punishment notifications and print it to display in all communes of Siem Reap. C, ban from taking office at the National Assembly for 15 respective sessions," the statement reads.

Mr. Samrin refused to endorse a July 6 letter from Mr. Sam An and 11 other CNRP lawmakers calling for the government to halt demarcation of Cambodia's border with Vietnam until 2018, and asking for the government to explain land swaps along the Vietnamese border.

Responding to the ensuing Facebook post by Mr. Sam An, National Assembly spokesman ChheangVun said last week that the decision was made because the letter amounted to a demand rather than questions.

However, Mr. Sam An insists that his constitutional right as a lawmaker to put questions to the government was violated, and that the letter was not forwarded to Mr. Hun Sen because of its politically sensitive subject matter.

Friday's decision to punish the CNRP parliamentarian was made during a meeting of the National Assembly's 13-member permanent committee, according to EngChhayEang, one of six CNRP lawmakers on the committee.

Mr. ChhayEang said the move to punish Mr. Sam An was proposed in a letter endorsed by 50 ruling party lawmakers, and approved by the seven CPP lawmakers on the permanent committee.

"In brief, we didn't vote in support," Mr. ChhayEang said of the CNRP members.

Mr. Sam An said on Friday that the punishment was overly harsh and that he would try to meet with Mr. Samrin to "finish this story."

"Actually, we want to find a political compromise with SamdechHengSamrin to finish this story," he said. "Because I think we should not argue among Khmer, but we need to focus on border issues to the north, west and east sides."

Mr. Sam An, along with CNRP lawmaker Real Camerin, has been at the fore of a recent campaign to spotlight Vietnamese border encroachments, which has sparked a public relations battle with the CPP government.

In recent weeks, the Foreign Affairs Ministry has sent a number of terse diplomatic notes to Vietnam asking it to withdraw from territory that is either in Cambodia or still disputed.

Mr. Hun Sen has even taken the unprecedented step of admitting that some posts along the border with Vietnam may have been placed inside Cambodian territory, promising to "demand corrections" in such cases.

Asked on Friday about the punishment handed down to Mr. Sam An, Mr. Vun, the National Assembly spokesman and a CPP lawmaker, said he did not want to discuss the issue.

"Don't ask me to speak. I don't want to speak, do you understand?" the spokesman said. "So I ask you not to mess around, and let others deal with this situation."

---

## តមកពីទំព័រទី ១២ ឧកញ៉ា សុខ ប៊ុន ត្រូវបានបញ្ជូនទៅ...

ត្រឡប់មកប្រទេសកម្ពុជាវិញដោយស្ម័គ្រចិត្ត បន្ទាប់ពីក្រុមគ្រួសាររបស់គាត់បានប្រាប់គាត់អំពីសុន្ទរកថារបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ។

លោកមានប្រសាសន៍ថា "បន្ទាប់ពីសម្តេចនាយករដ្ឋមន្ត្រីអំពាវនាវឱ្យគាត់ចូលខ្លួនក្រុមគ្រួសាររបស់គាត់បានប្រាប់ឱ្យគាត់ត្រឡប់មកវិញ ។ បន្ទាប់ពីទទួលបានដំណឹងពីក្រុមគ្រួសាររបស់គាត់ ហើយបានទៅទទួលគាត់នៅឯអាកាសយានដ្ឋាន និងបញ្ជូនគាត់ទៅតុលាការតែម្តងកាលពីព្រឹកថ្ងៃសៅរ៍" ។

លោកបានលើកឡើងទៀតថា អង្គរក្សរបស់លោក សុខ ប៊ុន ដែលលោកបដិសេធមិនប្រាប់អត្តសញ្ញាណ និងដែលក្នុងរូបភាពវីដេអូកាមេរ៉ាសុវត្ថិភាពគេឃើញកាន់កាំភ្លើងច្រងេងច្រងាង ហើយភ្ជង់ក្បាលកញ្ញា ឯក សុជាតា នោះ កំពុងរត់គេចខ្លួននៅឡើយ ។

លោកបានមានប្រសាសន៍ថា "ឥឡូវនេះយើងកំពុងតែរង់ចាំដីកាចាប់ខ្លួនពីតុលាការ ហើយខ្ញុំជឿជាក់ថា គាត់មិនទាន់ទៅណាឆ្ងាយទេ" ។ លោកបានបន្ថែមថា លោកមិនដឹងថា បុរសរូបនេះកំពុងស្ថិតក្នុងប្រទេសនៅឡើយ ឬក៏អត់នោះទេ ។

ពេលទាក់ទងកាលពីម្សិលមិញកញ្ញា ឯក សុជាតា បានគូសបញ្ជាក់ជាថ្មីថា នាងនឹងមិនដោះស្រាយបញ្ហានេះជាមួយលោក សុខ ប៊ុន នៅក្រៅប្រព័ន្ធតុលាការឡើយ មិនថាគាត់ផ្តល់ប្រាក់ប៉ុន្មាននោះទេ ។

កញ្ញាបាននិយាយថា "ខ្ញុំនៅតែទាមទារឱ្យចាត់វិធានការផ្លូវច្បាប់លើរូបគាត់ ហើយខ្ញុំនឹងមិនធ្វើការសម្របសម្រួលណាមួយក្រៅប្រព័ន្ធតុលាការឡើយ ។ ខ្ញុំឈានទៅមុខហើយដូច្នេះខ្ញុំនឹងមិនថយក្រោយវិញទេ" ៕

**សុខុម និង ស៊ុយឈាង (រាយការណ៍បន្ថែមដោយ Chris Mueller)**

ឌឹ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសម្រួលពីភាសាអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី

# សកម្មជនសង្គ្រោះជាតិត្រូវតុលាការកាត់ឱ្យជាប់ទោសពីបទកុបកម្ម

**ដោយឃី សុវុឌ្ឍី** | July 21, 2015

សកម្មជនសង្គ្រោះជាតិ១១នាក់ដែលត្រូវជំនុំជម្រះពីបទកុបកម្មទាក់ទងនឹងតួនាទីរបស់ពួកគេនៅក្នុងការតវ៉ាដោយហិង្សាកាលពីថ្ងៃទី១៥ ខែកក្កដា ឆ្នាំមុន ត្រូវតុលាការក្រុងភ្នំពេញរកឃើញថា មានទោសនៅរសៀលថ្ងៃនេះ ហើយបានផ្តន្ទាទោសឱ្យជាប់ពន្ធនាគារពី៧ទៅ២០ឆ្នាំ។

សាលក្រមនេះបានប្រកាសដោយមានវត្តមានមេធាវីតែម្នាក់គត់ ហើយមេធាវីផ្សេងទៀតបានធ្វើពហិការមិនចូលរួមក្នុងសវនាការរបស់តុលាការដែលពន្លឿនការជំនុំជម្រះនេះ។

ចៅក្រមជំនុំជម្រះ លឹម មករន្ទ បានប្រកាសថា "តុលាការសម្រេចកាត់ទោស មាជ សុវណ្ណារ៉ា អឿ ណារិទ្ធ និង ឃិន ចំរើន ឱ្យជាប់ពន្ធនាគាររយៈពេល២០ឆ្នាំពីបទដឹកនាំកុបកម្ម"។

សកម្មជនគណបក្សសង្គ្រោះជាតិប្រាំបីនាក់ផ្សេងទៀតត្រូវបានកាត់ឱ្យជាប់ពន្ធនាគាររយៈពេល៧ឆ្នាំពីបទចូលរួមក្នុងកុបកម្ម។

ការតវ៉ាកាលពីឆ្នាំមុនដើម្បីបើកទីលានប្រជាធិបតេយ្យឡើងវិញ បានក្លាយទៅជាហិង្សាក្នុងពេលដែលក្រុមសន្តិសុខខណ្ឌដែលពូកែប្រើហិង្សា បានប៉ះទង្គិចជាមួយក្រុមអ្នកតវ៉ាដែលបានតតបវិញជាលើកទី១។ ចុងចោទបានសារភាពថា ខ្លួនបានចូលរួមក្នុងការតវ៉ា ប៉ុន្តែបានបដិសេធថា ខ្លួនមិនបានចូលរួមក្នុងការប្រើហិង្សាទេ៕



Opposition activist OukPichSamnang leaves the Phnom Penh Municipal Court on Tuesday after being sentenced to seven years in prison for joining an insurrection. (SivChanna/The Cambodia Daily)

# CNRP Activists Convicted on Insurrection Charges

**BY KHY SOVUTHY | JULY 21, 2015**

Eleven CNRP activists standing trial on insurrection charges over their roles in a violent protest on July 15 last year were found guilty by the Phnom Penh Municipal Court on Tuesday afternoon and sentenced to between seven and 20 years in prison.

The decision was made in the absence of all but one of the defense lawyers, most of whom were boycotting a decision




**Continued to Page 21**

## តមកពីទំព័រទី ០១ ព្រំប្រទល់ខ្មែរវៀតណាម...

ប្រកាន់នយោបាយថា, ខ្លួនខ្លាំងមហិមាស្រវាឱបយកដីប្រទេស២.៣របស់គេវាជាការងាយយល់ណាស់ថា វៀតណាមកំពុងដេកឱបបន្លាតែប៉ុណ្ណោះ បើមិនស្លាប់ក៏គង់របួស ពីព្រោះយួនតែម្នាក់ឯងទៅបង្កើតសត្រូវគ្រប់ជ្រុង មានខ្មែរ ឡាវ នឹងចិន រីឯក្នុងស្រុកខ្លួនឯងដ៏គ្មានលំនឹងនោះមានខ្មែរក្រោមក្រុមកុកសម៉ុងតាញ៉ានឹងយួនសេរី ហើយពួកមិនមែនយួននៅក្នុងស្រុកនោះ មានចលនាតស៊ូរំដោះជាតិក្រៅស្រុករបស់គេពេញពិភពលោកថែមទៀត។

ថ្មីៗនេះ នៅប្រទេសខ្មែរមានសញ្ញាខ្លះៗហើយថា ការដឹកនាំកំពុងទាញប្រទេសចេញពីក្រញ៉ាំយួនហាណូយ ។ ទាំងបក្សប្រឆាំងនឹងអ្នកកាន់អំណាចហាក់ដូចជាបានមូលមាត់គ្នាដណ្តើមយកដែនដីនឹងដែនទឹកមកវិញ តាមរយការទូតក្តីចរចាតាមបច្ចេកទេសទំនើបក្តី ហើយក៏អាចនឹងត្រឡប់ទៅដាស់សន្ធិសញ្ញាក្រុងប៉ារីសឆ្នាំ១៩៩១ ដែលក្នុងនោះយួនបានសន្យាផ្តល់ឯករាជ្យ និងបូរណភាពគ្រប់គ្រាន់ឱ្យមកខ្មែរវិញ ជាមួយនឹងប្រទេសហត្ថលេខី១៨ទៀត ។ យួនមិនមានជម្រើសច្រើនទេ ដោយគេសង្ឃឹមថា នឹងផ្តល់យ៉ាងហោចណាស់ ក៏ដែនដីខ្មែរជំនាន់មុនសង្គ្រាមឆ្នាំ១៩៧០ដែរមកឱ្យខ្មែរវិញដែរ។



យើងនិយាយដោយប្រើពាក្យ"យ៉ាងហោចណាស់" ពីព្រោះថា ប្រសិនបើមានការរើបំរះរបស់ប្រជាពលរដ្ឋខ្មែរក្រោមប្រទេសវៀតណាមអាចនឹងត្រូវកាត់ផ្តាច់យ៉ាងងាយស្រួល ពីព្រោះអ្នកដែលមានឈាមជាខ្មែរមានដល់ទៅ៩០% នៃប្រជាជនខាងត្បូងនាដែនដីសណ្តរឯណោះ។ ប្រជាជនភាគតិចនៃភូមិភាគកណ្តាលយោងតាមជំរឿនប្រជាជន ក៏មានចំនួនមិនចាញ់ខ្មែរនៅតំបន់ខាងត្បូងដែរ ដូច្នេះក៏ងាយស្រួលផុយឆាប់បែកណាស់ដែរ។ បច្ចុប្បន្នវៀតណាមចង់នៅជាគណកម្មការអចិន្ត្រៃអ.ស.ប.ខាងផ្នែកសិទ្ធិមនុស្សជាតួនាទីដែលមន្ត្រីយួនមិនត្រូវជំទាស់នឹងបំណងសម្រេចវាស្នាអាយុជីវិតតំបន់ខ្លួនដោយខ្លួនឯងទៀតផង។ តើហេតុអ្វីក៏យួនដែលខ្មែរជាច្រើន តែងវាយតម្លៃថា ជាជនជាតិពូកែគិតអ្វីចេះតែត្រូវចេះតែព្យាយាម ឥឡូវបែរជាគិតស្រាលកំភ្លើកទៅវិញ? ពីព្រោះមិនត្រឹមតែរបូតខ្មែរនឹងឡាវពីដៃដ៏ក្រខ្វក់របស់ខ្លួននោះទេ ថែមទាំងអាចបាត់បង់ដែនដីដែលខ្លួនប្រវ័ញ្ចយកពីអតីតកាលវិញនោះផង ។

ចំណេះរបស់កុម្មុយនិស្ត គឺអំនួតនឹងភូតភរនឹងសំឡុតជាប្រចាំកម្ពុជាបានស្គាល់ច្បាស់ពីចំណេះដ៏លីលានេះ វានឹងចាញ់អាត្មាបន្ទាប់ពីភរគ្មានគេជឿ អួតគ្មានគេសសើរសំឡុតគ្មានគេខ្លាចមក៕

**តមកទំព័រទី ០២** ទៅលេងញូយ៉ក...

ស្រុកអាស៊ី ឬដូចខ្មែរទាំងស្រុងទេ។ គេគួរដឹងថា បើចង់រកគុយទាវកាហ្វេឆ្ងាញ់នៅហ្វីឡាខាងជើង គេទៅរកគុយទាវ "ណាមវ៉ាង"នៅផ្លូវវ៉ាយស៊ីងសាន់ -នៅខាងត្បូងគេទៅរកបាយស្រូប ម្ហូបខ្មែរ-ចិននៅគុយទាវ"ភ្នំពេញ"នៅផ្លូវលេខ៧ -បើរកម្ហូបខ្មែរឥឡូវនៅសល់មួយដែលគេនិយាយច្រើន គឺនៅប៉ែកខាងត្បូងលើផ្លូវលេខ៦ខាងត្បូងឈ្មោះ"ខ្មែរឃីតឆិន" ចំណែកឯហាងលក់គ្រឿងទេស ឬអលង្កា សំលៀកបំពាក់គ្រឿងបន្លែត្រីសាច់ គឺនៅផ្លូវលេខ៦-៧ខាងត្បូង -នៅខាងជើងក៏មានហាង២ធំៗដែរ នៅ"វ៉ាយស៊ីនសាន់ នឹងបិនស៊ីទី" រីឯខាងលិចវិញ គេច្រើនមកទិញឥវ៉ាន់នៅផ្លូវលេខ៧ខាងត្បូង។


រឿន វាសនា

គួរមានការកត់សំគាល់ដ៏សំខាន់មួយថា នៅហ្វីឡាដែលហៀវមានក្រុមអ្នកធ្វើវិបស្សនាកម្មដ្ឋានដ៏ធំបង្អស់មួយដែលមានចំណុចកណ្តាលនៅប៉ែកខាងជើងប្រមូលចាស់ក្មេងឱ្យទៅ"អង្គុយធម៌"នៅគ្រប់ទីសទីយ៉ាងស្ងាត់ស្ងៀមនឹងប្រសិទ្ធិភាពតែមិនមានមជ្ឈមណ្ឌលរបស់ខ្លួននៅហ្វីឡាទេ... ការអង្គុយធម៌នេះ នាំឱ្យចាស់ជាពិសេសមានសមត្ថភាពគ្រប់គ្រងខ្លួនឯងឡើងវិញ យ៉ាងមាំមួនកើនអាយុ ហើយរីករាយជាងមុន។

វត្ថុបំណងដែលយើងទៅហ្វីឡាដែលហៀវលើកនេះ មិនគ្រាន់តែទៅទស្សនាតំបន់កំណើតកាសែតខ្មែរផុសតែប៉ុណ្ណោះទេ តែយើងចង់បញ្ឈប់ការចែកចាយកាសែតខ្មែរនៅទីនោះថែមទៀត ដោយសារស្ថានភាពសេដ្ឋកិច្ច តែបំណងនោះ នឹងបានត្រូវផ្អាកមួយរយៈបន្ទាប់ពីបានទទួលយោបល់មួយចំនួន។

បន្ទាប់ពីសម្រាក២យប់ ថ្ងៃច័ន្ទ ទី៦កក្កដា យើងចេញដំណើរត្រឡប់ពីហ្វីឡាមកឡូវែលវិញ ដោយកាត់តាម"ដាន់បូរី"តំបន់ខាងលិចនៃរដ្ឋកុណិចទីកិតជាប់គ្នានឹងញូយ៉ក។ យើងបានជួបអតីតនាយទាហ៊ានអាមេរិកាំងដ៏ក្មេងម្នាក់ដើមកំណើតខ្មែរឈ្មោះ រឿន វាសនា ដែលបានទទួលយើងនារសៀលថ្ងៃដដែលយ៉ាងរាក់ទាក់មករស់នៅទីនោះ គេបាននិយាយថា "ទីនេះមានខ្មែរមិនដល់៥០០នាក់ទេ តែរស់នៅដាច់ៗពីគ្នាជីវភាពធូរធាដោយសម្បូរកាងារធ្វើមិនដាច់ទេ ជាពិសេសញូយ៉កនៅប្រមាណ២០នាទី ពីដាន់បូរីប៉ុណ្ណោះ។ ឥឡូវដាន់បូរីមានវត្តខ្លួនឯងមួយហើយ គឺជាទីដែលខ្មែរយើងទៅជួបជុំគ្នានៅទីនោះ"។

យើងមកដល់ឡូវែលវិញ ជិតពេលអាធ្រាតយ៉ាងនឿយហត់តែរីករាយនឹងដំណើរជើងគោកដែលយើងខានធ្វើជាយូរមកហើយ ៕

# លិខិត លោក គឹម គៀន នឹងលិខិតឆ្លើយតបរបស់ លោក ពិន សំខុន ពីរឿងសហពន្ធខ្មែរកម្ពុជាក្រោម

**សូមជំរាបចូលមកលោកពីនសំខុន្សចាងហ្វាងសារពត៌មានខ្មែរផុស**
**"KHMER POST" ចេញផ្សាយនៅរដ្ឋម៉ាសាឆូសេតស.រ.អា.**

**សូមទានជ្រាប !**

ខ្ញុំ គឹម ភៀន ធ្លាប់ចូលរួមចំណែកសរសេរអត្ថបទជាភាសាខ្មែរចុះផ្សាយក្នុងសារព័ត៌មានរបស់លោកក្នុងបំណងអភិរក្សអក្សរសាស្ត្រជាតិយើងឱ្យបានគង់វង់យូរអង្វែងនៅបរទេសនេះ។ ដោយយល់ថាណាមួយខ្លួនកាន់តែចាស់ហើយណាមួយទៀតដោយឃើញឧប្បត្តិហេតុនៃការសរសេរនេះ ច្រើនកើតឡើងផ្ទុយពីគោលបំណងដែលខ្លួនចង់បាន ដូចរឿងចំរូងចំរាស់កើតឡើងនៅវត្តសុរិយរង្សី គេហៅថា វត្តណត់ នោះ ខ្ញុំដឹងថា បើមិនខំសរសេរសម្រុះសម្រួលឱ្យមើលមុខគ្នាឱ្យចំហើយចរចារគ្នាឱ្យត្រង់ទៅត្រង់មក ប្រសិនណាយើងពីតជាចង់រួមកសាងសង្គមមួយសុខដុំរម្មនាមែន សុំកុំផ្តាំទៅ,ផ្ញើមក,នាំឱ្យរឿងកាន់តែបែករីកសាយភាយឡើងមិនចប់ទេ ដោយខ្ញុំលើកហេតុផលឱ្យឃើញថា ម្ខាងៗសុទ្ធតែមានកំហុសបន្តិចបន្តួចរៀងខ្លួន គួរបំភ្លេចចោល ហើយជួបគ្នាសាងក្តីសាមគ្គីជាថ្មី។ ខ្ញុំបានទាំងលុតជង្គង់ថ្វាយបង្គំ សុំអង្វរទាំងសង្ខាង (កាលនោះខ្ញុំអាយុ៧៥ឆ្នាំ)តែខ្ញុំគ្រាន់តែបានចម្លើយមួយម៉ាត់ថា "Too late"=ហួសពេលហើយ! ចុងបញ្ចប់មិនគ្រាន់តែវត្តសុរិយារង្សីត្រូវបែកជាចម្រៀកលក់វត្តចែកគ្នាទេ(ម្ខាងយកលុយដើររកទិញវត្តថ្មីម្ខាងរក្សាទុកវត្តជារបស់ខ្លួនតទៅទៀត) រូបខ្ញុំក្លាយជាអនាថាគ្មានខាងណារាប់អានទាំងអស់។ ខ្ញុំក៏មានពិសោធន៏មួយដែរថា រវាងមនុស្សបាក់បែកគ្នាជាពីរក្រុមកុំសង្ឃឹមថា ខ្លួនអាចបង្ហាញផ្លូវកណ្តាលឱ្យដើរនឹងបានគេស្រឡាញ់រាប់អានទាំងសង្ខាងនោះ ផ្ទុយទៅវិញទេគឺគេស្អប់ទាំងសង្ខាងតែម្តង! ព្រោះតែយើងមិនព្រមកាន់ជើងគេមួយរយភាគរយ១០០/១០០ ព្រោះថាគេត្រូវកន្លែងនេះវាល្អហើយ តែមិនល្អសោះព្រោះបានបង្ហាញកន្លែងគេធ្វើខុស។ ព្រោះដឹងថាមិនបានសុខទើបចង់ឈប់សរសេរ,តែ ព្រឹកនេះ (ថ្ងៃទី១២/៧/១៥)បានដំណឹងថា មានព្រះសង្ឃមួយព្រះអង្គនិមន្តមកពីខេត្តព្រះសួគ៌ា,កម្ពុជាក្រោមដើម្បីបិណ្ឌបាត្របច្ច័យកសាងសាលាមួយខ្នងខ្ញុំក៏ទៅចូលរួម។ តែការដែលធ្វើឱ្យខ្ញុំខកចិត្តយ៉ាងខ្លាំង គឺបងប្អូនក្នុងពុទ្ធបរិស័ទមួយចំនួនមិនសប្បាយចិត្តនឹងសារព័ត៌មានខ្មែរផុសដោយបានឃើញចុះផ្សាយពីថ្ងៃបុណ្យរំលឹកខួបការបាត់បង់ទឹកដីកម្ពុជាក្រោមសរសេរដោយ លោក ពិន សំខុន ស្តីពី "អង្គការសហព័ន្ធខ្មែរកម្ពុជាក្រោមក្នុងដំណើរទៅកាន់មាតុភូមិ" តែមិនបានសរសេរដូច្នោះលោកបានសរសេរថា **"រដ្ឋាភិបាលខ្មែរក្រោម"** ក្នុងដំណើរទៅកាន់មាតុភូមិវិញ។ បងប្អូនមួយចំនួនត្រឡប់ជាមកអាក់អាក់អន់ចិត្តនឹងខ្ញុំទៅវិញ ដោយស្មានថា ខ្ញុំបានសរសេរអត្ថបទ នោះ។ កំហុសត្រង់ថា លោកបានសរសេរថា **"រដ្ឋាភិបាលខ្មែរក្រោម"**ជំនួសពាក្យថា **" អង្គការសហ ព័ន្ធខ្មែរកម្ពុជាក្រោម"** ទៅវិញ។ ខ្ញុំបានសុំឱ្យលោក ម៉ាន់ រិន ជម្រាបមកលោកកែតម្រូវប្រសិនមាន ការខុសឆ្គងអីម្យាងៗ តែគាត់មិនព្រមហើយប្រកាន់មាំថា លោក ពិន សំខុន សរសេរខុសត្រូវតែកែខ្លួនឯងចាំបាច់គាត់សុំអី (SIC)។ ខ្ញុំថាបើគាត់គ្មានពេលតបសុំឱ្យខ្ញុំតបក្នុងនាមជាតំណាងសហព័ន្ធគាត់ក៏មិនព្រម។ ខ្ញុំយល់ខ្លះដែរវាងពាក្យថា រដ្ឋាភិបាលនឹងអង្គការសហព័ន្ធនេះវាមានផលវិបាកខុសគ្នាឆ្ងាយណាស់ពេលប្រើពាក្យទាំងពីរនេះមិនត្រូវពេលវេលា។ សូមលោកជ្រាបថា រដ្ឋាភិបាលនេះទុកសម្រាប់ក្រុមលោក ថាច់ ច័ន្ទ, លោក ថាច់ តាន់តារា, ព្រះអង្គ គង់ ស៊ីផាន, ព្រះអង្គ គឹម កាង ជាដើម។ ប្រើពាក្យរដ្ឋាភិបាលនៅពេលនេះជាភាសាអត្តឃាតហើយចំពោះភ្នែកអន្តរជាតិ។ ស្តាយណាស់ខ្ញុំមិនមានសិទ្ធិអីពន្យល់លោកបានច្រើនទេ មេត្តាលោកទាក់ទងទៅ លោក ម៉ាន់ រិន ឬលោកប្រធាន ថាច់ ង៉ុកថាច់ តែម្តង។ ចំណែកខ្ញុំសុំលោកមេត្តាសរសេរកែតម្រូវយ៉ាងណាឱ្យក្រុមបងប្អូនខ្មែរកម្ពុជាក្រោមនៅហ្វីឡាឈប់ចងពៀមយល់ច្រឡំមកលើរូបខ្ញុំតទៅទៀត ឱ្យខ្ញុំសុំសុខស្ងប់ពីថ្ងៃនេះតទៅ។

ចំពោះលោកវិញ ខ្ញុំគ្មានបន្ទោស ឬដាក់កំហុសអ្វីទេ ក្នុងការសរសេរពាក្យខុសឆ្គងនេះ ព្រោះលោកគ្មានព័ត៌មានពីអង្គការនេះគ្រប់គ្រាន់ដោយអង្គការនេះក៏គ្មានធនធានមនុស្សសម្បូរបែបដែរ ក្នុងការទំនាក់នងនឹងសារព័ត៌មានពិសេសជាមួយខ្មែរផូសនេះតែម្តង។ សូមលោកមេត្តាទទួលនូវការរាប់អានយ៉ាងកក់ក្តៅអំពីខ្ញុំ ។

## គឹមភៀនលិខិតឆ្លើយតបចំពោះ សមាជិក សមាជិកា សហព័ន្ធខ្មែរកម្ពុជាក្រោម តាមរយៈព័ត៌មានក្នុងលិខិតលោក គិម ភៀន

ខ្ញុំ ពិន សំខុន បានសរសេរដោយចេតនាដោយប្រើពាក្យថា **"រដ្ឋាភិបាលខ្មែរក្រោម"** ជំនួសពាក្យ **"សហព័ន្ធខ្មែរកម្ពុជាក្រោម"**ដោយមិនបានយល់ថា ជាពាក្យស្លាប់រស់របស់បងប្អូន។

**ដូច្នេះទី១**-សុំឈប់ច្រឡំថា អត្ថបទនេះជារបស់លោក គឹម ភៀន ទៀតទៅ ហើយសុំទោសដោយបានធ្វើឱ្យមានការឈឺចាប់ដល់លោកអ្នកដែលបានអានអត្ថបទនោះ។ ចំណែកលោកបង គឹម ភៀន ទៀតសោត ក៏សូមឈប់ឈឺចាប់នឹងព័ត៌មានដែលផ្សាយផ្ទាល់ចេញពីភាគីជម្លោះនៃវត្តសុរិយរង្សីតទៅទៀតដែរ សាមីខ្លួនគេអ្នកធ្វើយើងគ្រាន់តែជាព្រាបនាំសារតែប៉ុណ្ណោះ មិនគួរលោកបងទៅបាញ់ព្រាបនាំសារដោយសារតែគេលក់វត្តចែកគ្នានោះទេ។

**ទី២**-តទៅនេះ ខ្ញុំសូមធ្វើការកែតម្រូវនៅអត្ថបទ ចុះក្នុងកាសែតខ្មែរផុសស.រ.អា.លេខ ១៧៩ ទំព័រ៨ ដែលមានចំណងជើងថា **"រដ្ឋាភិបាលខ្មែរក្រោមក្នុងដំណើរទៅកាន់មាតុភូមិ"** សូមអានកែតម្រូវយ៉ាងដូច្នេះថា **"អង្គការសហព័ន្ធខ្មែរកម្ពុជាក្រោមក្នុងដំណើរទៅកាន់មាតុភូមិ"** វិញហើយសូមអភ័យទោសចំពោះការប្រើពាក្យខុសដោយចេតនានេះ ៕

## AMERICAN MUFFLER & BRAKE

យានដ្ឋានខ្មែរជួសជុលរថយន្តទូទៅតម្លៃសមរម្យ



Known as A muffler man. Customize pipe, exhaust & welding. come to see us we can make the different.

Shock & Struts, Tune-up, Axle Trans, Timing Belt, Customized Pipe Exhaust Clutch, Water Pump, Starter and much more...

WE FIX-U $SAVE

1380 Park Ave.
Cranston, RI 02920
Cell: 203-522-2174
www. amufflerman.com

Monday-Saturday 8:00 am-7:00 pm Phone: 401-944-3390
Open Sunday 9:00 am-3:00 pm Fax: 401-944-3390

**Mony, Chay, Sokheang, Sokheng & Jimmy**

WE ARE AT FIVE LOCATIONS

| | | | |
|---|---|---|---|
| 1412 Park Ave. Bridgeport, CT 06604 (203) 333- 0355 | 335 Whalley Ave. New Haven, CT 06511 (203) 777- 9800 | 1355 South Main St. Waterbury, CT 06706 (203) 757-7575 | 219N. Colony Rd. Wallingford, CT 06492 (203) 284-0861 |

## BUSINESS FOR SALE
## HENG EXPRESS

## លក់ភោជនីយដ្ឋានអាស៊ីនៅរ៉ូដអាយឡិន

Dine in-Take out
536 Cranston St.
Providence, RI 2907
18 Years in Business. Rent $1,000 per month, property tax is not included. Help training 1 month after purchased business. Call Soknieng at **401-274-6660**

## រកអ្នកធ្វើការ -ជាងធ្វើក្រចកស្រី ឬបុរស

ប្រាក់ខែជូនទៅតាមបទពិសោធន៏ពី $៥០០-$១.០០០ ក្នុង១អាទិត្យ
កន្លែងធ្វើការរវល់ច្រើន
Trenton, NJ ចម្ងាយ៤៥នាទី ពីហ្វីឡាដែលហ្វៀ
សម្រាប់អ្នកនៅឆ្ងាយមានកន្លែងឱ្យសំណាក់
ទូរស័ព្ទ : **609-227 1939**

## Help wanted – Nail Tecknician M or F

Salary base on experience $500-$1,000/week
Busy location, Trenton, NJ 45mn.from Phylly
For long distance, Provided accommodation
Call **609-227 1937**

**Your classify ad is here for only $50 per month**

ពាណិជ្ជកម្មរបស់អ្នកនៅទីនេះ
ចំណាយចំណាយត្រឹមតែ
**$50** ក្នុង១ខែ

***CALL:***
***978.677.7163***

*EMAIL: SOBENPIN@KHMERPOST.US*

## សិក្សាពីឥស្លាម

**សួរ :** មានចម្ងល់អ្វីទេពីឥស្លាម?
**ឆ្លើយ :** សូមទៅមើលគេហទំព័រ www.peacetv.tv ឬគេហទំព័រមួយទៀត www.gainpeace.com.
Q) Any Questions on Islam?
A)watch www.peacetv.tv
visit www.gainpeace.com.



## CONWAY
INSURANCE AGENCY

រយៈពេល២៥ឆ្នាំ ភ្នាក់ងារធានារ៉ាប់រងខុនវេយបានបម្រើសហគមន៍ដោយធានារ៉ាប់រងគ្រប់មុខប្រកបដោយគុណភាពនៅតំបន់ញូអ៊ីងឡែន ។
យើងខ្ញុំជាភ្នាក់ងារបំពេញសេវាគ្រប់មុខដូចខាងក្រោម :

**ការធានារ៉ាប់រងគ្រួសារ**
- រថយន្ត
- ផ្ទះ
- ផ្ទះល្វែង
- គ្រឿងអលង្ការ
- វត្ថុសិល្បៈ
- វត្ថុបុរាណ

**ការធានារ៉ាប់រងជំនួញ**
- អចលនវត្ថុ
- សុវត្ថិភាពជំនួញ (Liability)
- សុវត្ថិភាពជំនាញ (Professional Liability)
- វិកខឺខម (Worker's Compensation)
- បនដស៍ (Bonds)
- អ្នកមើលថែឡាន និងការ៉ាស់ឡាន
- ធានារ៉ាប់រងពិការភាព និងជីវិត
- កម្មវិធីពិសេសផ្សេងៗទៀត

CONWAY INSURANCE AGENCY

77 E. Merrimack Street. Lowell, MA 01852
**Tel: 978-454-5054|Fax 978-453-2480**
www.conwayinsurance.com
សូមទាក់ទងមក : ហ្វីលីប មុត, អ្នកគ្រប់គ្រង

## ខូម័រ សិប្បកម្មច្នៃរូបសំណាកក្រានីត
## COLMER MONUMENT WORKS

Memorials of Distinction
អាស័យដ្ឋាន:1025 Lawrence Street Lowell, MA 01852-4898
**(978) 452-7821**




- Granite Memorials — ផ្នូររាងបញ្ឈរធ្វើពីថ្មក្រានីត
- Granite & Bronze Markers — ផ្នូរផ្ដេកមានឆ្លាក់សំរិទ្ធលេថ្មក្រានីត
- Cemetery Lettering in Khmer — មានឆ្លាក់អក្សរខ្មែរលើថ្មនៃផ្នូរ

COLMER Monument Works

ភាពថ្លៃថ្នូរ កិត្តិយស និងការគោរពជូនលោកអ្នក
*Honor. Dignity. Respect for All*

ព័ត៌មានខ្លីៗ

# វាស្នា នួន ធ្វើ“ហ្វាន់រេស៊ីង”

**ខ្មែរផុសស.រ.អា**

លោក វាស្នា នួន បានប្រកាសបេក្ខភាពរបស់ខ្លួនសម្រាប់ប្រជាពលរដ្ឋឡូវែល បោះឆ្នោតអោយក្លាយជាសមាជិកក្រុមប្រឹក្សាសាលាក្រុងឡូវែលដែលមាន៩រូប ក្នុងនោះមានប្រធានមួយរូបដែលមានតួរនាទីជាអភិបាលក្រុងឡូវែលសម្រាប់អាណត្តិ២០១៦-១៧។ គណកម្មការគាំទ្របេក្ខភាពរបស់លោកបានធ្វើពិធីជប់លៀងរៃអង្គាសលុយសម្រាប់ឃោសនាស្របច្បាប់កាលពីថ្ងៃសៅរ៍កន្លងទៅនេះ ប្រមូលភ្ញៀវចូលរួមប្រមាណជា២០០នាក់ នៅភោជនីយដ្ឋានសានីដា។

លោក វាស្នា នួន ធ្លាប់ជាប់ឆ្នោតធ្វើជាសមាជិកក្រុមប្រឹក្សាសាលាក្រុងឡូវែលម្តងរួចហើយ កាលពីអាណត្តិឆ្នាំ២០១២-១៣ តែអាណត្តិបន្តភ្លាមបន្ទាប់មកលោកមិនបានជាប់នៅក្នុងដំណែងនេះទៀតទេ ។ នៅក្នុងពិធីជប់លៀងលោក វាស្នា មានវោហាថ្លែងពីបំណងដ៏ច្រើនសម្រាប់បំរើសហគមន៍ឡូវែលតែអិតបាននិយាយពីបុព្វហេតុដែលនាំអោយលោកចាញ់ឆ្នោតពីលើកមុន ហើយដកបទពិសោធន៍នោះមកដណ្តើមយកជ័យជំនះនាពេលនេះនោះទេ។ នៅក្នុងលិខិតផ្សព្វផ្សាយឃោសនារបស់លោក វាស្នា គេអាចឃើញមានការគាំទ្រយ៉ាងកក់ក្តៅពីលោកស្រីអគ្គរដ្ឋអាជ្ញារដ្ឋម៉ាសាឈូសិត ម៉ូរ៉ា ហ៊ីលិ ដ៏មានប្រជាប្រិយ ចំពោះបេក្ខភាព វាស្នា នួនផងដែរ។ ក្រៅពីនេះ បញ្ញវន្តនៃសហគមន៍ខ្មែរបានមកជួបជុំគ្នាស្ទើរទាំងអស់គ្នា ពីព្រោះលោកមានមិត្រជិតស្និតស្នាលច្រើនគ្នា...ចំណែកពួកបរទេសមានឃើញវត្តមាន ខប្លីន នៃសាលាក្រុង នឹងមេធាវីល្វីស ហាស្កុល្ប ថម ស្គាលិណូស...។ល។ ព្រះសង្ឃថ្មីវស្សា គឺព្រះតេជគុណ អ៊ុង រិទ្ធី នឹង ព្រះតេជគុណ វណ្ណ ម៉ែន ក៏បាននិមន្តទៅសម្តែងការគាំទ្រទាំង



ទើសទាល់ផងដែរ។

ចរន្តនៃទស្សនៈបោះឆ្នោតសហគមន៍ខ្មែរពេលនេះ គឺ "ខ្មែរបោះឆ្នោតឱយខ្មែរ" តែទស្សនៈនេះ អាចមិនហ្នឹងហ្នទេ នៅពេលជិតដល់ថ្ងៃបោះឆ្នោត ចំណែកឯការខិតខំថែរក្សាកេរឈ្មោះឯណោះទេ ដែលរឹងមាំសម្រាប់បេក្ខជនម្នាក់ៗ។ រាត្រីឃោសនារបស់លោក វាស្នា នួន មានកំដរដោយវង់តន្ត្រីសម័យយ៉ាងពិរោះនាំភ្ញៀវអោយរាំកំសាន្តយ៉ាងរីករាយក្រៃលែងរហូតដល់ម៉ោង១២អាធ្រាត៕

# មនុស្សក្នុងនយោបាយខ្មែរ២រូប ចូលសាងផ្នួស

**ដោយ ខ្មែរផុសស.រ.អា.**

**ឡូវែលៈ** សកម្មជននយោបាយ២រូប គឺលោក អ៊ុង រិទ្ធី អតីតទីប្រឹក្សាក្រុងឡូវែលនិងជាសកម្មជនគណបក្សសង្គ្រោះជាតិ នឹងលោក វណ្ណ ម៉ែន បេក្ខជនប្រធានជាប់ឆ្នោតគណបក្សសង្គ្រោះជាតិនៅម៉ាសាឈូសិតតែមិនបានទទួលការតែងតាំងពីប្រធានបក្សបានចូលសាងព្រះផ្នួសនៅវត្តត្រៃរតនារាម កាលពីថ្ងៃទី១០ ខែកក្កដាមុននេះ ចំពោះមុខព្រះគ្រូឧបជ្ឈាព្រះតេជគុណមី ឡែម ជាចៅអធិការវត្ត។

បន្ទាប់ចាកសិក្ខាបទមកវិញនៅថ្ងៃអាទិត្យទី១៩ គឺបានគ្រងចីវរសុំសីលចំនួន១០ថ្ងៃ នៅក្នុងវត្តមក លោក វណ្ណ ម៉ែន និយាយថា ការបួសជាសង្ឃគឺកាហាត់ពត់រំងាប់ចិត្តត្រូវរក្សាភាពស្មោះត្រង់មិនថា តែក្នុងនយោបាយទេ ក្នុងគ្រួសារក្នុងសង្គមក៏ត្រូវធ្វើជាប្រចាំមិនត្រូវទុករឿងលំបាកកើតទុក្ខ ឬសប្បាយពេកនៅក្នុងចិត្តច្រើនទេ ត្រូវបំភ្លេចឱ្យអស់។

លោក អ៊ុង រិទ្ធី និយាយពីបុព្វហេតុនៃការចូលទៅបួសថា ញោមប្រុសនឹងញោមស្រីរបស់លោកមានអាយុជាង៩០ម្នាក់ៗទៅហើយ សព្វថ្ងៃរស់នៅកាលីហ្វ័យនីញ៉ា ការបួសនេះ ជាប្រពៃណីខ្មែរធ្វើសម្រាប់សងគុណឪពុកម្តាយដែលបានឱ្យកំណើតដល់ខ្លួន។ រីឯលោក វណ្ណ ម៉ែន និយាយថា ពេលនេះជាឱកាសសម្រាប់បួសសងគុណ ខ្ញុំក៏ធ្វើនេះសម្រាប់ញោមនឹងក្រុមគ្រួសារដែលតាំងតែពីមកដល់សហរដ្ឋអាមេរិក មិនដែលបានធ្វើបុណ្យបញ្ជូនកុសលអ្វីដល់អ្នកនៅស្រុកខ្មែរនៅឡើយទេ



ជាពិសេសជូនកុសលដលប្អូនប្រុសខ្ញុំឈ្មោះ ម៉ែន ណុច ដែលបានបូជាជីវិត កាលពីពាន់ឆ្នាំមុន ក្នុងការតស៊ូមតិនៅស្រុកខ្មែរ ដែលគេបានធ្វើឱ្យដួលបោកក្បាលនឹងថ្មស្លាប់នៅកន្លែង ហើយខ្ញុំបានសច្ចាថានឹងបួសសងគុណបញ្ជូនកុសលប្អូនខ្ញុំ ឥឡូវខ្ញុំធ្វើបានហើយ៕

# គណបក្សប្រជាជនជួបសម្តែងការគួរសម

ជាមួយអភិបាលក្រុងឡូវែលឡូវែល,សមាជិកសមាជិកាគណបក្សប្រជាជននៅឡូវែលរដ្ឋម៉ាសាឈូសិតប្រមាណ២០នាក់ បានចូលជួបសម្តែងការគួរសមជាមួយអភិបាលក្រុងឡូវែល អេលិយ៉ុត វ៉ដនី កាលពីថ្ងៃសុក្រទី១៧ កក្កដាកន្លងទៅ។

តំណាងគណបក្សបាននិយាយថាៈ បំណងផ្ទះរបស់យើងជាអត្តសញ្ញាណរបស់យើង, ហើយឡូវែល គឺជាអនាគតរបស់យើងនឹងរបស់កូនចៅយើងទៀតផង។

នេះជាលើកដំបូងបង្អស់ហើយ ដែលគណបក្សប្រជាជនចេញបង្ហាញខ្លួនជាសាធារណនឹងដោយចំហរដឹកនាំដោយលោក អ៊ូ សុវណ្ណ អគ្គកុង ស៊ុល



របស់យើងគឺគាំទ្រយ៉ាងសកម្មរដ្ឋាភិបាលកម្ពុជា ហើយផ្សព្វផ្សាយដំណឹងពិតដល់ប្រជាពលរដ្ឋខ្មែរអាមេរិកាំងនៅឡូវែលផង។ ទន្ទឹមនឹងការចូលរួមនយោបាយនៅកម្ពុជាយើងក៏មានបំណងចូលរួមផងដែរ នូវសកម្មភាពសហគមន៍នឹងហេដ្ឋារចនាសម្ព័ន្ធអភិវឌ្ឍន៍ក្នុងទីក្រុងឡូវែលនេះដែរ។ យើងខ្ញុំមានជំនឿថា ច្បាស់ជាអាចចែករំលែកនូវធនធាននឹងរាប់ថា ឡូវែល គឺជាព្រះរាជាណាចក្រកម្ពុជានឹងលោក តុលា យុទ្ធ មានអមដំណើរដោយគណកម្មការរដ្ឋម៉ាសា-ឈូសិត និងក្រុមយុវជនផង នេះគឺបន្ទាប់ពីចលនានៃវប្បធមិសន្ទនាបានបង្កើតឡើង ហើយបន្ថយភាពតានតឹងរវាងគណបក្សកាន់អំណាចនឹងគណបក្សប្រឆាំងទាំងក្នុងស្រុកក៏ដូចក្រៅស្រុកមក៕

# CMAA

You are cordially invited to join the CMAA family this year again as we host another evening of fashion, food, music and fun while raising money to help educate and empower our community. This beautiful evening will take place Friday, July 31, 2015 at Lenzi's Restaurant in Dracut, MA

Philadelphia
雷 文 貿 易
Raymond Trading
吴 鎮 海
Hai Tuan Ngo
1601 Washington Ave
Phila, PA 19146
U.S.A
U.S.A.Cell:1-267-242-3846
CHINA Cell:86-136-4076-5741
E-mail:haingo88@yahoo.com

តមកពីទំព័រទី ១៩

## រដ្ឋាភិបាលបញ្ចេញសេចក្ដីព្រៀងច្បាប់...

លោកថ្លែងថា "ការងារដែលកាំកុងត្រួលបានធ្វើគឺតិចតួចនៅមានកម្រិត និងមិនពេញលេញទេ។ ផលិតផលគ្មានសុវត្ថិភាពមួយចំនួនបានធ្វើចរាចរលើទីផ្សាររួចទៅហើយ ដូច្នេះអ្នកទទួលទានប្រឈមបញ្ហាសុខភាព? នៅពេលទទួលទាន និងប្រើប្រាស់ផលិតផលគ្មានសុវត្ថិភាពទាំងនោះ"។

ការងារព្រាងច្បាប់នេះដែលធ្វើឡើងដោយអង្គការ FAO និងក្រសួងពាក់ព័ន្ធដែលបានពិគ្រោះយោបល់ជាមួយមេធាវីជាតិ និងអន្តរជាតិ រួមជាមួយតំណាងមកពីវិស័យឯកជនបានចាប់ផ្ដើមនៅខែមករា ឆ្នាំ២០១៤ ហើយតាមការរំពឹងទុកថាសេចក្ដីព្រាងចុងក្រោយនឹងចប់រួចរាល់ក្នុងរយៈពេល៦សប្ដាហ៍។

អំឡុងម៉ោងសំណួរ និងចម្លើយនៅចុងបញ្ចប់នៃសិក្ខាសាលាដែលធ្វើឡើងកាលពីម្សិលមិញ អ្នកចូលរួមបានសួរថា តើច្បាប់នេះនឹងត្រូវអនុវត្តដោយរបៀបណា តើការអនុវត្តច្បាប់នេះទទួលបានមូលនិធិតាមណា ហើយអ្នកណាជាអ្នកទទួលខុសត្រូវចំពោះការព្រាងអនុក្រឹត្យជាក់លាក់បន្ថែមទៅលើបទប្បញ្ញត្តិមិនច្បាស់លាស់ក្នុងច្បាប់នេះ។

លោកស្រី អ៊ីមែនូអែល បចវ៉ែរ (Emmanuelle Bourgois) អ្នកផ្ដល់ប្រឹក្សាផ្នែកច្បាប់ដែលបានជួយធ្វើសេចក្ដីព្រាងច្បាប់នេះមានប្រសាសន៍ថា? សេចក្ដីលម្អិតអាចនឹងដោះស្រាយបានបន្ទាប់ពីច្បាប់នេះត្រូវបានអនុម័ត ដែលធ្វើឱ្យកម្ពុជាកាន់តែស្របទៅតាមលក្ខខណ្ឌតម្រូវរបស់អន្តរជាតិសម្រាប់ការនាំចេញចំណីអាហារ។ លោកស្រីបានគូសបញ្ជាក់ថា "អាចនឹងមានបទប្បញ្ញត្តិបន្ថែមទៀតដែលត្រូវអភិវឌ្ឍក្រោមអាជ្ញាធរសុវត្ថិភាពចំណីអាហារ"។

ចំណែកឯលោកស្រី នីណា ប្រ៉ែនស្ត្រាប់ ដែលមកពីអង្គការ FAO បានថ្លែងថា លោកស្រីអាចយល់បានចំពោះក្ដីបារម្ភដែលលើកឡើងនៅក្នុងម៉ោងសំណួរចម្លើយនៅឯសិក្ខាសាលានោះ។

លោកស្រីបានមានប្រសាសន៍ថា "សំណួរខ្លះឆ្លុះបញ្ចាំងថា ប្រជាជនមានការព្រួយបារម្ភចំពោះការអនុវត្ត ហើយខ្ញុំគិតថា នេះជាក្ដីបារម្ភដែលសមហេតុផល។ ការមានច្បាប់នេះ គឺជារឿងមួយអ្នកអាចមានច្បាប់ដែលល្អបំផុតនៅក្នុងពិភពលោកប៉ុន្តែប្រសិនបើមិនអាចអនុវត្តបាន នោះវាពិតជាគ្មានប្រយោជន៍ទាល់តែសោះ ហើយចាំបាច់ត្រូវមានការកែសម្រួលចេញខ្លះ"។

**សុខុម**

**Continued from page 17**

# CNRP Activists...

by the court on Monday to fast-track the trial.

"The court decides to sentence Meach Sovannara, OeurNarith and KhinChamroeun to 20 years in prison for leading an insurrection," Presiding Judge Lim Makaron told the court.

The other eight activists were sentenced to seven years in prison for joining an insurrection.

The protest last year to reopen Phnom Penh's Freedom Park turned bloody when the government's notoriously violent district security guards moved in on a group of protesters, who for the first time responded by fighting back.

The defendants have admitted to attending the protest, but deny any role in the violence



តមកពីទំព័រទី ០៤

## រំលឹកព័ត៌មានពីថ្ងៃ ២៧ ឧសភា...

ហើយបញ្ជូនទៅរដ្ឋសភាជាតិ។ ថ្ងៃ៨កក្កដា គណបក្សប្រជាជនរៀបចំកិច្ចប្រជុំជាមួយអ.ក.រ. ដើម្បីស្តាប់យោបល់: សមាជិកសភាបក្សប្រឆាំង, លីកាដូ នឹងអាដហុក ធ្វើពហិការ មិនចូលប្រជុំអត់តម្លាភាព អន្តរជាតិមិនបានត្រូវអញ្ជើញ...មានតែសមាគមយុវជនដែលនៅជិតរដ្ឋាភិបាលបានឡើងនិយាយគាំទ្រគម្រោងច្បាប់។ ថ្ងៃ៩កក្កដា សភាអឺរ៉ុបបានអនុម័តសេចក្តីសម្រេចចិត្តដែលស្នើឱ្យសភាខ្មែរបញ្ឈប់ការបោះឆ្នោតលើច្បាប់នោះ ពីព្រោះវាអាចធ្វើឱ្យខូចថវិការ៧០០លានដុល្លារក្នុងមួយឆ្នាំតាមរយថវិការដែលនាំមកដោយអ.ក.រ.ទសងនោះ(ខេមបូឌាដេលី១១.៧.១៥)

-ថ្ងៃ១៣កក្កដា ថ្ងៃអនុម័តច្បាប់យ៉ាងហោចណាស់បាតុករប្រឆាំងជាង១ពាន់នាក់ ព្យាយាមមកធ្វើបាតុកម្មនៅមុខរដ្ឋសភា(ខេមបូឌាដេលី១៣.៧.១៥)

-គម្រោងច្បាប់ស្តីពីសហជីពបង្ករឱ្យមានប្រតិកម្មរាប់ទាំងប្រតិកម្មរបស់អង្គការអន្តរជាតិខាងកាងារ (OIT) ដែលមើលឃើញថា "ដើរថយក្រោយ"។ ច្បាប់នោះនិយាយថា ត្រូវមានកម្មករក្នុងរោងចក្រចំនួន២០ភាគរយ ទើបចុះឈ្មោះបាន... ហើយន័យអត្ថបទចុងក្រោយអនុញ្ញាត្តឱ្យរដ្ឋមន្ត្រីក្រសួងកាងារអាចភ្សួរដើងសហជីពបានបើរដ្ឋាភិបាលយល់ថា "ជាសកម្មភាពបំផ្លាញសេដ្ឋកិច្ចដែលធ្វើឱ្យខូចខាតដល់ផលប្រយោជន៍ជាតិ" (ខេមបូឌាដេលី១០.៦.១៥)។




ហ៊ុន ម៉ាណែត

### ផ្សេងៗ

ថ្ងៃទី២៩ឧសភា គណបក្សប្រជាជនជ្រើសរើសអ្នកគាំទ្រមួយក្រុម ក្រោមការដឹកនាំរបស់ ហ៊ុន ម៉ាណែត កូនប្រុសរបស់ ហ៊ុន សែន ដើម្បីបញ្ចុះបញ្ចូលខ្មែរនៅបរទេស(ខេមបូឌាដេលី០២.០៦.១៥)។ ថ្ងៃ៧ មិថុនា ឯកអគ្គរាជទូត៧រូបបានត្រូវតែងតាំង ពួកគេបានទទួលបេសកកម្មឃោសនាឱ្យគណបក្សប្រជាជនក្នុងសហគមន៍ខ្មែរនៅឯបរទេស(ខេមបូឌាដេលី១៣.៦.១៥)។

ថ្ងៃ៦កក្កដា សភាបានអនុម័តច្បាប់ទប់ស្កាត់ការដំឡើងប្រាក់ឈ្នួលផ្ទះកុំឱ្យឡើងតាមល្បឿននៃប្រាក់ខែ(ខេមបូឌាដេលី០៧.៦.១៥)។

ថ្ងៃ១៤មិថុនា សាយ ឈុំ អគ្គលេខាបក្សប្រជាជន នឹង ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃទទួលគោរមងារជា "សម្តេច" ដែលមានឈ្មោះថា "វិបុលសេនាភក្តី" សម្រាប់ សាយ ឈុំ នឹង "ក្រឡាហោម" សម្រាប់ ស ខេង ។ ២០មិថុនា សាយ ឈុំ ឡើងជំនួស ជា ស៊ីម ជាប្រធានព្រឹទ្ធ-សភា។ ២១មិថុនា សមាជិកគណកម្មាកណ្តាលបក្សប្រជាជន៥០៨ ក្នុងចំណោម៥៤៥ បានបោះឆ្នោតឱ្យ ហ៊ុន សែន ក្លាយជាប្រធានគណបក្សប្រជាជន ស ខេង នឹង សាយ ឈុំ ជាអនុប្រធាន ។ សមាជិក៣៤រូប កាន់ដំណែងជាគណអចិន្ត្រៃយ៍ដែលត្រូវធ្វើសេចក្តីសម្រេចពី១ថ្ងៃទៅ១ថ្ងៃ ហើយនឹងសមាជិក៩រូបទៀតជាក្រុមអនុវត្តន៍(លើភារកិច្ច)។ ក្នុងចំណោមទីប្រឹក្សាទាំង៣៨រូបរបស់ សាយ ឈុំ គេកត់សំគាល់ ឌួង សុជាតិ ពីក្រសួងសុខាភិបាលដែលទទួលការចោទប្រកាន់ថា បានបន្លំយកប្រាក់៣៥ម៉ឺនពីថវិការប្រយុទ្ធប្រឆាំងជម្ងឺ "ស៊ីដា-របេង-គ្រុនចាញ់" (ខេមបូឌាដេលី២២.៦.១៥)។ សម រង្ស៊ី បានថ្លែងពី "ការពេញចិត្តនឹងសោមនស្សដ៏ធំធេង" នឹងការ "កោតសសើរយ៉ាងកក់ក្តៅបំផុត" ជូនដល់ការតែងតាំងរបស់ ហ៊ុន សែន ដែលក្រោយមកបានបកស្រាយថាជា "ភាសាគួរសម" តែនៅបន្តរការប្រយុទ្ធដដែល (ខេមបូឌាដេលី០៦.៦.១៥)។

ថ្ងៃ៨មិថុនា នាយករដ្ឋមន្ត្រី ហ៊ុន សែន បង្ករឿងជាមួយ សម រង្ស៊ី ថា "បើការបោះឆ្នោតឆ្នាំ២០១៣វាបន្លំមែន តទៅទំព័រទី ២៥



# វិធីសាស្ត្រផ្សេងៗដើម្បីថែរក្សាភ្នែកលោកអ្នកនៅមុខកញ្ចក់កុំព្យូទ័រ



សព្វថ្ងៃនេះការប្រើប្រាស់កុំព្យូទ័រ គឺជាវិធីមួយដែលអាចជួយសម្រួលដល់ការងារបានច្រើនយ៉ាង និងកំពុងតែពេញនិយមចំពោះមនុស្សនៅលើសាកលលោកយើងនេះ ។ ថ្វីដ្បិតតែកុំព្យូទ័រមានសារប្រយោជន៍ច្រើនសម្រាប់មនុស្សយើងក៏ពិតមែន តែវាក៏ផ្តល់គុណវិបត្តិមួយចំនួនធំដល់សុខភាពភ្នែករបស់មនុស្សយើងដែរ។ ខាងក្រោមនេះ គឺជាសេចក្តីណែនាំរបស់លោកវេជ្ជបណ្ឌិត ងី ម៉េង ជាប្រធានកម្មវិធីជាតិសុខភាពភ្នែកតាមរយៈកោះសន្និភាពអំពីការថែរក្សាភ្នែកនៅពេលដែលលោកអ្នកប្រើប្រាស់កុំព្យូទ័រ ។

កត្តាដែលនាំឱ្យលោកអ្នកកើតមានបញ្ហាចំពោះភ្នែកបណ្តាលមកពីកុំព្យូទ័រមានដូចជា ៖

-កុំព្យូទ័រគឺមានពន្លឺ ដែលជះចេញពីអក្សរឬរូបភាពផ្សេងៗ ជួនកាលអក្សរទាំងនោះវាមិនសូវច្បាស់ ដូចនេះលោកអ្នកក៏ខំប្រឹងសម្លឹងមើល ហើយពន្លឺដែលជះចេញពីកុំព្យូទ័រអាចបង្កឱ្យមានបញ្ហាចំពោះភ្នែក ។

-ការប្រើប្រាស់កុំព្យូទ័រយូរនៅនឹងមុខកុំព្យូទ័ររហូត និងជារៀងរាល់ម៉ោងធ្វើការងារជាពិសេស គឺអ្នកវាយអត្ថបទ ។

-ជាធម្មតាចលនាភ្នែករបស់មនុស្សយើងម្នាក់ៗតែងតែធ្វើចលនាចុះឡើងៗជានិច្ច ដូចនេះនៅពេលដែលលោកអ្នកនាងកញ្ញាខំប្រឹងសម្លឹងមើលកុំព្យូទ័រយូរអាចធ្វើឱ្យភ្នែកបន្ថយនូវការធ្វើចលនាដោយគិតតែពីសម្លឹងមើល ហើយមិនបានព្រិចភ្នែកជាហេតុអាចបង្កឱ្យភ្នែកមានបញ្ហា ។

លោកវេជ្ជបណ្ឌិត ងី ម៉េង បានមានប្រសាសន៍ឱ្យដឹងទៀតថា រោគសញ្ញាដែលអាចបញ្ជាក់ថា លោកអ្នកកំពុងតែមានបញ្ហាភ្នែកនៅពេលដែលប្រើប្រាស់កុំព្យូទ័រដោយលោកអ្នកអាចវិភាគដឹងដោយខ្លួនឯងនោះមានដូចជា ៖

-ភ្នែកចុករោយ ចុកគ្រាប់ភ្នែកនៅពេលដែលលោកអ្នកសម្លឹងមើលកុំព្យូទ័រច្រើនម៉ោង ។

-ជាធម្មតានៅពេលដែលលោកអ្នកនាងកញ្ញាមើលកុំព្យូទ័រច្រើនអាចបណ្តាលឱ្យស្ងួតភ្នែក ព្រោះភ្នែករបស់មនុស្សយើងម្នាក់ៗតែងតែមានទឹកភ្នែកដែលធ្វើឱ្យសើម និងរអិលជាប់ជាប្រចាំ ដូចនេះនៅពេលដែលលោក អ្នកខំប្រឹងសម្លឹងមើល ហើយ មិនបានព្រិចភ្នែកជាហេតុដែលអាចធ្វើឱ្យភ្នែកស្ងួត ហើយលោកអ្នក អាចមានអារម្មណ៍ថាភ្នែក ស្ងួត ឬក៏ក្រហាយផ្សាៗជាដើម ។

-កាលណាលោកអ្នកសម្លឹងមើលកុំព្យូទ័រយូរពេកក៏អាចធ្វើឱ្យស្រវាំងភ្នែក និងអាចធ្វើឱ្យឈឺក្បាល ឬរោយកជាដើម ។ដូច្នេះហើយ ដើម្បីការពារកុំឱ្យកើតមានបញ្ហាទាំងនេះ លោកអ្នកត្រូវតែយកចិត្តទុកដាក់នៅក្នុងការថែរក្សាភ្នែកឱ្យបានដិតដល់។ ចំណែកឯការថែរក្សាភ្នែកនៅមុខកញ្ចក់កុំព្យូទ័រនេះវាមិនមែនជាការលំបាកទេដោយគ្រាន់តែលោកអ្នកអនុវត្តទៅតាមវិធីខាងក្រោមដូចជា ៖

-ត្រូវមានពេលសម្រាកមិនត្រូវសម្លឹងមើលយូរពេកទេ ដោយត្រូវមើល១៥នាទី ២០នាទីត្រូវងាកចេញទៅមើលអ្វីផ្សេងក្រៅពីកុំព្យូទ័រ ។

-នៅពេលមើលកុំព្យូទ័រត្រូវពង្រីកតួអក្សរឱ្យធំៗ និងច្បាស់ដើម្បីកុំឱ្យពិបាកនៅក្នុងការសម្លឹងមើល ជាពិសេសត្រូវបន្ថយពន្លឺកុំឱ្យភ្លឺខ្លាំងពេក ។

-ត្រូវឧស្សាហ៍ព្រិចភ្នែកកុំ ឱ្យភ្នែកស្ងួត ។

-ត្រូវដាក់កុំព្យូទ័រឱ្យនៅឆ្ងាយពីលោកអ្នកយ៉ាងតិចឱ្យបាន៣០សង់ទីម៉ែត្រ ។

-ត្រូវមានថ្នាំសម្រាប់បន្តក់ភ្នែកនៅពេលដែលលោកអ្នកកិតថា ភ្នែកលោកអ្នកមានបញ្ហា ហើយថ្នាំសម្រាប់បន្តក់ភ្នែកនោះក៏ត្រូវតែមានការណែនាំពីគ្រូពេទ្យជំនាញផងដែរ ទើបការប្រើប្រាស់មានប្រសិទ្ធភាព ។

-ជាងនេះទៅទៀតនោះចំពោះលោកអ្នកដែលជ្រើសរើសប្រើប្រាស់កញ្ចក់វែនតាជាមួយនឹងកុំព្យូទ័រ គឺត្រូវតែវាស់ភ្នែកឱ្យបានត្រឹមត្រូវ និងស្របតាមឪក្រេរបស់ភ្នែក ។

-បើសិនជាកាលណាលោកអ្នកដែលមានបញ្ហាភ្នែកដែលបណ្តាលមកពីកុំព្យូទ័រដូចជាចុករោយភ្នែក ក្រហាយភ្នែក ឬឈឺក្បាល នៅពេលដែលមើលកុំព្យូទ័រនោះ លោកអ្នកនាងកញ្ញាគួរតែទៅពិភាក្សាជាមួយគ្រូពេទ្យឯកទេស ដើម្បីឱ្យគ្រូពេទ្យពិនិត្យមើលទើបជាការប្រសើរ។ ទាំងនោះ គឺជាវិធីសាស្ត្រដែលអាចជួយឱ្យភ្នែករបស់លោកអ្នកមានសុខភាពល្អមិនមានបញ្ហានៅពេលដែលលោកប្រើប្រាស់កុំព្យូទ័រ ៕

MARCOTTE LAW FIRM
ក្រុមហ៊ុនមេធាវី Marcotte
45 MERRIMACK STREET
LOWELL, MASSACHUSETTS
(978) 458-1229
●សេចក្តីអន្តរាយដល់បុគ្គល
●ច្បាប់ធានារ៉ាប់រង
●សំណងបុគ្គល
●ការរំលោភបទព្រហ្មទណ្ឌ
●ពិការភាពដោយសន្តិសុខសង្គម
●គ្រោះថ្នាក់ចរាចរណ៍
●បទព្រហ្មទណ្ឌផ្លូវភេទ និងថ្នាំញៀន
●គ្រោះថ្នាក់នៅការដ្ឋាន
●ច្បាប់គ្រួសារ និងផែនការអចលនទ្រព្យ
●បំណុលអចលទ្រព្យ
●បណ្តឹងវិវាទទូទៅ
●បើកបរនៅពេលស្រវឹង និងប្រព្រឹត្តបទល្មើសពេលធ្វើចរាចរណ៍
មានបុគ្គលិកនិយាយភាសាខ្មែរលោកអ្នកអាចហៅទូរស័ព្ទមកក្រុមហ៊ុនយើងខ្ញុំដើម្បីពិគ្រោះ
(978) 458-1229
www.marcottelawfirm.com

"អត្ថបទទស្សនៈ ថវិការគ្រួសារជាអ្វី?"

# និយាយពីក្រ និងមាន

## ភាគ២ - ការពារសេដ្ឋកិច្ចគ្រួសារ

**ដោយ ពិន សំខុន**



ពិន សំខុន

រស់នៅជាពលរដ្ឋថ្លៃថ្នូរនឹងមានសិទ្ធគ្រប់គ្រាន់ តម្រូវឱ្យមនុស្សមានការងារធ្វើមានប្រាក់"ចំណូល" ជួនកាលនៅក្នុងផ្ទះតែមួយត្រូវមានមនុស្ស២-ឬច្រើននាក់មានប្រាក់ចំណូល ទើបគ្រប់គ្រាន់ចំណាយក្នុងផ្ទះ ។

**ប្រាក់ចំណាយៈ** អ្នកធ្វើការយកប្រាក់ខែនាំចំណូលមួយចំនួនមកផ្ទះបន្ទាប់ពីក្រុមហ៊ុនគេកាត់ ១-ប្រាក់ធានាជម្ងឺក្នុងគ្រួសារ ២-កាត់ប្រាក់ធានាការងារធ្វើ ៣-កាត់ប្រាក់ចូលនិវត្តន៍ ៤-កាត់ប្រាក់សន្សំសម្រាប់អ្នកស្ម័គ្រចិត្តមាន៤០១គ ៥-កាត់ពន្ធប្រចាំខែលើប្រាក់ចំណូលដែលត្រូវទូទាត់ប្រចាំឆ្នាំ។ ជាទូទៅប្រាក់ដែលគេកាត់យកទៅនោះមានតម្លៃស្មើនឹង២០ភាគរយនៃប្រាក់ប្រចាំខែ។ ការកាត់យកស្របច្បាប់លើប្រាក់ខែដែលនិយោជិកម្នាក់ៗរកបាន គឺជាការចូលរួមរបស់ពលរដ្ឋម្នាក់ក្នុងចលនារបស់ប្រទេស ដើម្បីទប់ស្កាត់កុំឱ្យសង្គមមនុស្សធ្លាក់ក្នុងភាពក្រីក្រទាបជាងកំរិតដែលគេបានកំណត់ទុក ។ ចំណែកប្រាក់ដែលនៅសល់បន្ទាប់ពីកាត់ស្របច្បាប់ទី១រួចហើយ គ្រួសារនិមួយៗអាចយកមកប្រើប្រាស់ដោយសេរីតែសេរីភាពនោះ ក៏តម្រូវចាយនៅលើភាពចាំបាច់មួយចំនួនផ្សេងទៀត បែងចែកទៅចំណាយប្រចាំខែមាន ១-ថ្លៃឈ្នួលផ្ទះ ២-ថ្លៃម្ហូបអាហារ ៣-ថ្លៃឈ្នួលទិញឡាន ៤-ថ្លៃប្រើភ្លើង ៥-ថ្លៃប្រើទឹកស្អាត ៦-ថ្លៃឈ្នួលប្រើទូស័ព្ទ ៧-ថ្លៃឈ្នួលប្រើទូរទស្សន៍ ៨-ថ្លៃឈ្នួលប្រើអិនធឺណិត ៩-ថ្លៃសាលាកូន ១០-ថ្លៃឈ្នួលដឹកសម្រាមចោល... នៅមានចំណាយប្រចាំឆ្នាំដូចជា ១១-បង់ពន្ធក្រុងនឹងរដ្ឋលើប្រាក់រកបាន ១២-បង់ពន្ធក្រុងលើសម្បត្តិដែលមានដូចជាមានឡានមានផ្ទះមានដី...។ ការចាំបាច់ច្រើនទៀត ក៏ត្រូវតែចំណាយប្រចាំជីវិត ដូចជា ១៣-ទៅវិស្សមកាល១ឆ្នាំម្តង ១៤-ទិញសំលៀកបំពាក់សម្រាប់គ្រួសារ ១៥-ចំណាយ ធ្វើបុណ្យខួប ឬកំណើតក្នុងគ្រួសារ ១៦-ត្រៀមសម្រាប់ចូលបុណ្យមិត្តភ័ក្រ្តម្តងៗ ១៧-នៅមានការរកមធ្យោបាយសន្សំដាក់កូនជ្រូកឱ្យបានខ្លះថែមទៀត...។





ចំណាយដ៏ច្រើនមុខ ម្លឹងៗ តើប្រាក់ចំណូលនោះ នឹងគ្រប់គ្រាន់ដែរ ឬទេ? ជាទូទៅមិនគ្រប់គ្រាន់ទេ! ដូច្នេះគេត្រូវតែបរិច្ចាកលើភាពគ្រប់គ្រាន់នោះខ្លះហើយ ដូចជាចែករំលែកបន្ទប់ដេកសម្រាប់ច្រើនគ្នាធ្វើម្ហូបអាហាររួមជិះឡានរួមគ្នាទៅធ្វើការកាត់វិស្សមកាលចោល ។ ទាំងនេះយើងមិននិយាយពីអ្នកញៀន ជក់បារី កាហ្វេ សុរា ដែលច្រើនអាទិភាពលើគ្រឿងញៀនច្រើនជាងគ្រឿងចាំបាច់នៅក្នុងផ្ទះទៅវិញផង។

**ប្រាក់ចំណូលៈ** ក្រៅពីអ្នកទៅធ្វើការ៨ម៉ោងក្នុង១ថ្ងៃនៅមានអ្នកខ្លះឆ្លាតគ្រាន់បើនៅសល់ពេលទំនេរខ្លះ ក៏ទៅរកការងារទី២ ទី៣ មកធ្វើបន្ថែមបង្កើនបានជាប្រាក់ "ចំណូលបន្ថែម" គួរឱ្យចាប់អារម្មណ៍ ។ ពេលទំនេរនោះបានមកពីគេធ្វើការពេលព្រឹក (ពីម៉ោង៧ព្រឹក-៣ល្ងាច) នៅសល់ពេលល្ងាចទំនេរទៅធ្វើការនៅកន្លែងមួយទៀត (ពីម៉ោង៥រសៀល-៩យប់) នៅសល់ពេល៨-៩ម៉ោងសម្រាប់ដំណេកនឹងបានសម្រាកថ្ងៃសៅរ៍ នឹងអាទិត្យដែរ។ ជាគោលការណ៍ គេគ្រោងពេលវេលាសម្រាប់ជីវភាពក្នុងមួយថ្ងៃ គឺ ៨ម៉ោងសម្រាប់ដេក៨ម៉ោងសម្រាប់គ្រួសារ ៨ម៉ោងសម្រាប់កាងារ ។ ប្រាក់ចំណូលដែលទាបបំផុតស្របច្បាប់ប្រមាន២ម៉ឺនក្នុងមួយឆ្នាំ ហើយការងារនោះ ។ អ្នកដែលមានជីវភាពតិចជាងកំរិតតិចបំផុតនោះ អាចទៅរាយការណ៍ប្រាប់ក្រសួងសង្គមកិច្ចដែលអាចជួយពលរដ្ឋជាលុយម្ហូប ឬជាលុយបន្ថែមមិនឱ្យធ្លាក់ទៅក្នុងសភាពតោកយ៉ាកទេ។ រីឯអ្នកដែលមានស្មារតីរឹងមាំប្រាជ្ញាខ្ពស់ពូកែររកលុយទៅវិញ ក៏អាចមានលទ្ធភាពរកប្រាក់ចំណូលបានដោយគ្មានកំរិតណាកំណត់ឱ្យឈប់ទេ... ពាក្យថា "មូលធននិយម" គឺជាពាក្យលើកដំកើងមនុស្សនឹងលើកដំកើងអ្នកពូកែររកលុយដោយគតិច្បាប់មិនដូចអត្ថន័យផ្ទុយគ្នានៅប្រទេសកុម្មុយនីស្តនោះទេ៕


AccuCare Home Care Agency
Group Adults Foster Care Program

Homecare Agency
Group Adult Foster Care Program (GAFC)
MassHealth

កម្មវិធីជំនួយផ្នែកថែទាំសុខភាពតាមផ្ទះរដ្ឋ

ជាសេវាមានគុណភាពខ្ពស់ និងទុកចិត្តបាន
បុគ្គលិកមានសណ្តានចិត្តល្អ និងធ្វើការតាមវិជ្ជាជីវៈ
អ្នកគ្រប់គ្រង និងបុគ្គលិកនិយាយភាសាខ្មែរ



Compassionate Care & Reliable
Professional & Cultural Sensitive
Management & Staffs speak Khmer

កម្មវិធី Group Adult Foster Care (GAFC) គឺជាដំណោះស្រាយល្អបំផុតសំរាប់ចាស់ៗ ខ្មែរយើង ដែលមានប ញ្ហាវាំវែផែកសុខភាព ឬជរាហើយមិនចង់ ចាកចេញពីលំនៅដ្ឋានខ្លួនឯង ឬមិនចង់បែកពីក្រុមគ្រួសារដែលបានរស់នៅជាមួយគ្នាជាយូរមកហើយ ។ យើងអាចជួយអោយជីវិតលោកអ្នកកាន់តែប្រសើរឡើង តាមរយៈការផ្តល់នូវសេវាថែទាំសុខភាពមួយទល់មួយដល់ផ្ទះលោកអ្នកតែម្តង ។

Accucare Homecare Agency is the perfect solution for seniors and others who are not ready to leave their home for an institutional setting or live with reltives because of illness or chronic conditions. We improve your life by providing one-on-one compassionate senior care in the comfort of your own home.

ដើម្បីអាចចូលរួមក្នុងកម្មវិធីនេះបានលោកអ្នកត្រូវមានលក្ខណៈដូចខាងក្រោម :
To be eligibled for GAFC you must:
-រស់នៅផ្ទះរដ្ឋ (live in subsidized or public housing)
-អាយុ ២២ ឆ្នាំឡើងទៅ (age 22 years and older)
-មាស់ហែលស្តង់ដា (eligible for Masshealth Standard)
-ត្រូវការជំនួយក្នុងការរស់នៅប្រចាំថ្ងៃយ៉ាងហោចណាស់មួយដូចជា មុជទឹក ស្លៀក-ពាក់ ពេលប្រើបន្ទប់ទឹក ចំអិនអាហារ ឬ ពេលដើរ (need daily assistance with one or more personal care tasks such as bathing, dressing, toileting, meal preparation and/or moving)
-មានការអនុញ្ញាតពីគ្រូពេទ្យផ្ទាល់ខ្លួនអ្នក (have physician statement of your condition)
-ត្រូវបានវាយតំលៃផ្នែកសុខភាព នឹងការអនុម័តយល់ព្រមពីកម្មវិធី (be screened and approved for the program )

ផលប្រយោជន៍ទទួលបាន :
Benefits you will get:
-ការថែទាំផ្ទាល់ខ្លួនមួយទល់មួយក្នុងផ្ទះរបស់អ្នករាល់ថ្ងៃមួយថ្ងៃមួយម៉ោងលើការរស់នៅប្រចាំថ្ងៃ (personal care service in your home, up to one hour of service each day)
-ជំនួយលើការគ្រប់គ្រងថ្នាំសង្កូវអ្នក (Medication Managemant)
-ផែនការថែរទាំសុខភាពផ្ទាល់ខ្លួនមួយ ដែលធ្វើឡើងដោយគ្រូពេទ្យ និងខេសមានីយើ (an individual care plan developed by a registered nurse and case manager)
-វាយតំលៃលើសេចក្តីត្រូវការជាប្រចាំជាបន្តបន្ទាប់ (ongoing monitoring of needs)
-សមាជិកអាចទាក់ទងមក ២៤ម៉ោង (24-hour access to services)

ត្រូវការជ្រើសរើសបុគ្គលិកធ្វើការ PCA/ HHA needed
for Lowell, Lynn, Revere, and Boston

ដើម្បីចុះឈ្មោះសូមទាក់ទងមក
To register, please contact:

ឱក តុលាយុត្តិ ឡូវែល
Tolayuth Ok: Lowell
Tel: (978)735-4955, Fax: (978) 735-4956
Office: 144 Merrimack St., Suite 404. Lowell, MA 01852

# វិធីខាត់ស្បែកដងខ្លួនឱ្យស្រស់ស្អាត





កម្តៅថ្ងៃដែលពោរពេញដោយថាមពលនៃការបផ្លាញស្បែកមិនត្រឹមតែស្បែកមុខដែលត្រូវការថែទាំស្បែកដងខ្លួន ក៏ត្រូវការយកចិត្តទុកដាក់ដែរ ។ បើចង់មានស្បែកកាយ សថ្លា គ្មានភាពខ្មៅស្រអាប់នោះ អាចសាកល្បងនូវវិធីខាត់ស្បែក...

**- ខាត់ដោយវិតាមីន C**

បន្ថែមភាពសថ្លាដល់ស្បែកដោយវិតាមីនដោយយកអំបិលសមុទ្រ កន្លះចានចង្កឹះ ស្ករស ១,៣ ចានចង្កឹះ ប្រេងដូង កន្លះចានចង្កឹះ និងទឹកក្រូចច្របាច់ប្រមាណ ៣០ តំណក់ មកផ្សំចូលគ្នា ហើយបើចង់ឱ្យអារម្មណ៍ធូរស្រាលអាចបន្តក់ប្រេងក្រអូប ១ ស្លាបព្រាបាយ យកមកដុសខាត់ឱ្យសព្វរាងកាយ ជាការស្រេច ។ រូបមន្តនេះ មិនត្រឹមតែជួយឱ្យស្ត្រីមានស្បែកសស្រស់ថ្លាទេ ប៉ុន្តែបានជួយបន្ថែមខូលឡាចេនដល់ស្បែកធ្វើឱ្យស្បែកស និងទន់ម៉ដ្ឋទៀតផង ។

**- ខាត់ដោយទឹកក្រូចឆ្មារ**

សម្រាប់ស្ត្រីដែលមានបញ្ហារឿងមុនកើតនៅខ្នងសូមណែនាំរូមន្តក្រូចឆ្មារ ដែលសម្បូរដោយថាមពលនៃការសម្លាប់មេរោគដែលជួយឱ្យអ្នកបង្ហាញស្បែកកាយដែលសថ្លា គ្មានមុនដោយគ្រាន់តែ ចាក់ស្ករស ២ចានចង្កឹះ ចូលក្នុងចាន ដែលត្រៀមទុក ។ ថែមប្រេងដូង ១,៤ចានចង្កឹះ ទឹកក្រូចឆ្មារ ១ស្លាបព្រាបាយ ទឹកឃ្មុំ កន្លះស្លាបព្រាបាយ និងទឹកខ្មេះធ្វើពីផ្លែប៉ោម ប្រមាណ ១ស្លាបព្រាកាហ្វេ កូរបញ្ចូលគ្នាឱ្យសព្វរួចឧស្សាហ៍ ខាត់ស្បែកជាប្រចាំនោះអ្នកនឹងឃើញលទ្ធផល ។

**- ខាត់វ៉ានីឡាអាល់ម៉ុនដ**

បើចង់មានស្បែកទន់តឹងណែនដូចស្បែកទារកត្រូវយកស្កតសកន្លះចានចង្កឹះ រួចកូរបញ្ចូលគ្នា យកផ្លែវ៉ានីឡា មកកោសយកតែគ្រាប់ដាក់ចូលថែមប្រមាណ២ស្លាបព្រាកាហ្វេ រួចកូរបញ្ចូលគ្នា ។ គុណប្រយោជន៍ពីប្រេងអាលម៉ុនដ៍ និងវ៉ានីឡាជួយរក្សាសំណើមដល់ស្បែកបានយូរអង្វែងពេលប្រើជាប្រចាំ ។

**- ខាត់ដោយក្លែបផ្កាកុលាប**

យកប្រេងដូង១ចានចង្កឹះមកលាយជាមួយស្រទាប់ផ្កាកុលាប កន្លះចានចង្កឹះ ស្ករស កន្លះចានចង្កឹះ និងប្រេងអាល់ម៉ុនដ៍ កន្លះចានចង្កឹះ រួចកូរបញ្ចូលគ្នា ទុកចោលប្រមាណ ១៥-២០នាទីឱ្យជាតិប្រេងជ្រាបចូលស្រទាប់ផ្កាកុលាបសិន សឹមយកមកខាត់ស្បែកឱ្យសព្វរាងកាយ ។ ស្រទាប់ផ្កាកុលាបសម្បូរដោយគុណប្រយោជន៍ក្នុងការសម្អាតស្បែកជួយបន្ថយ ការកើតមុនព្រមជាមួយសារធាតុប្រឆាំងរ៉ាឌីកាល់សេរីដែលធ្វើឱ្យស្បែកស្រស់ថ្លា ថែមទាំងមានសំណើម ព្រោះដោយសារគុណប្រយោជន៍ពីប្រេងដូង និងប្រេងអាល់ម៉ុនដ៍ ។

**-ខាត់ដោយចេកអំបូង**

សាកល្បងយកចេកអំបូងមកហាន់ជាចំណិតផ្សំជាមួយស្ករស២ស្លាបព្រាបាយប្រើដៃ ឬស្លាបព្រាច្របាច់ឱ្យចេកបែកជាសាច់តែមួយជាមួយស្ករសឹមថែមសារធាតុចម្រាញ់ពីវ៉ានីឡាកន្លះស្លាបព្រាកាហ្វេ កូរបញ្ចូលគ្នាមួយសាទៀតយកមកខាត់ស្បែកកាយជាប្រចាំនោះ អ្នកនឹងមានអារម្មណ៍ថា ស្បែកទន់ម៉ដ្ឋ គ្មានស្នាមជ្រីវជ្រួញ ។ រូបមន្តនេះ អាចយកមកធ្វើជាវិធីខាត់ស្បែកមុខបានគ្រាន់តែបន្ថយបរិមាណជាតិស្ករឱ្យតិចរួចប្រើចុងម្រាមដៃម៉ាស្សាថ្នម ។ លើកសែងបរិវេណភ្នែករួចលាងសម្អាតដោយទឹកក្តៅឧណ្ហៗនោះ អ្នកនឹងបានផ្ទៃមុខទន់ម៉ដ្ឋមិនខាន ៕

តមកពីទំព័រទី ២២ **រំលឹកព័ត៌មានពីថ្ងៃ ២៧ ឧសភា...**

ដូចដែលគាត់ចេះតែបន្តនិយាយនោះ ត្រូវតែហ៊ានមកស្បត់នៅមុខព្រះអង្គដងកើ (អ្នកតាដំបូកែនៅមុខវាំង)ឱ្យរន្ទះបាញ់ត្រូវគ្រាប់ត្រូវរបួសនឹងស្លាប់ទណ្ឌហន្ត។ សម រង្ស៊ី នៅពេលត្រឡប់ពិបរទេសវិញ ទទួលយកការបង្ករឿងដោយបន្ថែមថា បើរាប់សន្លឹកឆ្នោតទៅវាមានប្រសិទ្ធភាពជាង (ខេមបូឌាដេលី១១.៦.១៥) ។

ថ្ងៃ៩មិថុនា ព្រះមហាក្សត្រ សីហមុនី បានលើកលែងទោសឱ្យ សួន សេរីរដ្ឋា មានទោសជាប់គុក៧ឆ្នាំ ដោយការចោទប្រកាន់"ភរវកម្ម" កាលពីឱកាសបោះឆ្នោតលើកមុន ហើយបានគេចខ្លួនតាំងពីពេលនោះមក ឥឡូវនេះបានទទួលការអនុញ្ញាតឱ្យបង្កើតគណបក្សនយោបាយមួយមានឈ្មោះថា "គណបក្សអំណាចប្រជាពលរដ្ឋខ្មែរ" (MPPM) ។ ១២ មិថុនា ម៉ម សុណាន់ដូ ប្រកាសបំណងបង្កើតគណបក្សនយោបាយមួយឈ្មោះ "គណបក្សសង្គមប្រជាធិបតេយ្យ-សំបុកឃ្មុំ" (ខេមបូឌាដេលី១៣.៦. ១៥) ...នេះគឺស្វាគមន៍ ចំពោះអ្វីទាំងអស់ដែលបំបែកគណបក្សប្រឆាំង (ខេមបូឌាដេលី១៣.៦.១៥) ថ្ងៃ២២ មិថុនា សហភាពអឺរ៉ុប សន្យាផ្តល់ថវិការ១១លានដុល្លារដល់គ.ជ.ប. ដើម្បីរៀបចំបញ្ជីបោះឆ្នោតឆ្នាំ២០១៧-១៨ (ខេមបូឌាដេលី ២៣.៦.១៥)

**(ប្រែសម្រួលពីភាសាបារាំងដោយខ្មែរផុសស.រ.អា.)**


**KhmerPost USA, LLC**

**សារពត៌មានខ្មែរផុសសហរដ្ឋអាមេរិក**

អាស័យដ្ឋាន 45 Merrimack St. Suite 218A. Lowell, MA 01852

លេខទូរស័ព្ទ Phone: 978 677-7163 | Fax: (978) 677-7092

អ៊ីម៉ែល info@khmerpost.us

អានកាសែតនៅគេហទំព័រ www.khmerpost.us

តាមដានយើងនៅទំព័រហ្វេសប៊ុក Like us at: www.facebook.com/KhmerPostUSA

**ផ្សាយពាណិជ្ជកម្ម Advertising**

អគ្គនាយកទីផ្សារ និងគ្រប់គ្រង សុបិន្ត ពិន Soben Pin, *Managing Partner*

លេខទូរស័ព្ទ 978 - 656 - 8141 (Mobile) 978 677-7163 (Office)

អ៊ីម៉ែលsobenpin@khmerpost.us

**អ្នកនិពន្ធ Editorials**

និពន្ធនាយក ពិន សំខុន Roger Samkhon Pin, *Publisher & Editor-in-Chief*

(978) 942 - 1641 | rogerpin@khmerpost.us

អ្នកនិពន្ធកិត្តិយស **Contributed Writers:**

Kim Phien, Richard Howe,Jr.

**ច្នៃសោភ័ណភាពកាសែត Design Artist**

Heng Chhunleng

នាយករដ្ឋបាល Office Manager **978-677-7163**

Thach Vanna ថាច់ វណ្ណា

KhmerPost USA, LLC is an independent newspaper that aims to facilitate mass communication among the Cambodian communities, their neighboring communities, and families. We aim to address local community, and national news; and give an insight into Cambodian & global news. We also strive to bridge the language and cultural gaps and reduce social isolation by publishing in Khmer & English. It published twice a month in Massachusetts serving Greater Lowell, Lynn, Revere, MA, Providence, RI, CT, NY, NJ, and Philadelphia, PA.

Mail subscription is available within the U.S. & Canada at 100.00 or 120 Euros in Europe per year.

The KhmerPost USA has full authorization from Bernard Krisher, the publisher of the Cambodia Daily to reproduce all the articles that are produced by the Cambodia Daily free of charge effective date: 6/19/2009

# ទូលព្រះបង្គំមិនហ៊ានរាយការណ៍ទេ ទាន ! (តពីភាគ៤)

**ដោយ : បញ្ញ សិលា** **តពីលេខមុន**



...ទូលព្រះបង្គំយើងខ្ញុំមិនអាចបន្តការស្នាក់នៅនឹងបង់ថ្លៃសេវាកម្មផ្សេងៗបានទៀតទេទាន, ព្រោះកិរិតតម្លៃឆ្នាំនេះឡើងជាងពីឆ្នាំមុនទ្វេជា១០-២០ដងឯណោះ។ រកបានបន្តិចបន្តួចនៅឯឋានក្រោមមកដល់ឋាននាយត្រូវបង់សេវាកម្មដឹកជញ្ជូនតាមតម្លៃម៉ាក្សេណ្សូរសឹងដាច់ខ្យល់ស្លាប់ទៅហើយមកជួបនឹងតម្លៃទ្វេគុណជាច្រើនដងរាប់មិនឈ្នះនៅឋាននេះទៀត ទូលព្រះបង្គំយើងខ្ញុំត្រឡប់ទៅផែនដីវិញបានស្អីច្រះច្រំលក់កេរអាករទាំងអស់សងបំណុលគេសឹងមិនរួចរកផ្ទះនៅមិនបានប្រពន្ធកូនចៅមុខតែត្រូវជ្រកនៅតាមសំយាបផ្ទះគេមិនខាន....”។ សម្លេងតបវិញហាក់ដូចមានសេចក្តីក្រោធលាយឡំធ្វើឱ្យយើងដឹងថា នោះជាវាចារតបរបស់ទេពអគ្គលេខាៈ ”អវសោឯងជានរណា? អ្នកណាហៅឱ្យមក? ហេតុអីទើបត្រូវមកឋានយើងនេះ?...”។ សម្លេងតបវិញហាក់ដូចបាក់អំនួតអស់រលីងៈ ”សូមព្រះអង្គមេត្តាសន្តោសប្រោសប្រណីទូលបង្គំជាអនុរក្សថែរក្សាផែនដីគោកធ្លោកនគរសុវណ្ណភូមិទូលបង្គំមកទីនេះដោយបំណងផ្ទាល់ខ្លួនតែប៉ុណ្ណោះ គឺទូលបង្គំសុំយកដង្វាយមកថ្វាយព្រះអង្គពេលមកដល់ភ្លាមនោះព្រះអង្គបានទទួលរួចមកហើយផងដែរ គឺទូលបង្គំសុំព្រះអង្គមេត្តាជួយបញ្ចៀសគ្រោះភ័យដែលនឹងកើតមានឡើងនៅដំណាច់ឆ្នាំនេះ គឺទូលបង្គំមកគិតគូរជាមួយព្រះអង្គឱ្យបានមុនកុំឱ្យខកការសូមទានជ្រាប!”។ ព្រះទេពអគ្គលេខាបន្តទៅទៀតៈ ”បើដឹងខ្លួនថា ត្រូវមកពឹងពាក់ឱ្យយើងជួយម្តេចក៏សំដីធ្លោះៗម្លេះ? ត្រូវដឹងថា យើងមិនបានពឹងឱ្យអ្នករាល់គ្នាមកជួបយើងទេ! យើងគ្មានឱ្យអ្នករាល់គ្នាយកដង្វាយមកថ្វាយនាំយើងឱ្យក្លាយជាដំណាងទេព្តាពុករលួយអយុត្តិធមិខូចសីលធមិក្រិតក្រំនៃលោកដ៏ជាទីអរិយ៍ស្ងប់សុខនេះឡើយ! តើអ្នករាល់គ្នាបានដឹងខ្លួនថា បានប្រព្រឹតរំលោភបំពានទូវគតិច្បាប់ទីនេះយ៉ាងធ្ងន់ធ្ងរដែលមិនអាចអត់ឱនឱ្យបានេះ ឬទេ? បើអ្នករាល់គ្នាទ្រាំមិនបាននឹងសេវាកម្មផ្សេងៗនៅទីនេះទេ អ្នករាល់គ្នាអាចត្រឡប់ទៅផែនដីគោកធ្លោកសុវណ្ណភូមិវិញដោយសេរីគ្មាននរណាហាមឃាត់អ្នកទាំងអស់គ្នាទេ រួចចាំដល់ពេលព្រះសក្កទេវរាជត្រូវការកោះហៅអ្នករាល់គ្នាយើងនឹងចាត់ចែងរាជរថទៅដឹកជញ្ជូនអ្នកគ្រប់គ្នាដោយឥតគិតថ្លៃ-ហ្វ្រី អហ្វ ឆាគ! -ដែរអ្នករាល់គ្នាយល់ឬនៅ? ។ ចូរកុំចង់មកលេងល្បែងអុកឡុកធ្វើបាតុកម្មឬពហិការបំផ្លាញសេចក្តីសុខស្ងប់នាឋានដ៏ប្រសើរនេះតាមវិធីពួអ្នកមានអំណាចនៅនាភពផែនដីគាំទ្រដោយរដ្ឋាភិបាលធ្វើបាតុកម្មប្រឆាំងនឹងបាតុកម្មត្រឹមត្រូវរបស់អ្នកក្រីក្រគ្នាធ្វើឡើងដើម្បីសុំតែរស់មួយចំអែតសុំទាមទារដីកេរកម្មសិទ្ធិដែលគ្នាត្រូវគេរឹបអូសប្លន់យកទាំងកំរោលនោះឱ្យសងមកគ្នាវិញ ពួកអ្នកមានទ្រព្យមានអំណាចបានធ្វើបាតុកម្មប្រឆាំងដោយចោទប្រកាន់ថាគ្នាបានចូលរុករានដីទឹកខ្លួនដោយអាងខ្លួនឯងមានបង្កាន់ដៃឬប្លង់កម្មសិទ្ធស្របច្បាប់មកតែពីខ្លួនមានលុយមានអំណាចរួចក៏ចាប់គ្នាវាយដំដាក់ខ្នោះច្រកគុកស្រេចតែចិត្តគ្មានត្រាបណី។ ចូរកុំចង់លេងល្បែងពាលយ៉ាងនោះនៅទីនេះជាមួយទេពនិករឱ្យសោះ។ យើងព្រមទទួលដង្វាយរបស់អ្នករាល់គ្នាព្រោះយើងមិនអាចដាច់មេត្តាដែលបានឃើញអ្នករាល់គ្នាខំមកពឹងពាក់ហើយៗអត់រវល់អើពើទុកឱ្យអ្នករាល់គ្នាអស់សង្ឃឹមត្រឡប់ក្រោយបែរវាដាច់ព្រហ្មវិហារធមិពេកពួកអ្នករាល់គ្នាបែជាក្អេងក្អាងក្រអើតក្រទមយើងអស់សង្ឃឹមខ្លាំងណាស់ ចូរកុំភ្លេចថា យើងគ្មានពឹងឱ្យអ្នករាល់គ្នាធ្វើដំណើរតាមផ្លូវម៉ាក្សេរណ្សូរទេ អ្នករាល់គ្នាធ្វើអីៗដោយចិត្តឯងតែប៉ុណ្ណោះ

**តទៅលេខក្រោយ**


LOWELL ELDER CARE
978-596-1111

## មជ្ឈមណ្ឌលថែទាំមនុស្សចាស់ក្រុងឡូវែល

**345 Chelmsford St. Lowell, MA 01851/ – www.lowelleldercare.com**

### អ្វីទៅជាមណ្ឌលថែទាំមនុស្សចាស់ក្រុងឡូវែល?

គឺជាលំនៅដ្ឋានកក់ក្តៅមួយ ដែលផ្តល់សេវាមានកម្មវិធីជាក់លាក់ដល់សហគមន៍បំណង គឺគាំទ្រឲ្យមនុស្សចាស់ជរាអាចរស់នៅដោយឯករាជ្យខ្លួនឯង និងជួយឲ្យមានសុខុមាលភាពផ្នែកផ្លូវកាយ ផ្លូវចិត្ត និងផ្នែកសង្គម ។ កម្មវិធីរបស់យើងធានានូវបរិស្ថានរស់នៅមួយប្រកបដោយសុវត្ថិភាព និងមានបរិយាកាសដូចជាផ្ទះរបស់ពួកគាត់ ។

### ទីតាំងនៃមណ្ឌល

ទីតាំងអាចរកឃើញដោយងាយក្នុងអគារថ្មី ជាមួយនូវការតុបតែងរចនាបែបសិល្បៈខ្មែរយ៉ាងល្អប្រណិត ។ មានបន្ទប់ទទួលទានអាហារស្អាត និងមានពន្លឺគ្រប់គ្រាន់ បន្ទប់អានសៀវភៅ បន្ទប់កុំព្យូទ័រ បន្ទប់សម្រាក បន្ទប់មើលភាពយន្ត និងកន្លែងផ្សេងៗទៀតជាទីពេញចិត្តរបស់លោកអ្នក ។

### មណ្ឌលផ្តល់សេវាដល់មនុស្សចាស់

- មានរថយន្តជូនដំណើរទៅវិញទៅមកពីផ្ទះលោកអ្នក
- ការពិនិត្យ និងថែទាំសុខភាព
- ការព្យាបាលតាមរយៈការហាត់ប្រាណ
- កិច្ចការសង្គម (ផ្តល់ការពិគ្រោះផ្ទាល់ខ្លួន និងក្រុមគ្រួសារ)
- ម្ហូបខ្មែរក្តៅៗ និងចំណីផ្សេងៗ
- ការហាត់ប្រាណសំរាប់សុខភាពរាងកាយ
- កម្មវិធីសិល្បៈ និងតន្ត្រី
- ការអប់រំពីសុខភាព
- ការពិភាក្សាលើព្រឹត្តិការបច្ចុប្បន្ន (និងការសំណេះសំណាលគ្នា)
- សកម្មភាព និងដំណើរកំសាន្តក្រៅមណ្ឌល

### Our Services

- Door-to-Door Transportation
- Medical Care and Support
- Physical Therapy
- Social Worker
- Khmer Meals and Snacks
- Adaptive Physical Exercise
- Music Programs
- Health Educational Seminars
- Discussions on current events, (and times of reminiscing)
- Outdoor Field Trips





**សូមហៅលេខទូរស័ព្ទ (978) 596-1111**

# គ្រឿងផ្សំធម្មជាតិសំរាប់ព្យាបាលពេល ក្អក ហៀរសំបោរ !



មនុស្សគ្រប់គ្នាច្បាស់ជាដឹងពីជំងឺផ្ដាសាយ ហើយអំឡុងពេលផ្ដាសាយ ឬបន្ទាប់អ្នកច្បាស់ជាមានជួបបញ្ហាហៀរសំបោរ, កន្ដាស់, តឹងច្រមុះ, ឈឺក, ក្អក, ក្ដៅខ្លួន និងអស់កំលាំង។ និយាយពីការហៀរសំបោរវិញ មិនមែនផ្ដល់ការឈឺចាប់ឱ្យយើងនោះទេ ប៉ុន្ដែវាជាការរំខានមួយដ៏សំខាន់ដែលប៉ះពាល់ដល់ការសិក្សា ឬការងាររបស់យើង ជាពិសេសវាអាចប៉ះនឹងច្រមុះរបស់យើងខ្លាំងបំផុតរហូតដល់ថ្នាក់រលាកនៅខាងក្នុងច្រមុះចេញឈាមទៀតផង នៅពេលដែលយើងញីសសំបោរចេញមកខ្លាំងពេក ដូចនេះយើងត្រូវតែរកវិធីទប់ស្កាត់កុំឱ្យហៀរសំបោរ។

នៅពេលនេះយើងនឹងណែនាំពីរបៀបបង្កើតគ្រឿងផ្សំធម្មជាតិពិសេសមួយប្រភេទដែលប្រើប្រាស់សំរាប់ព្យាបាល និងមិនឱ្យអ្នកហៀរសំបោរបាន ដូចនេះសូមធ្វើតាមការណែនាំខាងក្រោម។

**គ្រឿងផ្សំដែលត្រូវការ :**

- ទឹកឃ្មុំ មួយស្លាបព្រា
- ខ្ទឹមសបុកឱ្យម៉ត់ កន្លះស្លាបព្រា
- ខ្ញីបុកឱ្យម៉ត់ កន្លះស្លាបព្រា
- ទឹកក្រូចឆ្មារ មួយស្លាបព្រា
- ទឹកតែក្ដៅឧណ្ហៗ មួយកែវ

បន្ទាប់ពីអ្នកបានត្រៀមគ្រឿងផ្សំទាំងនេះរួចរាល់ហើយ សូមដាក់ទឹកឃ្មុំ, ខ្ទឹមស, ខ្ញី និងទឹកក្រូចឆ្មារ ចូលទៅក្នុងទឹកតែក្ដៅឧណ្ហៗមួយកែវនោះ ហើយអ្នកអាចពិសារទឹកនេះក្នុងមួយថ្ងៃបីដងបន្ទាប់ពីពេលបាយ ឬមុនពេលចូលគេងបាន។ ដោយសារតែខ្ញីអាចធ្វើឱ្យសសៃឈាមមានដំណើរការល្អ និងធ្វើឱ្យរាងកាយមានកំដៅដូចនេះហើយអ្នកនឹងមិនហៀរសំបោរទៀតទេ ចំំណែកឯខ្ទឹមសមានអត្ថប្រយោជន៍សំរួលដល់ផ្លូវដង្ហើម ហើយចំហាយរបស់ខ្ទឹមសអាចសំអាតទងសួត និងសួតរបស់អ្នកបាន ដូចនេះវីរុសផ្ដាសាយមិនអាចនៅបានយូរនោះទេ និងអាចកាត់បន្ថយការក្អកបានទៀតផង។ ទឹកក្រូចឆ្មាអាចជំរះស្លេសនៅបំពង់ក និងទឹកឃ្មុំដើម្បីបន្ថែមឱជារសដើម្បីឱ្យអ្នកផឹកបានងាយស្រួលបន្តិច។

សរុបសេចក្ដីមក មិត្តអ្នកអានអាចប្រើប្រាស់វិធីខាងលើនេះនៅពេលដែលអ្នកហៀរសំបោរ, ឈឺក ឬនៅអំឡុងពេលផ្ដាសាយបាន។ ដោយសារតែសារធាតុទាំងនោះនឹងចូលទៅបំផ្លាញវីរុសនៃជំងឺផ្ដាសាយបានភ្លាមៗ ហើយអាចឱ្យអ្នកឆាប់ជានឹងមិនហៀរសំបោរ ឬឈឺកឡើយ៕




## តមកទំព័រទី ១៦ រដ្ឋាភិបាលបញ្ចេញសេចក្ដីព្រាងច្បាប់...

លោក អេង ឆៃអ៊ាង បានមានប្រសាសន៍ថា "សេចក្ដីសម្រេចដាក់ទណ្ឌកម្មលោក អ៊ុំ សំអាន ត្រូវបានស្នើឡើងតាមរយៈលិខិតមួយដែលយល់ព្រមដោយតំណាងរាស្ដ្រគណបក្សកាន់អំណាច៥០រូប និងយល់ព្រមដោយតំណាងរាស្ដ្រគណបក្សប្រជាជនកម្ពុជាប្រាំពីររូបក្នុងគណៈ-កម្មាធិការអចិន្ដ្រៃយ៍នេះ។

លោកបានមានប្រសាសន៍អំពីសមាជិកគណបក្សសង្គ្រោះជាតិថា "និយាយឱ្យខ្លីទៅយើងមិនបានបោះឆ្នោតគាំទ្រទេ"។

លោក អ៊ុំ សំអាន បានមានប្រសាសន៍កាលពីថ្ងៃសុក្រថា ការដាក់ទណ្ឌកម្មនេះវាធ្ងន់ជ្រុលពេក ហើយថា

លោកនឹងព្យាយាមជួបជាមួយលោក ហេង សំរិន ដើម្បី "បញ្ចប់រឿងនេះ"។

លោកបានមានប្រសាសន៍ថា "តាមពិតយើងចង់ស្វែងរកការសម្របសម្រួលនយោបាយមួយជាមួយសម្ដេច ហេង សំរិន ដើម្បីបញ្ចប់រឿងនេះ។ ពីព្រោះខ្ញុំគិតថា យើងមិនគួរឈ្លោះប្រកែកគ្នាក្នុងចំណោមខ្មែរនិងខ្មែរទេ ប៉ុន្ដែយើងចាំបាច់ត្រូវផ្ដោតលើបញ្ហាព្រំដែននៅទិសខាងជើងខាងលិច និងខាងកើត"។

លោក អ៊ុំ សំអាន រួមជាមួយតំណាងរាស្ដ្រគណបក្សសង្គ្រោះជាតិលោក រៀល ខេមរិន្ទ្រ បានដឹកនាំយុទ្ធនាការមួយនាពេលថ្មីៗនេះ ដើម្បីលើកឡើងនូវការទន្ទ្រានព្រំដែនដោយវៀតណាមដែលបានបង្កឱ្យមានបញ្ហាទំនាក់ទំនងជាសាធារណៈជាមួយរដ្ឋាភិបាលគណបក្សប្រជាជនកម្ពុជា។

ក្នុងពេលប៉ុន្មានសប្ដាហ៍ថ្មីៗនេះ ក្រសួងការបរទេសបានផ្ញើកំណត់ទូតមួយចំនួនទៅប្រទេសវៀតណាម ដោយបានស្នើសុំឱ្យវៀតណាមដកថយចេញពីទឹកដីដែលស្ថិតនៅក្នុងប្រទេសកម្ពុជា ឬកំពុងមានជម្លោះនៅឡើយ។

លោក ហ៊ុន សែន បានទទួលស្គាល់ដែលពុំធ្លាប់មានពីមុនមកថា បង្គោលមួយចំនួនតាមបណ្ដោយព្រំដែនជាមួយប្រទេសវៀតណាមអាចត្រូវបានបោះនៅខាងក្នុងទឹកដីកម្ពុជាដោយលោកបានសន្យាថា "ទាមទារឱ្យមានការកែតម្រូវ" ក្នុងករណីបែបនេះ។

នៅពេលសួរកាលពីថ្ងៃសុក្រអំពីការដាក់ទណ្ឌកម្មដែលសម្រេចចំពោះលោក អ៊ុំ សំអាន លោក ឈាង វុន អ្នកនាំពាក្យរដ្ឋសភា និងជាតំណាងរាស្ដ្រគណបក្សប្រជាជនកម្ពុជាបានមានប្រសាសន៍ថា លោកមិនចង់ពិភាក្សាអំពីបញ្ហានេះទេ។

អ្នកនាំពាក្យរូបនេះបាននិយាយថា "កុំឱ្យខ្ញុំនិយាយ។ ខ្ញុំមិនចង់និយាយទេ យល់ទេ? ស្នើសុំកុំឱ្យរញ៉េរញ៉ៃ។ ទុកឱ្យគេជួយសម្រួលស្ថានការណ៍"៕ **មានិត**

KhmerPost USA

The Cambodian-American Biweekly Newspaper

សារព័ត៌មានខ្មែរ-អាមេរិក ចេញពីរសប្តាហ៍ម្តង

a free local newspaper reaching over 20,000 Cambodian readers in the Greater Lowell area every two weeks

ផ្តល់ជូនកាសែតឥតគិតថ្លៃដល់អ្នកអានខ្មែរច្រើនជាង២០០០០នាក់នៅតំបន់ឡូវែលរាល់ពីរសប្តាហ៍ម្តង

Soben Pin, Managing Partner អ្នកគ្រប់គ្រង សុបិន្ត ពិន

978.677.7163 (Office) 978. 656.8141 (Mobile)

សូមកក់ពាណិជ្ជកម្មអ្នកជាមួយយើងខ្ញុំ ហើយទទួលបានការបញ្ចុះតម្លៃ២០%

Reserve Your 2015 Ads with us today and receive up to 20% OFF!

Sample of our affordable pricing បញ្ជីតម្លៃពាណិជ្ជកម្មក្នុងតម្លៃសមរម្យ

| ទំហំទំព័រ Page Size | ប្រវែង Length x Width | 1ខែ 1 month 10%OFF |
|---|---|---|
| 1/2 page color | (6.5"x10") | $484 |
| 1/4 page color | (6.5"x5") | $264 |
| 1/8 Classify ad | (3.25"x5") | $100 |
| Business Card | | $50 |

Our 2015 Publishing Dates កាលវិភាគបោះពុម្ព

| | |
|---|---|
| July | 10th & 24th |
| August | 7th & 21st |

*all ad materials are due one week prior to publishing date.

រាល់គំរូពាណិជ្ជកម្មត្រូវបញ្ជូន១សប្តាហ៍មុនចូលរោងពុម្ព




Call or Visit our Sales Office

45 Merrimack Street. Suite 218A. Lowell, MA 01852

Tel: 978.677.7163. Cell: 978. 656.8141 Fax: 978.677.7092

Email: sobenpin@khmerpost.us or KhmerPostUSA@gmail.com

www.khmerpost.us | www.facebook.com/KhmerPostUSA

# ទៅកម្សាន្តនឹងទេសភាព ទឹកជ្រោះជួរភ្នំជុំជិតព្រឹក្សព្រៃ “ថ្មរូង”









ហាស់ ! ហាំ... គយគន់ទឹកជ្រោះឈ្មោះនឹងថ្មដា ស្តាប់សៀងវាតា ថ្មចថ្មរខ្ចរព្រឹក្សព្រៃ ផ្អើលអស់បក្សីស្រដីខ្សៀវខ្សារ រុក្ខាមានភ័ព្វជាប់ជួរអន្លាយលើភ្នំឆើតឆាយស្រស់ស្រាយខៀវខ្ចី,មាត់អូរហូរទឹកសន្ទឹករោងស្បូវមនុស្សម្នារញូវទៅលេងផ្កាត្រែង ហាក់គ្មានចំបែងប្រឡៃងគ្នាស្និទ្ធ ទេសភាពល្អពិតដ្បិតមានប្រុស-ស្រ, ហត្ថាក្បង់ទឹកនឹកដល់កញ្ញាមុជលេងជលសាគាប់នេត្រាក្រៃមិត្តយើងឯណោះចេះចាំចរណៃកុំឃ្លូរពេកថ្លៃលែលកអាហារ...។ ទេសភាពបែបនេះ នៅឯណាមាន? គឺនៅរមណីយដ្ឋាន "ថ្មរូង"។

សូមជំរាបថា រមណីយដ្ឋាន "ថ្មរូង" ពិតជាមានទេសភាពស្រស់ត្រកាលដូចពាក្យកាព្យរៀបរាប់លើអញ្ចឹង...ប្រសិនបើយើងធ្វើដំណើរទៅកម្សាន្តទីនោះ នារដូវប្រាំងទេសភាពហាក់ក្រៀមក្រោះបន្តិច ព្រោះតែទឹកហូរតិចតួច ឯដើមឈើធំ-តូចខ្លះស្លោកស្លឹកស្រពាប់ផ្ទាំងថ្មចង្រ្កឹងនៅផ្ទឹងស្ងួតទឹកគ្មានសំឡេងរអឹកឈ្លូឆរអ្វីឡើយ ។ ប្រសិនបើទៅលេងនារដូវវស្សាវិញ ធានាថាគ្មានទុក្ខទោម្នេញនឹងបរិយាកាសទាំងឡាយនោះឡើយ ដោយសារតែធម្មជាតិស្រស់ខៀវខ្ចី មានភ្នំព្រឹក្សព្រៃព័ទ្ធជុំវិញ ទឹកជ្រោះ ទឹកអូហូរខ្លាំងៗបែកផ្កាត្រែង បង្កសំឡេងឈ្លូឆរគ្មានដាច់ខ្យល់បក់រវ្ញូៗដើមរុក្ខារេរាំ នាំក្លិនពិដោរប៉ះផាត់រាងកាយប្រុស-ស្រី សត្វស្លាបហិចហើរបង្ហើរវាចា ឮសូរខ្សៀវខ្សារគួរមេត្រីមនុស្សម្នាអ៊ូអរស្លូចិត្តកម្សាន្តរួចហើយប្រះប្រាណគេងលើអង្រឹង ។ ទីនេះមានលក់ម្ហូបអាហាររាប់សិបមុខ ត្រីដុត មានដុតសម្លម្ជូរ កកូរ ឆាអាំង ជ្រូក គោ មាន់ ទា ម្ចីម្នាតាមចិត្ត ជាពិសេសសាច់សត្វព្រៃ លែលកកុម្ម៉ង់ឆីមានឱជារស។ មានរោងស្បូវ និងក្បូសមិនខុសចិន្តា ជួលញ៉ាំអាហារមិនថ្លៃពេកទេ ទម្រេតខ្លួនប្រាណបានលើអង្រឹងធ្វើហាក់មិនដឹងមិនមានរឿងអ្វី ។ ចង់មុជទឹកលេងប្រឡៃងធម្មជាតិក៏បានមានស្រស់កល្យាណនៅក្បែរៗយើង...ស្រង់ទឹករួចរៀបចំខ្លួន សូរិយាអង្រួនជូនដល់សាយ័ណ្ហគ្មាន់គ្មេះវិលវិញ ។

គួរបញ្ជាក់ថា ទៅកាន់រមណីយដ្ឋានថ្មរូងធ្វើដំណើរតាមផ្លូវជាតិលេខ៤ រយៈចម្ងាយ១១៥ គីឡូម៉ែត្រពីរាជធានីភ្នំពេញ...ទៅហួសជ្រោះជ្រងពេជ្រនិលបន្តិចឃើញមានដាក់ស្លាកខាងស្តាំដៃ "រមណីយដ្ឋានថ្មរូង"បត់ចូលតាមផ្លូវក្រាលក្រួសក្រហមបត់បែនឡើងចុះតាមជើងភ្នំ ប៉ុន្តែមិនពិបាកទេ ប្រហែល៩គីឡូម៉ែត្រនឹងដល់រមណីយដ្ឋានហើយ ស្ថិតក្នុងស្រុកកំពង់សិលា ខេត្តព្រះសីហនុជាប់ព្រំប្រទល់ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ។







# ឱសថបុរាណ ៥យ៉ាងជួយព្យាបាលជំងឺឈឺក្បាលបានឆាប់រហ័ស



ព្យាបាលជំងឺឈឺក្បាលដោយប្រើឱសថបុរាណត្រូវបានគេដឹងថា មានប្រសិទ្ធិភាពយ៉ាងខ្លាំងបំផុត។ ចាស់ៗជំនាន់មុនមិនចាំបាច់ត្រូវការប្រើថ្នាំពេទ្យ ក៏អាចព្យាបាលជំងឺបានដែរ។ ជំងឺឈឺក្បាលជាជំងឺមួយប្រភេទដែលមនុស្សជាច្រើនតែងប្រឈមមុខ ព្រោះមានហេតុផលជាច្រើនដែលធ្វើឱ្យកើតជំងឺឈឺក្បាល ហើយក៏មានវិធីច្រើនដែរដើម្បីព្យាបាលជំងឺនេះ រួមបញ្ចូលទាំងការប្រើប្រាស់ឱសថបុរាណដ៏មានប្រសិទ្ធិភាពតាំងពីជំនាន់មុនមកម្ល៉េះ។

**វិធីទី១ :**

ស្លឹកក្រូចឃ្វិច្ប ស្លឹកផ្កាកុលាប្ប ជីក្រហម្ប ស្លឹកក្រូចឆ្មារ្ប ស្លឹកក្រូចថ្លុង មកចម្អិនយកចំហាយញើស។

**វិធីទី២ :**

ប្រើស្លឹកក្រូចថ្លុង ២សន្លឹក្ប ខ្ទឹមបារាំង ២ផ្លែ, បុកបញ្ចូលគ្នា។

**គន្លឹះសាមញ្ញ១២យ៉ាង-ដើម្បីកម្ចាត់ជំងឺឈឺក្បាល**

**វិធីទី៣ :**

ប្រើប្លាស្ទិចទ្រាប់ពីលើក្រដាស ហើយបុកផ្លែល្វា២ផ្លែលាយជាមួយទឹកចំណុះ៥មីលីលីត្រ ទទួលទានមុនពេលចូលគេង។

**វិធីទី៤:**

ព្យាបាលជំងឺឈឺមួយចំហៀងក្បាល។ ប្រើមើមស្ពៃក្រហមស្រស់ ២៥ក្រាម លាងឱ្យបានស្អាត បុកវាលាយជាមួយទឹករួចកូរវាចូលគ្នាឱ្យសព្វ។

**វិធីទី៥:**

នៅពេលអ្នកគ្រុនឈឺក្បាល ប្រើស្លឹកជីក្រហមស្រស់លាយជាមួយទឹកក្ដៅបន្តិច រួចទទួលទានកាករបស់វាអាចយកមកបិទពីលើថ្ងាស៕




# Khmer Post Subscription form

Khmer Post subscription is $10 for 1month -$30 for 3 month - $50 for 6 months and $100 for12 months
The price is only for mailing - We send your personal mail via Post office.

យើងទទួលយកតែ"ម៉ានីអ័រឌឺ"តែប៉ុណ្ណោះ -We accepte only Money or

អាស័យដ្ឋាន Khmer Post address :45 Merrimack St.Suite 218A Lowell, MA 01852

ទូរស័ព្ទ Phone : off.978 677 7163 -Soben's Cell.978-656 8141 - Roger Cell. 978 - 942 1641

<<www.Khmerpostusa.us>> publication is 2 issues per month

## បណ្ណបញ្ជាទិញកាសែត"ខ្មែរផុសស.រ.អា"

## Khmer Post subscription order

ឈ្មោះ - My name..........................................................................

អាស័យដ្ឋាន -Addresse......................................................................

..................................................................................................

ខ្ញុំចង់ជាវកាសែតខ្មែរផុសស.រ.អា...................ខែ.........តម្លៃជាវ..............ដុល្លារ

I'd like to subscribe KhmerPostusa for ........... Month-
Subscrition price $......................

# ទើបបើកថ្មី

## Grand Opening

**AUG. 1st, 2015**




120 Cross St. Lowell, MA 01852 (Formerly CMAA Building)

www.lowellacademy.net, **978-459-5300**

**ផ្តើមចុះឈ្មោះ ពីឡូវនេះ!**

**សូមអញ្ជើញមកចូលរួមអបអរថ្ងៃសម្ភោធ និង**
**កាត់ខ្សែបូវិទ្យាស្ថាន ថែសម្ផស្ស និងធ្វើក្រចក នៅឡូវែល**

You are cordially invited to the Grand Opening & Ribbing Cutting of Lowell Esthetic and Nail Academy

**Date : Saturday, August 1, 2015**

**Time: 1:00PM to 5:00 PM**

**Foods and Refreshments will be served**



Certifications

- Esthetics • Nail

យកសញ្ញាប័ត្រ

•ថែសម្ផស្ស •ធ្វើក្រចក

- Class Start Aug. 31st, 2015 (Day, Nights, and Weekends)
  ថ្នាក់ផ្តើមថ្ងៃទី ៣១ សីហា ២០១៥ (បីវេនៈ ថ្ងៃ, យប់, ចុងសប្តាហ៍)
- Services : ESL Class * Transportation *Job Placements * Tutoring for Exams
  សេវាកម្ម : ថ្នាក់ ESL -ដឹកជញ្ជូនទៅមក -ជួយរកការងារឱ្យធ្វើ -ណែនាំឱ្យប្រឡងជាប់-

**Call To Enrol Now!**
**978-459-5300**

More information, please contact : Senghap Roeun, Director: (978) 888-8099